# ព្រះបាទ ជ័យវរ្ម័នទី ៧
# Jayavarman VII



**ទុក្ខរបស់ប្រជារាស្ត្រ ជាសេចក្ដីទុក្ខខាងផ្លូវចិត្ត ដែលមានសេចក្ដីឈឺចាប់ខ្លាំងណាស់**
**ទោះបីមិនមែនជាសេចក្ដីទុក្ខរបស់ព្រះអង្គ តែជាសេចក្ដីទុក្ខសំរាប់អ្នកគ្រប់គ្រង**
**The misery of people is painful mental misery.**
**Even though it is not his's misery, it is quardian's misery.**

សិក្សាស្រាវជ្រាវ និងរៀបរៀងដោយ
ព្រះភិក្ខុ **សុង ធន់** ( ធម្មនាថោ )

Research and Composed by
**Pra Song Thourn**

www.elibraryofcambodia.org

ទំណោយពីលោក ម៉ៅ ឃុនសិរីវ័ន
កក្កដា ២០15

# ព្រះបាទ ជ័យវរ្ម័នទី ៧

# Jayavarman VII

សិក្សាស្រាវជ្រាវ និងរៀបរៀងដោយ
ព្រះភិក្ខុ **សួង ធន់ (ធម្មនាថោ)**

Research and Composed by
**Pra Song Thourn**

បោះពុម្ពលើកទី ១
រក្សាសិទ្ធិគ្រប់បែបយ៉ាង

ព.ស. ២៥៥៧ គ.ស. ២០១៣

www.elibraryofcambodia.org

**រោងពុម្ព ម៉េង ហាវ**

**MENG HAO PRINTING HOUSE**

អាសយដ្ឋាន : ផ្ទះលេខ៨១ ផ្លូវ១៧២ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ ភ្នំពេញ ( ខាងលិច **វត្តឧណ្ណាលោម** ប្រហែល២០០ម៉ែត្រ)

ទូរសព្ទ : ០១២ ៨២៦ ៩២០ / ០១២ ៧៧៩ ១០០ / ០១២ ៧១២ ៧១៥

អ៊ីម៉ែល : hao_print@yahoo.com / heangprint@gmail.com

www.elibraryofcambodia.org

# អារម្ភកថា

សៀវភៅនេះបានកើតឡើងដោយការជួយបណ្តុះគំនិត របស់ញោម បណ្ឌិត **ឆែម ទៀង** សមាជិកវិទ្យាស្ថានបណ្ឌិតសភាជាតិកម្ពុជា តាមរយៈការបណ្តុះគំនិតនេះពោលគឺចាប់ពី២០០៧មក អ្នករៀបរៀងដែលមិនធ្លាប់បានចាប់អារម្មណ៍សិក្សាអំពីប្រវត្តិសាស្ត្រ និងបុរាណស្ថានខ្មែរពីមុនមកក៏ចាប់ផ្តើមចាប់អារម្មណ៍សិក្សាអំពីប្រវត្តិសាស្ត្រ និងសាសនស្ថានខ្មែរ។

លុះដល់ឆ្នាំ២០០៩ អ្នករៀបរៀងមានឱកាសសិក្សាបន្តថ្នាក់អនុបណ្ឌិតនៅសកលវិទ្យាល័យ (Mahamakutrajavidyalaya University) ដោយសកលវិទ្យាល័យតំរូវអោយសរសេរកិច្ចការស្រាវជ្រាវ។ ក្នុងពេលជាមួយគ្នានេះ អ្នករៀបរៀងក៏បានលើកយករជ្ជកាលព្រះមហាក្សត្រខ្មែរដ៏អច្ឆ-រិយរបស់ព្រះអង្គនាសម័យមហានគរគឺ ព្រះបាទជ័យវរ្ម័នទី៧ មកសិក្សាដោយយល់ឃើញថា ប្រធានបទខាងលើពុំសូវមានអ្នកសេរសេរ ព្រមទាំងមានឯកសារចំនួនតិចតួចដែលស្តីអំពីរជ្ជកាលរបស់ព្រះអង្គ ដែលជាហេតុធ្វើអោយកូនខ្មែរមួយចំនួនមានយល់ដឹងមិនសូវច្បាស់អំពីរជ្ជកាលព្រះអង្គដែលជារជ្ជកាលមួយ អាណាចក្រខ្មែរបុរាណមានការរីកចំរើនជាងសម័យណាៗទាំងអស់។

ក្រោយពីការសរសេរកិច្ចការស្រាវជ្រាវ ដែលទាក់ទងនិងប្រធានបទខាងលើរួច អ្នករៀបរៀងបានបកប្រែពីអត្ថបទដើមជាភាសាថៃមកជាភាសាខ្មែរ ដើម្បីធ្វើឯកសារសំរាប់អោយកូនខ្មែរបានសិក្សា ព្រមទាំងស្វែងយល់



www.elibraryofcambodia.org

អំពីរជ្ជកាលដ៏រុងរឿងរបស់ព្រះអង្គអោយកាន់តែប្រសើរឡើង។

អ្នករៀបរៀងមិនអាចចាត់ទុកបានថា សៀវភៅនេះជាឯកសារប្រមូលផ្ដុំនូវព្រឹត្តិការណ៍ក្នុងរជ្ជកាលរបស់ព្រះបាទជ័យវរ្ម័នទី៧ អោយបានគ្រប់ជ្រុងជ្រោយបានទេ តែអ្នករៀបរៀងសង្ឃឹមថា សៀវភៅនេះពិតជានឹងផ្ដល់នូវចំណេះចំពោះអ្នកអានអោយបានស្គាល់អំពីរបបសង្គម និងការគ្រប់គ្រងក្នុងរជ្ជរបស់ព្រះអង្គបានមួយកំរិត។

ក្នុងពេលនេះផងដែរ អ្នករៀបរៀងក៏សូមអភ័យទោសនូវចំនុចខ្វះខាត និងកំហុសឆ្គងដោយមិនអាចជៀសផុតបាន ហើយក៏សូមទទួលដោយរីករាយនូវពាក្យរិះគន់ក្នុងន័យស្ថាបនា ដើម្បីយកមកកែតំរូវអត្ថបទនេះអោយកាន់ប្រសើរឡើង។

សូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះម្ចាស់អត្ថបទ ម្ចាស់ឯកសារ និងម្ចាស់រូបភាព ដែលអ្នករៀបរៀងបានលើកយកមកចងក្រងសៀវភៅនេះ។ ព្រមទាំងថ្លែងអំណរព្រះគុណចំពោះព្រះភិក្ខុ **ថាច់ គឿន** (សុជាតោ) សមណនិសិត្សសកលវិទ្យាល័យ មហាចុឡាឡុងកនរាជវិទ្យា-ល័យ សាខាខេត្តសុរិន្ទ្រ ព្រះភិក្ខុ **ចាន់ ជឿន** សមណនិសិត្សសកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា និងលោក **សុខ ដារ៉ា** បរិបញ្ញាអក្សរសាស្ត្រភាសាអង់គ្លេសសកលវិទ្យាល័យភ្នំពេញអន្តរជាតិ ដែលមេត្តាជួយផ្ទៀងផ្ទាត់អក្ខរាវិរុទ្ធ។

បុណ្យកុសលដែលកើតចេញពីសៀវភៅនេះ សូមឧទិសចំពោះបុព្វ-បុរសខ្មែរ ដែលបានសង់នូវបុរាណស្ថានដ៏មានសារៈប្រយោជន៍ដល់កូនខ្មែរ



www.elibraryofcambodia.org

ព្រមទាំងមនុស្សជាតិជំនាន់ក្រោយ ព្រមទាំងអ្នកប្រាជ្ញខ្មែរ និងបរទេស ដែលបានខិតខំសិក្សាស្រាវជ្រាវនូវមរតកដ៏ថ្លៃថ្លានេះ សូមអស់លោកទាំងនោះបានទៅសោយសុខក្នុងសុខក្នុងគតិភពកុំបីអាក់ខានឡើយ។

**វត្តបុទុមវាលសុវណ្ណារាម ខេត្តសុរិន្ទ ប្រទេសថៃ**

**ថ្ងៃទី ១១ កុម្ភៈ ២០១២**

**អ្នករៀបរៀង**

**ព្រះភិក្ខុ សួន ឆន់ (ឆន្ទធារោ)**

**មរិញ្ញាបត្រ (ទស្សនវិជ្ជាព្រះពុទ្ធសាសនា)**

**(Mahachulalongkornrajavidyalaya University)**

**អនុបណ្ឌិត (ការគ្រប់គ្រង)**

**(Mahamakutrajavidyalaya University)**



www.elibraryofcambodia.org

www.elibraryofcambodia.org

មាតិការ ទំព័រ


១. ព្រះរាជជីវប្រវត្តិនិងព្រឹត្តិការណ៍មុនគ្រងរាជ្យ ........ ១

២. ព្រះបាទជ័យវរ្ម័នទី៧និងការអភិវឌ្ឍន៍របបសង្គម ........ ២៧

២.១.១ ការស្ថាបនារាជធានីអង្គរធំជារាជធានីថ្មី ........ ៣០

២.១.២ ប្រាសាទព្រះខ័ន ........ ៣៦

២.១.៣ ប្រាសាទតាព្រហ្ម ........ ៣៩

២.១.៤ ប្រាសាទនាគព័ន្ធ ........ ៤១

២.១.៥ ប្រាសាទបាយ័ន ........ ៤៦

២.១.៦ ប្រាសាទបន្ទាយក្តី ........ ៥៥

២.១.៧ ប្រាសាទបន្ទាយឆ្មារ ........ ៥៦

២.១.៨ ប្រាសាទបន្ទាយទ័ព ........ ៨៣

២.១.៨ ប្រាសាទតាព្រហ្ម ........ ៨៤

២.២ សមិទ្ធិផលដែលបន្សល់ទុកប្រទេសថៃបច្ចុប្បន្ន ........ ៨៥

២.២.១ ប្រាសាទវត្តកំផែងលែង ........ ៨៦

២.២.២ ប្រាសាទប្រាង្គសាមយ៉ត ........ ៩៤

២.២.៣ ប្រាសាទមឿងសិង្ហ ........ ៩៩

២.២.៤ ប្រាសាទវត្តព្រះផាយហ្លួង ........ ១០៧

២.២.៥ ប្រាសាទភីម៉ាយ ........ ១០៨

២.២.៦ ប្រាសាទប្រាង្គដែង ........ ១១៩

៣. ព្រះបាទជ័យវរ្ម័នទី ៧ និងវិស័យសុខាភិបាល ........ ១២១

៣.១ អង្គប្រកបនៃមន្ទីរពេទ្យ ........ ១២៩

៣.២ រូបបដិមាករដែលដំកល់ទុកក្នុងមន្ទីរពេទ្យ ........ ១៤៥

៣.៣ ឧបករណ៍និងទីតាំងរបស់មន្ទីរពេទ្យ ........ ១៥២




www.elibraryofcambodia.org

៣.៤ ទំរង់ប្លង់និងផ្នែកស្ថាបត្យកម្មនៃព្រះវិហារប្រចាំមន្ទីរ ..... ១៥៥
៣.៥ ទំរង់ប្លង់នៃមន្ទីរពេទ្យ ..... ១៥៦
៣.៦ ការគ្រប់រគងក្នុងមន្ទីរពេទ្យ ..... ១៦៥
៣.៧ ឧបករណ៍និងនិសថបុរាណដែលប្រើក្នុងមន្ទីរមន្ទីរពេទ្យ ..... ១៦៩
៣.៦ ចំនួនមន្ទីរទេព្យដែលបានរកឃើញនាបច្ចុប្បន្ន ..... ១៧១
៤. រាជមគ្គានិងធម្មសាលា ..... ២០៥
៥. ការធ្វើដំណើរបស់រាជទូតចិន (ជីតាក្វាន់) ..... ២២៤
៦. ឯកសារពិគ្រោះ ..... ២៣៨
៧. ប្រវត្តិអ្នករៀបរៀង ..... ២៤៣



www.elibraryofcambodia.org

## ១. ព្រះរាជជីវប្រវត្តិនិងព្រឹត្តិការណ៍មុនគ្រងរាជ្យ

ព្រះបាទជ័យវរ្ម័នទី៧ទ្រង់ប្រសូត្រប្រហែលឆ្នាំ១១២០ ឬយ៉ាងហោចណាស់ក៏ក្នុងឆ្នាំ១១២៥ក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី២។ ព្រះអង្គបានរៀបអភិសេកតាំងតែព្រះអង្គនៅព្រះជន្មក្មេងនៅឡើយ ជាមួយនិងព្រះនាងជ័យរាជទេវី ដែលមានឥទ្ធិពលជាច្រើនចំពោះព្រះអង្គទៀតផង។ ក្នុងពេលវេលាដែលដឹងមិនច្បាស់មួយព្រះបាទជ័យវរ្ម័នទី៧ទ្រង់យាងចាកចេញពីអាណាចក្រខ្មែរដើម្បីនាំកងទ័ពទៅច្បាំងនិងអាណាចក្រចម្ប៉ាក្នុងក្រុងវិជ័យ[១] គឺក្រុងបិញឌិញប្រទេសវៀតណាមបច្ចុប្បន្ន។

ការដែលស្ដេចយាងចេញធ្វើសឹកសង្គ្រាមពេលនេះបាននាំនូវសេចក្ដីទុក្ខសោកចំពោះព្រះនាងជ័យរាជទេវីជាខ្លាំង។ ដូចដែលបានកត់ត្រាទុកក្នុងសលាចារឹកក្នុងព្រះរាជវាំង ដែលព្រះជេដ្ឋភគនីរបស់ព្រះនាងជាអ្នកកត់ត្រាសិលាចារឹកបានកត់ត្រាថា «ព្រះរាជាយាទ្រង់មានទឹកព្រះនេត្រជោគព្រះភក្ត្រកន្សែងដូចនាងសីតាកន្សែងអាល័យព្រះស្វាមីដែលទ្រង់ឃ្លាតទៅ

---

[១] បញ្ហាការដែលព្រះអង្គយាងទៅច្បាំងជាមួយអាណាចក្រម្ប៉ានេះ ជាការសន្និដ្ឋានរបស់អ្នករៀបរៀងប៉ុណ្ណោះ ព្រោះតាមរយៈអត្ថបទក្នុងសិលាចារឹកមិនបានបញ្ជាក់ថា ព្រះអង្គយាងទៅច្បាំងនិងអាណាចក្រចម្ប៉ានោះទេ គ្រាន់តែបញ្ជាក់ថា ព្រះអង្គយាងទៅអាណាចក្រចម្ប៉ា យើងមិនអាចដឹងច្បាស់ថា ព្រះអង្គយាងទៅអាណាចក្រចម្ប៉ាពេលនេះជាការយាងទៅក្នុងលក្ខណៈការទូត ឬចាប់ជាឈ្លើយសឹក ឬព្រះអង្គភៀសព្រះកាយ ឬក៏និរទេសព្រះអង្គយ៉ាងណាមួយនោះទេ។



www.elibraryofcambodia.org

ទ្រង់បានខិតខំប្តូងសួងអោយព្រះស្វាមីទ្រង់យាងត្រឡប់មកវិញ និងទ្រង់ព្យាយាមគេចចេញពីសេចក្តីទុក្ខដោយការបំពេញតបធម៌ តាមមគ្គានៃសាសនាព្រាហ្មណ៍» តែនៅទីបំផុតទ្រង់ក៏បានរកឃើញនូវសេចក្តីត្រជាត់ត្រជុំក្នុងព្រះពុទ្ធសាសនា។ សិលាចារឹកបានកត់ត្រាបន្តទៀតថា «ទ្រង់បានទទួលពាក្យប្រៀនប្រដៅពីព្រះនាងជេស្ឋភគិនី គឺព្រះនាងឥន្ទ្រទេវី អោយពិចារណាព្រះពុទ្ធជាម្ចាស់ជាទីតាំងនៃការបំពេញតបធម៌របស់ព្រះនាង ដោយទ្រង់ជ្រើសរើសមគ្គាដ៏ត្រជាក់ត្រជុំរបស់ព្រះអរិយបុគ្គល»។

ក្នុងពេលដែលព្រះបាទជ័យវរ្ម័នទី ៧ ទ្រង់កំពុងស្នាក់នៅក្នុងអាណាចក្រចម្ប៉ានោះ។ ព្រះបិតារបស់ព្រះអង្គគឺព្រះបាទធរណីន្ទ្រវរ្ម័នទី២ ទ្រង់ចូលទិវង្គត់។ ព្រះបាទយសោយវរ្ម័នទី២ ដែលគ្មានអ្នកណាដឹងថា ព្រះអង្គជាប់សាច់សាលោហិតពីខាងណាស្តេចឡើងគ្រងរាជបន្ត។ ក្នុងរជ្ជកាលរបស់ព្រះបាទយសោវរ្ម័នទី២ មានព្រឹត្តិការណ៍សំខាន់ដែលបានចារឹកទុកក្នុងប្រាសាទបន្ទាយឆ្មារ ព្រមទាំងមានរូបចំលាក់រឿងនេះទុកក្នុងប្រាសាទនេះផងដែរ។ ព្រះបាទយសោវរ្ម័នទី២ ត្រូវទទួលរងគ្រោះដោយការលួចវាយប្រហារដោយពួកអាថិកំបាំង ដែលក្នុងសិលាចារឹកប្រើពាក្យថា «រាហូ» ហើយក្នុងរូបចំលាក់នោះក៏ជារូបរបស់រាហូផងដែរ។ តែព្រះរាជាត្រូវបានទទួលការជួយសង្គ្រោះពីសំណាក់ព្រះរាជកុមារ ដែលសន្និដ្ឋានថា ជាព្រះរាជបុត្ររបស់ព្រះ ជ័យវរ្ម័នទី៧។



www.elibraryofcambodia.org

យើងមិនអាចដឹងបានថា អ្នកណាជារាហូ និងអ្វីជាមូលហេតុនៃការក្បត់របស់ពួកគេនោះទេ។ ឈ្មោះរបស់គេធ្វើអោយនឹកឃើញ ដល់រាហូក្នុងរឿងនិទានដែលព្យាយាមនិងលេបព្រះអាទិត្យ និងព្រះចន្ទនៅពេលមានសុរិយគ្រាស ឬ ចន្ទគ្រាស ដែលព្យាយាមការពារមិនអោយខ្លួនលួចទឹកអម្រិតដែលបានមកពីការកូរទឹកសមុទ្រ។ ដូចនេះពាក្យថា រាហូ ជាឈ្មោះបុគ្គលដែលចូលចិត្តការបំផ្លិចបំផ្លាញ និងជាបុគ្គល់ដែលគួរអោយខ្លាច។ ដោយហេតុនេះឈ្មោះ រាហូ សមគួរដល់ឈ្មោះសំរាប់មេដឹកនាំក្បត់បាន។

មិនយូរប៉ុន្មានក្រោយពីរហេតុការណ៍ក្នុងឆ្នាំ ១១៦៥ ព្រះបាទយសោវរ្ម័នទី២ ទ្រង់ត្រូវបានប្លុងព្រះជន្មដោយមន្ត្រីធំម្នាក់ក្នុងព្រះរាជវាំង ហើយប្រកាសខ្លួនជាស្តេចផែនដីដោយមានព្រះនាមថា ត្រីភូវនាទិត្យវរ្ម័ន គឺអ្នកមានព្រះអាទិត្យនៃលោកទាំងបីជាអ្នកថែរក្សា។



www.elibraryofcambodia.org

## ការឡើងគ្រងរាជរបស់ព្រះបាទត្រីភូវនាទិត្យវរ្ម័ន

ព្រះបាទត្រីភូវនាទិត្យវរ្ម័ន ទ្រង់បានគ្រងរាជសម្បត្តិក្នុងក្រុងអង្គរអស់រយៈពេល១២ឆ្នាំ។ យើងមិនអាចដឹងបានថា ការដណ្តើមរាជរបស់ព្រះអង្គបានបង្កអោយកើតហេតុការណ៍អ្វីខ្លះក្នុងអាណាចក្រខ្មែរនោះទេ។ តែទោះបីជាយ៉ាងណាក៏ដោយ តាមរយៈសិលាចារឹកប្រាសាទភិមានអាកាសបានអោយដឹងថា ពេលដំណឹងនេះបានឮទៅដល់អាណាចក្រចម្ប៉ា។ ព្រះបាទ-ជ័យវរ្ម័នទី៧ ស្តេចយាងមកយ៉ាងប្រញាប់ដើម្បីជួយសង្គ្រោះព្រះបាទយសោវរ្ម័នទី២ ឬពេលខ្លះមានអ្នកគិតថា ព្រះអង្គក៏ត្រូវការអាងសិទ្ធិក្នុងការគ្រងរាជ្យ ព្រោះរាជបល្ល័ង្កនេះធ្លាប់ជារបស់ព្រះបិតារបស់ព្រះអង្គ។ តែដោយព្រះបាទយសោយវរ្ម័នទី២ ត្រូវបានបាត់បងទាំងរាជសម្បត្តិ និងព្រះជន្មរួចទៅហើយ។

ព្រះបាទជ័យវរ្ម័នទី៧ ទ្រង់បានសំរេចព្រះទ័យគង់នៅអាណាចក្រខ្មែរដើម្បីរង់ចាំឱកាសដ៏សមរម្យក្នុងការជួយសង្គ្រោះប្រទេសជាតិ ដែលពោរពេញទៅដោយអថ្នាកម្ម។ ចំណែកព្រះនាងជ័យរាជទេវី ពេលទ្រង់បានព្រះស្វាមីយាងត្រឡប់មកវិញដូចនេះទ្រង់ក៏ឈប់សូត្រមន្តបួងសួងទៀត។ ដោយទ្រង់មានព្រះរាជគោលបំណងអោយព្រះស្វាមីជួយរំដោះប្រទេសជាតិអោយរួចផុតពីអន្លង់មហណ្ណពនៃគ្រោះកម្ម ដែលប្រទេសជាតិកំពុងធ្លាក់ទៅក្នុងគ្រោះមហន្តរាយយ៉ាងជ្រៅ។



www.elibraryofcambodia.org

## កងទ័ពចាមវាយដណ្ដើមយកក្រុងអង្គរបានក្នុងឆ្នាំ ១១៦៦

ដោយប្រមាណក្នុងឆ្នាំ១១៦៦ ចំពេលដែលអាណាចក្រខ្មែរមានអ្នកក្បត់ដណ្ដើមរាជបល្ល័ង្កនោះ ក៏មានអ្នកឆ្លៀតឱកាសគឺព្រះបាទ ជ័យឥន្ទ្រវរ្ម័នបានដណ្ដើមរាជបល្ល័ង្ករបស់អាណាចក្រចម្ប៉ាដូចគ្នាផងដែរ។ ណយោបាយដំបូងរបស់ព្រះអង្គ គឺអែបអបនិងអាណាចក្រយួន ឬ យ៉ាងហោចណាស់ក៏ធ្វើអោយព្រះអង្គទុកព្រះទ័យថា អាណាចក្រយួននិងនៅជាអាជ្ញាកណ្ដាលក្នុងរឿងនេះ។

ក្នុងឆ្នាំ១១៧០ ព្រះបាទជ័យឥន្ទ្រវរ្ម័ន បានបញ្ជូនរាជទូតនាំគ្រឿងបណ្ណាការទៅថ្វាយស្ដេចចក្រពត្តិលីអញតោន (LianhTon) នៃចក្រភពចិន។ ក្រោយពីនោះពេលដែលព្រះអង្គទ្រង់ទុកព្រះទ័យនិងស្ថានការណ៍តាមព្រំដែនភាគខាងជើងរួចហើយ ព្រះអង្គក៏បែរព្រះទ័យចង់រុករានអាណាចក្រខ្មែរ។ តាមរយៈសិលាចារឹកក្នុងព្រះរាជវាំងបានអោយដឹងថា ព្រះបាទជ័យឥន្ទ្រវរ្ម័នស្ដេចនៃអាណាចម្ប៉ា ទ្រង់ក្លាហានដូចរាវនៈ (Ravana) (សត្រូវរបស់ព្រះរាម) បានលើកទ័ពរបស់ព្រះអង្គដោយរថសិកក៏ខ្លាំងខ្លាចាប់ផ្ដើមវាយប្រហារតាមព្រំដែនរបស់អាណាខ្មែរ លឿនប្រៀបដូចផ្លេចបន្ទោរ។ តែកងទ័ពចាមមិនអាចវាយប្រហារចូលក្នុងអាណាខ្មែរបាន ព្រះបាទជ័យឥន្ទ្រវ៌ន ទ្រង់ប្ដូរផែនការរបស់ព្រះអង្គ និងសំរេចព្រះទ័យលើកកងទ័ពតាមជើងទឹកដើម្បីកុំអោយអាណាចក្រខ្មែរដឹងខ្លួន។



www.elibraryofcambodia.org

ក្នុងឆ្នាំ ១១៧៧ ព្រះបាទជ័យឥន្ទ្រវរ្ម័នទ្រង់បានលើកកងទ័ពជើងទឹក ដោយធ្វើដំណើរតាម ឆ្នេរសមុទ្រប្រទេសវៀតណាមបច្ចុប្បន្ន ហើយឡើងតាមដងទន្លេមេគង្គ និងឆ្លងកាត់តាមបឹងទន្លេសាបឡើងតាមស្ទឹងសៀមរាប កងទ័ពចាមលើកមកម្តងនេះជាការលើកមកយ៉ាងទាន់ហន់យ៉ាងពិតប្រាកដ ក្រុងអង្គរមិនបានត្រៀមការការពារអ្វីសោះឡើយ។ តាំងតែកសាងក្រុងអង្គរនេះមកទីក្រុងនេះ មិនធ្លាប់ទទួលរងការកំរាមកំហែងពីសំណាក់កងទ័ពបរទេសណាមួយឡើយ កំពែងការពារក្រុងអង្គរ ដែលបានកសាងតាំងតែសម័យព្រះបាទយសោវរ្ម័នទី១ ក៏ចាស់ទ្រុឌទ្រោមណាស់ទៅហើយ។ម្យ៉ាងទៀតកំពែងនេះក៏មិនបានហ៊ុំព័ទ្ធក្រុងអង្គរបានគ្រប់ផ្នែក។ មជ្ឈមណ្ឌលនយោបាយ និងសាសនា ក៏មាននៅចំពោះជុំវិញព្រះរាជវាំងប៉ុណ្ណោះ។ អាចមានតែប្រាសាទអង្គរវត្តមួយគត់ ដែលមានកំពែងនិងគូទឹកព័ទ្ធជុំវិញ។

តែជាការពិតដែលថា ទាំងកំពែង និងគូទឹកដែលព័ទ្ធជុំវិញប្រាសាទអង្គរវត្តមិនបានកសាងឡើងដើម្បីជាបន្ទាយការពារសិកសត្រូវនោះទេ។ ការពារក្រុងអង្គរ ឬ យសោធបុរៈនោះមិនមែនជាការកាពោរដោយយោធា តែជាការការពារដោយសាសនា។

តាំងតែរជ្ជកាលព្រះបាទយសោវរ្ម័នទី១មក ព្រះរាជាខ្មែរទាំងឡាយបានកសាងក្រុងអង្គរអោយជាកន្លែងស្ថិតរបស់អទិទេព ដែលមិនអាចមានអ្នកណាមកបំផ្លាញបាន។ ដូចនេះក្រុងអង្គរត្រូវបានកាន់កាប់ដោយកងទ័ពចាម ទោះបីមានការកាពារទុកដូច្នេះក៏ដោយសេចក្តីវិនាស និងមានការ



www.elibraryofcambodia.org

កើតឡើងយ៉ាងពិតប្រាកដក។ ទ័ពចាមបានគ្រប់គ្រងក្រុងអង្គរ ព្រមទាំងកាប់សំលាប់និងប្លន់ទីក្រុងនេះ ព្រះបាទត្រីភូវនាទិត្យវរ្ម័ន បានអស់ព្រះជន្មក្នុងសមរភូមិប្រយុទ្ធដ៏ក្តៅគគុត។

សិលាចារឹកប្រាសាទវិមានអាកាសបានអោយដឹងថា «ស្តេចចាមក្នុងការចម្បាំងដែលធ្វើអោយក្រេវក្រោធដោយព្រះយម (អទិទេពនៃសេចក្តីស្លាប់) ដែលគង់នៅទិសខាងត្បូង និងចុះបន្ទាបដោយព្រះអាទិត្យ (ដែលធ្វើអោយកើតសេចក្តីសំរេចក្នុងការចម្បាំង) ចាប់ព្រះរាជា (នៃអាណាចក្រខ្មែរ) ដែលពោពេញទៅដោយភាពរន្ធត់ នៃទង្វើរបស់ព្រះអង្គ (ព្រះរាជាចាម) ក៏ត្រាស់អោយប្រហារ ជីវិតភ្លាម»។

## ផលវិបាកនៃជ័យជំនះរបស់កងទ័ពចាម

កងទ័ពចាមកាន់កាប់ក្រុងអង្គរអស់រយៈពេល៤ឆ្នាំ ប្រព័ន្ធខាងសាសនាដែលបានកសាងតាំងតែរជ្ជកាលព្រះបាទយសោវរ្ម័នទី១ និងព្រះ_រាជាដែលគ្រងរាជក្រោយៗមកទៀតត្រូវរាំងស្ទះ។ ក្រុងអង្គររវាងការគ្រប់គ្រងរបស់កងទ័ពចាមក្នុងអំឡុង៤ឆ្នាំនេះជាយ៉ាងណានោះ? ការប្លន់និងការកាប់សំលាប់មិនមែនចំពោះឃ្លាំងរបស់ព្រះរាជា និងទ្រព្យសម្បត្តិរបស់ប្រជារាស្ត្រប៉ុណ្ណោះ។ រូបអទិទេពដែលនៅថែរក្សាក្រុងអង្គរក៏ត្រូវបាននាំទៅអាណាចក្រចម្ប៉ាផងដែរ ឬមិនដូច្នេះក៏ត្រូវបំផ្លាញដើម្បីកុំអោយស័ក្តិសិទ្ធទៅទៀត។ ទោះបីជាណាក៏ដោយ ក្រុងអង្គរមិនត្រូវបានបំផ្លាញអោយ



www.elibraryofcambodia.org

សាបនោះទេ។ ព្រះរាជបំណងរបស់ព្រះបាទជ័យឥន្ទ្រវរ្ម័ន ស្តេចនៃអាណាចក្រចាម គឺដើម្បីបំផ្លាញអាណាចក្រខ្មែរដែលមានអ្នកដណ្តើមរាជសម្បត្តិកំពុងគ្រប់គ្រង។

តាមកំណត់ហេតុរបស់ប្រវត្តិសាស្ត្រចិនបានអោយដឹងថា ការបង្ក្រាបរបស់អាណាចក្រចម្ប៉ាមកលើអាណាចក្រខ្មែរយ៉ាងឃោឃៅបំផុត ដោយពោលថា «ព្រះរាជាចាមទ្រង់បានវាយប្រហាររាជធានីរបស់អាណាខ្មែរយ៉ាងលឿនដូចផ្ទេកបន្ទោរដោយកងទ័ពជើងទឹកដ៏ខ្លាំងក្លា បានកាប់សំលាប់ និងប្លន់ក្រុងអង្គរនិងប្រហារជីវិតព្រះរាជាខ្មែរ ដោយមិនព្រមស្តាប់ពាក្យអង្វរករសុំសន្តិភាពឡើយ» ហេតុដូចនេះបង្កអោយកើតគំនុំគំគួនយ៉ាងធ្ងន់ធ្ងរដែលជាផលតាមមកក្នុងឆ្នាំទី៥នៃស័ក្តរាជតិងយួន (Kingyan) គឺត្រូវនិងឆ្នាំ១១៩៩។ គំនុំគំកួនដ៏ធ្ងន់ធ្ងរនេះបង្កអោយមានចលនារំដោះជាតិឡើងដែលមានព្រះបាទជ័យវរ្ម័នទី៧ទ្រង់ជាអ្នកដឹកនាំ។



www.elibraryofcambodia.org

## ចលនារំដោះឯករាជ្យរបស់អាណាចក្រខ្មែរក្រោមការដឹកនាំព្រះបាទជ័យវរ្ម័នទី ៧

យើងមិនអាចដឹងបានថាព្រះបាទជ័យវរ្ម័នទី៧ទ្រង់បានត្រៀមការតស៊ូ និងពួកឈ្លានពានយ៉ាងដូចម្ដេច ឬនៅទីកន្លែងណានោះទេ?[២] (តែបញ្ហាទីកន្លែងដែលព្រះអង្គដឹកនាំប្រមូលកងទ័ពកំចាត់សត្រូវឈ្លានពាននេះ អ្នករៀបរៀងសន្និដ្ឋានថា នៅម្ដុំខាងជើងភ្នំដងរែក ស្ថិតនៅភាគឦសានប្រទេសថៃបច្ចុប្បន្ន ព្រោះថា បើនៅភាគខាងកើតនអាណាចក្រខ្មែរ គឺជាប់និងអាណាចក្រចម្ប៉ា ឬបើនៅភាគកណ្ដាល គឺនៅជិតនិងព្រះបាទត្រីភូវរ្ម័នដែលជាសត្រូវរបស់ព្រះអង្គ។ ម្យ៉ាងទៀតបញ្ហាដែលយើងគួរគិតផងដែរនោះ នៅភាគឦសានប្រទេសថៃបច្ចុប្បន្នព្រះបាទជ័យវរ្ម័នទី៧ បានសាងមន្ទីរ និងសាសនស្ថាននានាច្រើនជាងតំបន់ដ៏ទៃទៀតក្នុងអាណាចក្រខ្មែរនាសម័យនោះ) ។

---

2 បញ្ហាទីកន្លែងដែលព្រះបាទជ័យទី៧ ទ្រង់ដឹកនាំប្រមូលកងទ័ពកំចាត់សត្រូវឈ្លានពាននេះអ្នករៀបរៀងសន្និដ្ឋានថា នៅតំបន់ភ្នំដងរែកដែលបច្ចុប្បន្ន គឺភាគខាងជើងនៃព្រះរាជាណាចក្រកម្ពុជា និងភាគឦសានប្រទេសថៃ។ ព្រោះថា បើនៅភាគខាងកើតអាណាចក្រខ្មែរ គឺជាប់និងអាណាចក្រចម្ប៉ា ឬបើនៅភាគកណ្ដាល គឺនៅជិតនិងព្រះបាទត្រីភូវរ្ម័ន ដែលជាសត្រូវរបស់ព្រះអង្គ។ ម្យ៉ាងទៀតបញ្ហាដែលយើងគួរសង្កេតផងដែរនោះ នៅតីនៅបរិវេណភ្នំដងរែកនេះ ព្រះបាទជ័យ-វរ្ម័នទី៧ បានសាងមន្ទីរទេព្យនិងសាសនស្ថាននានាច្រើនជាងតំបន់ដ៏ទៃទៀតក្នុងអាណាចក្រខ្មែរនាសម័យនោះ



www.elibraryofcambodia.org

ក្នុងផ្នែកសាសនាដែលនៅក្នុងសិលាចារិក ដែលជាឯកសារសំខាន់ដែលទាក់ទងនិងព្រះរាជជីវប្រវត្តិរបស់ព្រះបាទជ័យវរ្ម័នទី៧ គឺសិលាចារិកប្រាសាទព្រះខ័ន សិលាចារិកប្រាសាទតាព្រហ្ម។ សិលាចារិកធំមួយក្នុងប្រាសាទវិមានអាកាសបានកត់ត្រាពីការកាន់សីលភាវនា ដែលព្រះមហេសីដ៏សំខាន់របស់ព្រះអង្គ គឺព្រះនាងជ័យរាជទេវីទ្រង់បានប្រត្តិបត្តិដ៏យូរលង់ដោយពោលថា ដោយការឧទិសខ្លួនដ៏ឧត្តុងឧត្តមថ្វាយចំពោះព្រះស្វាមីម្ចាស់ស្រ្តីអ្នកប្រកបដោយអំពើល្អនិងសេចក្តីករុណាព្រះអង្គនេះ ទ្រង់មានព្រះរាជគោលបំណង និងឃើញព្រះនគរបានរួចផុតពីអន្លង់ នៃសេចក្តីទុក្ខសោកដែលព្រះនគរកំពុងធ្លាក់ចុះយ៉ាងជ្រៅ។ សិលាចារិកដូចគ្នានេះដែរក៏បានកត់ត្រាយ៉ាងខ្លីៗទាក់ទង និងការច្បាំងរបស់ព្រះបាទជ័យវរ្ម័នទី ៧ ត្រង់គាថាទី៧០បានកត់ត្រាថា «ទ្រង់មានសេចក្តីអត់ធ្មត់ក្នុងសេចក្តីទុក្ខដែលកើតពីជ័យជំនះក្នុងការចំបាំង (របស់ព្រះរាជានៃអាណាចក្រចម្ប៉ា ព្រះអង្គនេះ) ដែលមានទាហានដូចមហាសមុទ្រដែលគ្មានកោះត្រើយ ក្រោយពីទ្រង់បានធ្វើពិធីរាជាពិសេករួចហើយ ព្រះអង្គ (ព្រះបាទជ័យវរ្ម័ន ទី៧) ទ្រង់បានគ្រប់គ្រងដែនដីដ៏បរិសុទ្ធដែលអាចពោលបានថា ជាទីប្រថាប់របស់ព្រះអង្គដោយការបង្ក្រាបក្រុងវិជ័យ (រាជធានីរបស់អាណាចក្រចម្ប៉ា) និងនគរផ្សេងៗទៀត»។

យើងមិនអាចដឹងអោយបានច្បាស់លាស់អំពីការប្រយុទ្ធគ្នាដែលកើតឡើងនោះទេ តែហាក់ដូចជាកើតឡើងក្នុងដំបន់ព្រះខ័ន នៅទិសខាងជើងក្រុងអង្គរ។ ការប្រយុទ្ធគ្នាចុងក្រោយទំនងជាការប្រយុទ្ធគ្នាតាមជើងទឹក



www.elibraryofcambodia.org

ដែលមានរូបភាពធ្លាក់នៅតាមប្រាសាទបន្ទាយឆ្មារនិងប្រាសាទបាយ័ន។ រូបចំលាក់ក្នុងប្រាសាទប្រាយ័ននេះគឺសំខាន់បំផុត ព្រោះហេតុថា ឆ្លាក់នៅលើជញ្ជាំងថែវមួយផ្នែកពេញតែម្តង។ រូបចំលាក់ទាំងនេះចែកចេញជាច្រើនជយរ។ ជារូបចំលាក់ទូកចំបាំងរវាងកងទ័ពខ្មែរ និងកងទ័ពចាមកំពុងជួបគ្នាមុខគ្នានៅជិតក្បាលទូកនីមួយៗ ទាហានបានប្រុងប្រៀបខ្លួនស្ទុះទៅវាយលុកទូកមួយទៀត។ គេអាចស្គាល់ទាហានខ្មែរបានដោយមិនពាក់ប្លុក និងកាត់សក់ខ្លី។ ចំណែកទាហានចាមពាក់មួកកាតិបយ៉ាងចំឡែក ហើយមានទំរង់ដូចជាផ្កាដាក់ផ្កាប់នៅលើក្បាល។ ក្នុងរូបចំលាក់គេឃើញទូករបស់ទាហានខ្មែរនិងទាហានចាមចូលមកជួបគ្នា ការប្រយុទ្ធគ្នារវាងខ្លួននិងខ្លួនក៏ផ្តើមឡើងអ្នកស្លាប់ ឬរបួសត្រូវបានធ្លាក់ចូលទៅក្នុងទឹក ដែលមានក្រពើជាច្រើនកំពុងរង់ចាំស្រាប់។ ផ្នែកខាងលើក៏មានរូបចំលាក់ការប្រយុទ្ធគ្នានៅលើដីផងដែរ។ នៅខាងក្រោមដំបូលមានរូបចំលាក់ព្រះបាទជ័យវរ្ម័នទី៧ ដែលកំពុងដឹកនាំការប្រយុទ្ធដោយព្រះអង្គផ្ទាល់។ ដោយគង់នៅក្រោមក្លស់កណ្តាលសមរភូមិប្រយុទ្ធ និងទ្រង់កំពុងជួយបណ្តេញសត្រូវអោយចេញទៅខាងក្រោមរូបចំលាក់ការប្រយុទ្ធនេះ ក៏បានឆ្លាក់បង្ហាញពីទិដ្ឋភាពទូទៅ នៃជីវភាពប្រចាំថ្ងៃរបស់ប្រជារាស្ត្រខ្មែរជាជួរវែង។ មានទាំងរូបភាពផ្ទះសំបែងទីផ្សារ ជាសកម្មភាពដែលកើតមានក្នុងក្រុងអង្គរ ក្រោយរជ្ជកាល ព្រះបាទជ័យវរ្ម័នទី៧។ រយៈពេលនៃជ័យជំនះរបស់ព្រះបាទជ័យវរ្ម័នទី៧ លើកងទ័ពចាមមិនអាចដឹងបានច្បាស់ទេតែអាចកើតឡើងមុន ១១៨១ ដែលជាឆ្នាំរាជាភិសេករបស់ព្រះអង្គ។



www.elibraryofcambodia.org

ពិធីអាចប្រព្រឹត្តិទៅបានក៏លុះត្រាណាកងទ័ពចាមដកថយចេញអស់ពីអាណាចក្រខ្មែរ និងក្រោយពីការផុសផុលក្រុងអង្គរយ៉ាងហោចណាស់ក៏បានមួយចំណែកដែរ។ ទាំងនេះព្រោះថា ក្រុងនេះបានទទួលរងនូវការបំផ្លិចបំផ្លាញនូវបដិមាកម្មដ៏មានដំលៃព្រមទាំងទ្រព្យ សម្បត្តិក៏ត្រូវបានដឹកចេញពីសាសនស្ថានផ្សេងៗ ការកសាងនិងការទំនុកបំរុងទាំងផ្នែកសាសនា និងសម្ភារៈក្នុងក្រុងអង្គរជាភារកិច្ចដ៏ធ្ងន់ធ្ងរសំរាប់ព្រះបាទជ័យវរ្ម័នទី៧ត្រូវធ្វើ តែដំបូងព្រះអង្គត្រូវមានជ័យ យ៉ាងដាច់ខាតលើកងទ័ពចាមជាមុនសិន ដើម្បីកុំអោយសត្រូវពួកនេះត្រឡប់មកជាថ្មីទៀត។

ការតស៊ូនិងអាណាចក្រចម្បាប្រព្រឹត្តិទៅអស់រយៈពេលយូរអង្វែង និងសែនលំបាកព្រះបាទជ័យវរ្ម័នទី៧បានសំរេចព្រះទ័យធ្វើ ការតស៊ូនេះបានដល់ទីបញ្ចប់។ តាមការកត់ត្រារបស់អ្នកប្រវត្តិសាស្រ្ត ចិនបានអោយដឹងថាព្រះរាជាខ្មែរទ្រង់បានសច្ចាធ្វើការសងសឹកនឹងសត្រូវរបស់ព្រះអង្គ ទង្វើរនេះបានទទួលជោគជ័យក្រោយពីព្រះអង្គ បានសំងំពួននិងការប្រឹងប្រែងយ៉ាងអត់ធ្មត់អស់រយៈពេល១៨ឆ្នាំ។

តែមុនពេលដែលព្រះអង្គនឹងធ្វើការសងសឹកនេះ ព្រះអង្គចាំបាច់ត្រូវបង្ក្រាបការបះបោក្នុងអណាចក្ររបស់ព្រះអង្គជាមុនសិន។ ការបះបោរនេះបានកើតទេឡើងក្នុងតំបន់មួយឈ្មោះថា ម៉លយាំង (Malyang) ស្ថិតនៅខាងត្បូងនៃខេត្តបាត់ដំបងសព្វថ្ងៃ។ ក្នុងការបង្ក្រាបនេះព្រះអង្គបានទុកព្រះទ័យអោយព្រះអង្គម្ចាស់ វិទ្យានន្ទនៈ ដែលបានមកជ្រកកោណក្នុង



www.elibraryofcambodia.org

អាណាចក្រខ្មែរ។ សិលាចារឹកភាសាចាមក្នុងក្រុងម៉ាយសន (MiSon) បានអោយដឹងថា ព្រះអង្គម្ចាស់ វិទ្យានន្ទនៈស្តេចយាងមកអាណាចក្រខ្មែរ ក្នុងឆ្នាំ១១៨១ ចំពេលដែលព្រះអង្គនៅជាយុវជនស្តេចនៃអាណាចក្រខ្មែរ (ព្រះបាទជ័យវរ្ម័នទី៧ ដែលទើបនិងគ្រងរជ្ជកាលពីឆ្នាំទៅទ្រង់ឃើញថា យុវក្សត្រអង្គនេះប្រកបដោយមហាបុរសពេញលក្ខណៈ៣២ប្រការ ទ្រង់បាន ប្រោសប្រណី និងបង្រៀនន្ទូវបណ្តាវិជ្ជាការផ្សេងៗព្រមទាំងកលយុទ្ធគ្រប់ បែបយ៉ាងអោយព្រះអង្គម្ចាស់វិទ្យានន្ទនៈទៀតផង។ ចំពេលជាមួយគ្នានេះ ផងដែរមានតំបន់មួយក្នុងអាណាចក្រខ្មែរឈ្មោះម័លយាំងមានប្រជារាស្ត្របះ បោរប្រឆាំងនិងព្រះមហាក្សត្រ។ ព្រះបាទជ័យវរ្ម័នទី៧ទ្រង់យល់ថា អ្នក អង្គម្ចាស់វិទ្យានន្ទនៈនេះមានជំនាញការខ្ពស់ក្នុងយុទ្ធវិធីទើបប្រោសអោយនាំ កងទ័ពទៅបង្ក្រាប។ អ្នកអង្គម្ចាស់វិទ្យានន្ទនៈបានធ្វើអោយជោគជ័យតាម ដែលព្រះបាទជ័យវរ្ម័នទី៧ត្រូវការគ្រប់ប្រការ ព្រះអង្គបានតែងតាំងអ្នកអង្គ ម្ចាស់វិទ្យានន្ទនៈជាយុវរាជនិងព្រះរាជទានរង្វាន់ ដែលអាណាចក្រខ្មែរអាច អោយបានដល់អ្នកអង្គម្ចាស់ទៀតផង។

អ្នកអង្គម្ចាស់វិទ្យានន្ទនៈនៅបានជួយព្រះបាទជ័យវរ្ម័នទី៧ សងសឹក និងអាណាចម្ប៉ាទៀតផង។ ក្នុងឆ្នាំ១១៩០ព្រះបាទជ័យឥន្ទ្រវរ្ម័នទី៤ នៃ អាណាចក្រចាមបានលើកទ័ពមកឈ្លានពានអាណាចក្រខ្មែរទៀត។ យើង មិនអាចដឹងបានថា ព្រះបាទជ័យវរ្ម័នទី៧ទ្រង់បានចូលរួមច្បាំង និងការ ឈ្លានពានរបស់ពួកចាម ឬមួយក៏អត់នោះទេ។



www.elibraryofcambodia.org

តាមរយៈសិលាចារឹកត្រាំងអាណាចក្រចាមបានអោយដឹងថា ព្រះបាទជ័យវរ្ម័នទី៧ទ្រង់វាយដណ្ដើមបានរាជធានីរបស់អាណាចក្រចាម និងប្រមូលយកមកវិញនូវសិវលឹង្គដែលពួកចាមប្រមូលយកទៅ។ ស្ដេចចាមគឺព្រះបាទជ័យឥន្ទ្រវរ្ម័នទី៤ត្រូវបានចាប់ជាឈ្លើយសឹក និងបញ្ជូនមកអាណាចក្រខ្មែរ។ ព្រះបាទជ័យវរ្ម័នទី៧ទ្រង់បាន បែងចែកអាណាចក្រចាមជាពីរចំណែកគឺ មួយចំណែកគ្រប់គ្រងដោយប្អូនថ្លៃរបស់ព្រះអង្គ និងមួយចំណែកទៀតគ្រប់គ្រងដោយអ្នកអង្គម្ចាស់វិទ្យានន្ទនៈ។ តែស្ថានភាពបែបនេះមិនអាចស្ថិតនៅបានយូរអង្វែងបាន ព្រោះក្រោយមកមានការបះបោកើតឡើងក្នុងក្រុងបិញឌិញ។ ពួកបះបោបានបណ្ដេញប្អូនថ្លៃរបស់ព្រះបាទជ័យវរ្ម័នទី៧ចេញពីអាណាចក្រចាម។ ព្រះបាទវិទ្យានន្ទនៈ បានប្រកាសឯករាជលែងមានជំលោះអាណាចក្រខ្មែរតទៅទៀត ហើយព្រះអង្គបង្រួបបង្រួមអាណាចក្រចាមអោយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ព្រះអង្គតែមួយអង្គប៉ុណ្ណោះ បន្ទាប់ពីព្រះអង្គទ្រង់បានប្រហារជីវិតព្រះបាទ ជ័យឥន្ទ្រវរ្ម័នទី៤ ដែលព្រះបាទជ័យវរ្ម័នទី៧ទ្រង់បានដោះលែងពីពន្ធនាគារ អោយទៅច្បាំងនិងព្រះបាទវិទ្យានន្ទនៈ។ រហូតដល់ឆ្នាំ១២០៣ ព្រះបាទវិទ្យានន្ទនៈ ត្រូវបានបណ្ដេញចេញពីរាជបល្ល័ង្គដោយព្រះបិតាលារបស់ព្រះអង្គឯងដែលបានទទួលការជួយឧបត្ថម្ភពីអាណាចក្រខ្មែរ ចាប់ពីឆ្នាំ១២០៣_១២២០ អាណាចក្រចម្ប៉ាក្លាយជាខេត្តរបស់អាណាចក្រខ្មែរប៉ុណ្ណោះ។



www.elibraryofcambodia.org

ទោះជាយ៉ាងណាក៏ដោយការដែលព្រះបាទជ័យវរ្ម័នទី៧ ទ្រង់ជួបនូវការលំបាកជាមួយនិងប្រទេសខាងកើត តែក៏មិនបានជំទាស់ព្រះអង្គក្នុងការពង្រីកអំណាចទៅទិសខាងលិចនិងទិសខាងជើងនោះទេ។ សិលាចារឹកខ្មែរដែលបានរកឃើញទិសខាងជើងបំផុតគឺ សិលាចារិក សាយហ្វុងជាប់និងក្រុងវៀងចន្ទប្រទេសឡាវបច្ចុប្បន្ន។ ចំណែកអ្នកប្រវត្តិសាស្ត្រមិនបានកត់ត្រាថា ព្រះជ័យវរ្ម័នទី៧ទ្រង់មានព្រះរាជអំណាចចូលទៅដល់ភូមិភាគខ្លះនៃជ្រោយម៉ាលេយូ និងពង្រីកការគ្រប់គ្រងចូលទៅក្នុងប្រទេសភូមា។ តាមរយៈសិលាចារឹកប្រាសាទព្រះខ័នបានអោយដឹងថា ទឹកដែលប្រើក្នុងព្រះរាជពិធីអភិសេកនោះបានាំមកថ្វាយពីព្រាហ្មណ៍ឈ្មោះ សុរិយភដ្ត និងពីព្រាហ្មណ៍ផ្សេងៗទៀតរួមទាំងស្តេចនៃអាណាចក្រជ្វា (ស្តេចនៃអាណាចក្រយវនៈ) ស្តេចទាំងពីរនៃអាណាចក្រចាម។

យើងដឹងហើយថាការយកទឹកជាគ្រឿងបណ្តាការនោះជា និមិត្តរូបនៃស្វាមីភ័ក្ត និងជាលក្ខណៈនៃប្រទេសចំណុះទោះបីបច្ចុប្បន្ននេះក្នុងរាជវាំងក្រុងភ្នំពេញក្នុងឱកាសមានរាជាភិសេក។ ទឹកស័ក្តសិទ្ធដែលយកមកប្រើក្នុងពិធីនេះក៏យកមកប្រភពទឹកផ្សេងៗទូទាំងប្រទេស។ម្យ៉ាងទៀត ព្រះបរមតេជានុភាពរបស់ព្រះបាទជ័យវរ្ម័នទី៧ នៅមានទំហំធំធេងនិងការចងសម្ព័ន្ធភាពរវាងរាជវង្សរបស់ព្រះអង្គដោយការរៀបអាពាហ៍ពិពាហ៍។ សិលាចារឹកប្រាសាទព្រះខ័នបានពោលថា ចំពោះអ្នកដែលមានសេចក្តីសម្បូណ៍គង់វង់ដែលព្រះអង្គបានព្រះរាជទានអោយហើយ ព្រះអង្គក៏នៅ



www.elibraryofcambodia.org

ព្រះរាជទានព្រះរាជធិតាដែលទ្រង់សិរីឆោម អោយរៀបអភិសេកទៀតផង។ ក្នុងពេលជាមួយគ្នាផងដែរ ព្រះអង្គត្រូវទទួលទុក្ខសោកដោយការបាត់បង់ព្រះមហេសី ដែលបានចូលទីវង្គត់ក្រោយពីទ្រង់បានធ្វើទាន។ និងបានរួបរួមទ្រព្យសម្បត្តិថ្វាយចំពោះសាសនស្ថានសំខាន់ក្នុងអាណាចក្ររហូតធ្វើអោយបញ្ជីរទ្រព្យសម្បត្តិ ដែលថ្វាយចំពោះសាសនាស្ថានមានអត្ថន័យវែងពេញសិលាចារិកទាំងអស់ដែលរកឃើញក្នុងព្រះរាជវាំង។ ម្យ៉ាងទៀតដូចដែលយើងបានដឹងច្បាស់ហើយថា ទ្រង់មានព្រះជេស្ឋភគនីដែលតាមសិលាចារឹកពោលថា ទ្រង់មានបញ្ញាលើសអ្នកប្រាជ្ញ។ ព្រះបាទជ័យវរ្ម័នទី៧ ទ្រង់តែងតាំងព្រះនាងជាសាស្តាចារ្យធំក្នុងវត្តព្រះពុទ្ធសាសនា ព្រះនាងបានព្រទានការបង្រៀនដល់ស្ត្រីទាំងឡាយ។ ពេលព្រះមហេសីចូលទីវង្គត់ទៅព្រះបាទជ័យវរ្ម័នទី៧ទ្រង់រៀបអភិសេកជាមួយព្រះនាងឥន្ទ្រទេវីនិងទ្រង់តែងតាំងអោយព្រះនាងជាមហេសីឯក។ តែយ៉ាងណាក៏ដោយតំណែងដ៏ខ្ពង់ខ្ពស់នេះមិនបានធ្វើអោយព្រះនាងបត់បែនចេញពីការស្វែងរកវិជ្ជាគុណ ចំពោះស្ត្រីដែលមានសេចក្តីប្រាថ្នាយ៉ាងមុតមាំក្នុងវិជ្ជាគុណ ព្រះនាងទ្រង់បានជួយផ្សព្វផ្សាយព្រះមហាករុណាធិគុណ របស់ព្រះបាទជ័យវរ្ម័នទី៧ក្នុងរូបនៃវិជ្ជាដូចទឹកអម្រិត។ ព្រះនាងទ្រង់បានតែងចារឹកដែលបានរកឃើញក្នុងព្រះរាជវាំងក្រុងអង្គរធំជាភាសាសំស្ក្រិត ដែលរកអ្នកណាមកប្រៀបផ្ទឹមពុំបាន។



www.elibraryofcambodia.org

ទាក់ទងនិងការចូលទីវង្គត់របស់ព្រះបាទ័យវរ្ម័នទី៧ យើងមិនអាចដឹងទាំងស្ថានការណ៍និងមូលហេតុអ្វីទាំងអស់ត្រឹមតែដឹងថា ព្រះអង្គនៅគ្រងរាជ្យក្នុងឆ្នាំ១២០១ ព្រោះជាឆ្នាំដែលព្រះអង្គទ្រង់បញ្ជូនរាជទូតទៅកាន់ប្រទេសចិន។ មានភស្តុតាងប្រការខ្លះដែលធ្វើអោយយើងគិតថា ព្រះអង្គអាចចូលទីវង្គត់ប្រហែលក្នុងឆ្នាំ១២១៩ ពេលដែលទ្រង់មានព្រះជន្មច្រើនណាស់ទៅហើយ គឺមានព្រះជន្មាយុច្រើនជាង៩០វស្សា។

តាមលក្ខណៈព្រះវរកាយរបស់ព្រះបាទជ័យវរ្ម័នទី៧ គឺទ្រង់ហាក់ដូចជាមានលក្ខណៈធាត់ព្រះវរកាយធំ ព្រះកេសាក្របួចជាផ្នួងតូចៗនៅលើព្រះកេសា។ តាមភស្តុតាងទាក់ទងនិងព្រះរាជជីវប្រវត្តិរបស់ព្រះអង្គប្រការខ្លះនិងឃើញដោយមនោភាពបានបង្ហាញអោយយើងដឹងថា ព្រះអង្គជាមហាបុរសដែលមានភាពរឹងមាំភាពអត់ធ្មត់ និងមានសេចក្តីប្រាថ្នាច្រើនក្រោយពីការរង់ចាំនិងជួបប្រទះនូវសេចក្តីលំបាកអស់រយៈពេលយូរ ក៏អាចរំដោះប្រទេសជាតិអោយរួចផុតពីការគ្រប់គ្រងរបស់បរទេស និងទំនុកបំរុងអោយចំរើនរុងរឿងខ្ពង់ខ្ពស់បំផុតក្នុងប្រវត្តិសាស្ត្រខ្មែរ។

សិលាចារិកទាំងឡាយបានពោលពីព្រះអង្គដោយសរសើរថា ទ្រង់ជាអ្នកមានសទ្ធាយ៉ាងមុតមាំក្នុងព្រះពុទ្ធសាសនា។ ដូចសិលាចារិកប្រាសាទតាព្រហ្មណ៍បានចារឹកថា «មគ្គានៃធម៌ដែលនាំទៅរកព្រះនិពាន្តជាធម៌ដែលប្រាសចាគឧបសគ្គក្នុងការចូលដល់សច្ចធម៌ ជាធម៌ដែលព្រះអរិយបុគ្គលរមែងសរសើរក្នុងលោកទាំងបី និងជាដាវដែលបំផ្លាញព្រៃរបស់កិលេស។



www.elibraryofcambodia.org

ព្រះអង្គទ្រង់បានទទួលមរតកនៃសទ្ធានេះពីព្រះរាជបិតារបស់ព្រះអង្គ ដែលទ្រង់បានផ្តាច់ពីប្រពៃណីព្រះរាជាព្រះអង្គមុនៗធ្លាប់ប្រតិបត្តិមក។

បើយើងនិយាយអោយចំ គឺព្រះអង្គជាអ្នកបដិវត្តរបបគ្រង ដ៏សំខាន់បំផុតមួយក្នុងប្រវត្តិសាស្ត្រខ្មែរ ព្រោះថាព្រះរាជាអង្គមុនៗទ្រង់សម្ព័ន្ធភាពជាមួយព្រះអទិទេព ជាពិសេសព្រះសិវៈតែយូៗម្តង គេឃើញព្រះអង្គបូជាព្រះវិស្ណុ ឬពេលខ្លះក៏រួមទាំងពីរព្រះអង្គបញ្ចូលគ្នាហៅថាហរិហរៈ។ ចំណែកព្រះរាជាមិនថាព្រះអង្គនៅមានព្រះជន្ម ឬចូលទីវង្គត់ព្រះអង្គមានតេជបារមីស្មើរនិងព្រះអទិទេពដែលព្រះអង្គគោរពបូជា ដូចជាព្រះអង្គគោរពព្រះសិវៈព្រះអង្គក៏ឋានៈស្មើនិងព្រះសិវៈផងដែរ។ ចំណែកព្រះបាទជ័យវរ្ម័នទី៧ទ្រង់បានផ្លាស់ប្តូររបបដើមច្រើនយ៉ាង ដោយមិនចាត់ទុកព្រះអង្គជាព្រះអទិទេព ឬព្រះអង្គនិងត្រូវទៅស្ថិតជាមួយព្រះអទិទេព ក្រោយពេលចូលទីវង្គត់ទៅតែព្រះអង្គទ្រង់ចាត់ទុកព្រះអង្គជាព្រះពោធិសត្វឬព្រះពុទ្ធជាម្ចាស់ ដែលកំពុងមានព្រះជន្មដោយព្រះអង្គមិនព្រមចូលនិព្វាន្ត តែព្រះអង្គនៅចាំជួយស្រោចស្រង់ប្រជារាស្ត្រអោយផុតទុក្ខ (នេះជាគតិថ្មី)ដោយព្រះអង្គជឿថាការជួយរំដោះទុក្ខអោយដល់ប្រជារាស្ត្រព្រះអង្គដែលជាព្រះមហាក្សត្រក៏បានរួចាកផុតទុក្ខផងដែរ។

សិលាចារឹកដូចគ្នានេះផងដែរបានពោលបន្តទៀតថា«ព្រះអង្គទ្រង់បានរកឃើញអម្រិតធម៌បានដល់ព្រះសាសនានៃព្រះស្រីសាក្យមុនី ដែលនេះក៏គឺព្រះពុទ្ធសាសនាលទ្ធិមហាយានដែលគោរពព្រះពោធិសត្វលោកេស្វរៈជាធំ»



www.elibraryofcambodia.org

## ២.ព្រះបាទជ័យវរ្ម័នទី ៧និងការអភិវឌ្ឍន៍បែបសង្គម

ព្រះបាទជ័យវរ្ម័នទី៧ ជាព្រះមហាក្សត្រដ៏អច្ឆរិយមួយព្រះអង្គនាសម័យមហានគរ ពាក្យថាអច្ឆរិយនេះមិនមែនមានក្នុងសិលាចារឹក ឬមានអ្នកមកដាក់ព្រះនាមអោយព្រះអង្គនោះទេ តែជាការដាក់ឈ្មោះរបស់អ្នកប្រាជ្ញដែលគេបានរកឃើញនូវស្នាព្រះហស្តរបស់ព្រះអង្គ ដោយស្នាព្រះហត្ថទាំងនោះមានទំហំធំធេងខ្លាំងណាស់ ពោលគឺសំណង់កសាងរបស់ព្រះអង្គបានសង់ឡើងដើម្បីបំរើអោយវិស័យសង្គមកិច្ច និងសាសនាមាននៅរាយពាសពេញប្រទេស ខ្មែរ ថៃ ឡាវនាបច្ចុប្បន្ន។

ស្នាព្រះរបស់ព្រះអង្គមានអ្នកប្រាជ្ញខ្លះសង្ស័យថា មិនអាចទៅរួចដែលសង់ឡើងរួចរាល់ក្នុងរជ្ជកាលរបស់ព្រះអង្គ វាអាចទៅរួចដែលថាសំណង់ការសាងទាំងនេះព្រះអង្គសង់បន្តពីរជ្ជស្តេចមុនៗ ហើយក៏មករួចរាល់ក្នុងរជ្ជកាលរបស់ព្រះអង្គឬអាចដែលថា ព្រះអង្គបានសាងសង់សម្ទិផលទាំងអស់នេះពិតមែន តែនៅមិនទាន់រួចរាល់ព្រះរាជាអង្គក្រោយៗ ក៏សង់បន្តរហូតរួចរាល់។

តែនេះជាសង្ស័យឬជាសន្និដ្ឋានរបស់អ្នកប្រាជ្ញជំនាន់ក្រោយតែប៉ុណ្ណោះភស្តុតាងដែលល្អបំផុតសំរាប់រឿងនេះគឺសិលាចារឹក និង ស្លាបត្យកម្មព្រោះសិលាចារឹក និងស្ថាបត្យកម្មបានកត់ត្រាពីការសាងសង់ទាន់ហេតុការណ៍។ ហើយបើយោងទៅតាមអត្ថបទសិលាចារឹក និងស្ថាបត្យកម្មសំណង់កសាងទាំងនេះគឺជាស្នាព្រះហត្ថរបស់ព្រះអង្គយ៉ាងពិតប្រាកដ។



www.elibraryofcambodia.org

ឧត្តមគតិរបស់ព្រះបាទជ័យវរ្ម័នទី៧គឺ «ការដែលជាមហាចក្រពត្តិដ៏កំពូលដូចគ្នានិងព្រះបាទអសោកមហារាជនៃប្រទេសឥណ្ឌា» ព្រះអង្គមានព្រះរាជគោលបំណងដែលទ្រង់ជាមាហាចក្រពត្តិដូចនេះអាចមកពីការព្រះអង្គត្រូវការអំណាច និងធ្វើអោយព្រះនគរមានការរីកចំរើនរុងរឿង និងគង់វង់។

ក្រោយពីព្រះអង្គបានបណ្តេញកងទ័ពចាមចេញអស់ពីអាណាចក្រខ្មែរ ព្រះអង្គបានងាកព្រះទ័យមកបង្រួបបង្រួមអាណាចក្រខ្មែរ ដែលបាត់បង់នៅពេលវិបត្តិនយោបាយមុនរជ្ជកាលព្រះអង្គឡើងវិញ។ ក្នុងតំបន់ទន្លេ ចៅព្រះយ៉ា (Chaopraya River) ស្ថិតនៅភាគខាងលិចប្រទេសថៃសព្វថ្ងៃ និងភាខាងត្បូងប្រទេសឡាវ។

តាមរយៈសិលាចារឹកអក្សរសាស្ត្រខ្មែរដែលបានរកឃើញនៅ សាយហ្វង ជិតក្រុងវៀងចន្ទ។ តែព្រះបាទជ័យវរ្ម័នទី៧ទ្រង់ជ្រាបច្បាស់ថាអាណាចក្រដែលដួលរលំទៅហើយ ក៏អាចត្រឡប់មានអំណាចជាថ្មីបានដូចគ្នានិងអាណាចក្រខ្មែរក្រោមការគ្រប់គ្រងរបស់ព្រះអង្គ។ ព្រះអង្គត្រូវការអោយព្រះនគររបស់ព្រះអង្គមានការការពារក្នុងកំរិតមួយដែលថា គ្មានអ្នកណាអាចមកបំផ្លាញបាន។ ក្នុងការសាងសង់រូបចំណងភ្នំព្រះសុមេរុឡើងក្នុងរាជធានីព្រះរាជាខ្មែរ ដែលគ្រងរាជ្យសម័យមុនព្រះអង្គ ព្រះអង្គបានគិតថា ទ្រង់បានសង់លោកនៃទេវតាឡើងកណ្តាលអាណាចក្រខ្មែរ។ តែក្តីសង្ឃឹមរបស់ព្រះរាជាទាំងនោះត្រូវបានរលាយសាបសូន្យ ដោយការឈ្លាន



www.elibraryofcambodia.org

ពានរបស់កងទ័ពចាមក្នុងឆ្នាំ**១១៧៧**។

ដូចនេះទើបសមគួរដែលព្រះអង្គនិងទ្រង់សាងសង់ការពារផ្នែកសាសនាអោយរឹងមាំជាងមុន។ ទំនងដោយហេតុនេះហើយដែលធ្វើអោយព្រះបាទជ័យវរ្ម័នទី៧ ទ្រង់សាងសាសនស្ថានវត្តអារាម ផ្លូវថ្នល់ទូទាំងអាណាចក្រជាពិសេសក្នុងដំបន់ក្រុងអង្គរ ដែលជាហេតុធ្វើអោយអាណាចក្រខ្មែរមានសំណង់កសាងពោលគឺប្រាង្គប្រាសាទច្រើនជាងសម័យណាៗទាំងអស់។



www.elibraryofcambodia.org

## ២.១.១ ការស្លាប់នារាជធានីអង្គរធំជារាជធានីថ្មី

រាជធានីអង្គរធំជារាជាធានីចុងក្រោយបំផុតនិងមានភាពរឹងមាំ និងភាពប្រណិតបំផុតក្នុងប្រវត្តិសាស្ត្រខ្មែរ កងទ័ពចាមបានវាយប្រហាររាជធានីអង្គរបានក្នុងឆ្នាំ១១៧៧ ប៉ុន្តែរាជធានីអង្គរមិនត្រូវបានបំផ្លាញអោយខ្ទេចខ្ទីរទាំងស្រុងនោះទេ។ រាជធានីអង្គរធំដែលព្រះបាទជ័យវរ្ម័នទី៧ ទ្រង់បានសង់ឡើងថ្មីនេះមិនចំរាជធានីអង្គរ ដែលកសាងដោយព្រះបាទ យសោវរ្ម័ននោះទេ។ វាមានវិសាលភាពតូចជាងហើយតាំងនៅហាក់ដូចជាលាតលន្ទឹងទៅទិសខាងជើងដោយមានប្រាសាទបាយ័ននៅចំណុចកណ្តាល។



ក្លោងទ្វាររាជធានីអង្គរធំ

រាជធានីអង្គរធំមានរាងបួនជ្រុង មានកំពែងសាងអំពីថ្មបាយក្រៀមព័ទ្ធជុំវិញដោយកំពែងជ្រុងនីមួយៗមានប្រវែងពាគីឡូម៉ែត្រ ដោយលើកដីខ្ពស់ដើម្បីទប់ជ្រែងពីខាងក្នុង ចំណែកពីខាងក្រៅកំពែងមានគូទឹកទទឹង



www.elibraryofcambodia.org

១០០ម៉ែត្រព័ទ្ធជុំវិញ។ ទ្វារចំនួន៥ដែលគេសង់ពុះតាមជញ្ជាំងកំពែងរាជធានី ធ្វើអោយអាចចូលទៅក្នុងរាជធានីបានតាមទិសខាងជើង ទិសខាងត្បូងនិង ទិសខាងលិច។ ដោយទិសនីមួយៗមានទ្វារមួយចំណែកទិសខាងកើតមាន ទ្វារពីរគឺទ្វារជ័យ និងទ្វារមរណៈ (ខ្មោច)។ នៅចំពីមុខទ្វារដែលជាផ្លូវចូល នីមួយៗ គេសង់ស្ពានកត់ទតឹងគូរទឹកនៅកន្លែងជ្រុងនីមួយៗនៃកំពែងរាជ ធានី គេសង់ប្រាសាទតូចៗដែលហៅថាប្រាសាទជ្រុងព្រមទាំងមានសិលា ចារឹកតាមប្រាសាទនីមួយទៀតផង។

ក្នុងបណ្តាសិលាចារឹកតាមប្រាសាទជ្រុងទាំងនេះបាននិយាយថា ព្រះជ័យវរ្ម័នទី៧ បានកសាងជ័យគីរីមួយ (Jayagiri) (ភ្នំនៃជ័យជំនះ) ទ្រព្យកោសល្យដោយពិតពីឋានសួគ៌ ដែលចែងចាំងដោយរស្មីរ និងជ័យ សិន្ធុ (yaSindhu) (សមុទ្រនៃជ័យជំនះ) ដែលជំរៅរបស់សមុទ្រនេះ គេ មិនអាចគណនាបាននៅឯឋានភ្នជុំងនាគ។

ដូចនេះកំពែងរាជធានីអង្គរធំទើបមានលក្ខណៈជានិមិត្តរូបច្រើនជាង សាងឡើងដើម្បីការពាររាជធានី ដូចជាកំពែងរាជធានីជានិមិត្តរូបដំណាង ដោយជួរភ្នំដែលព័ទ្ធជុំវិញចក្រវាល និងគូទឹកដែលព័ទ្ធជុំវិញរាជធានី ជា និមិត្តរូបដំណាងអោយមហាសមុទ្រក្នុងចក្រវាល ដែលគ្រប់គ្រងដោយ ស្តេចនាគ៨ ដែលទ្រទ្រង់ចក្រវាល។

នៅចំពីមុខទ្វារចូលនីមួយៗ ស្ពានដែលគេសង់ឆ្លងកាត់គូទឹកនោះ មានរូបពួកយក្សពីរជួរកំពុងតែទ្រសត្វនាគមួយ។ បើយើងដើរចូលទៅក្នុង



www.elibraryofcambodia.org

រាជធានីនិងបានឃើញនៅខាងឆ្វេង មានពួកទេវតាដែលមានព្រះភក្រ្តស្លូតបូត ហើយនៅពីលើក្បាលមានពាក់មុដរបស់ព្រះអទិទេព ចំណែកនៅខាងស្តាំ មានពួកយក្សភ្នែកលៃន ដែលនៅលើក្បាលមានពាក់មួកជាអ្នកចំបាំង និងលំអទៅដោយស្លឹកឈើ។ ពួកយក្សទាំងនោះទំនងជាទាញនាគមកវិញ ដើម្បីឃាត់កុំអោយរត់គេច។

លោក G.Coedés បានសន្និដ្ឋានថា រូបទាំងនោះគឺជាទំរង់ផ្ទររបស់ព្រះឥន្រ្ទ (ឥន្រ្ទនូ) ដែលភ្ជាប់ពីឋានទេវលោកមកឋានមនុស្សលោក។ ក្រៅពីនេះ នៅតាមក្លោងទ្វាររាជធានីអង្គរធំគេបានឆ្លាស់រូបព្រះឥន្រ្ទ ជាក្បាច់ត្រឡោកខ្ពស់ជិះនៅលើសត្វដំរីក្បាលបី។

ក្លោងទ្វារនីមួយៗនៃរាជធានីអង្គរធំ មានការសង់បន្ទីតពីលើនូវរូបក្បាលមនុស្ស៤។ លោក Boisisselier បានសន្និដ្ឋានថា រូបមនុស្សដែលមានមុខ៤នេះមិនមែនមានន័យថា ក្បាលមួយមានមុខ៤នោះទេ លោកគិតថា មុខទាំង៤គឺដំណាងអោយព្រះអទិទេព៤ ដែលសោយរាជ្យនៅទាំង៤ទិស (ខាងលិច ខាងកើត ខាងជើង និងខាងត្បូង)។

លក្ខណៈផ្នែកស្ថាបត្យកម្មនៃក្លោងទ្វាររាជធានីអង្គរធំ គឺជាភាពប៉ិនប្រសព្វដ៏អស្ចារ្យដែលគួរអោយកោតសរសើរក្រៃលែង។ នៅចំពីមុខក្លោងទ្វារខ្ពស់ៗទាំងនោះមានខ្សែបន្ទាត់ខ្ពស់ស្រលះមួយបានបន្លាយខ្លួនជាយក្ស២ជួរដ៏ខ្លាំងពូកែ។



www.elibraryofcambodia.org

## ព្រះរាជវាំងនិងតួនាទីសំខាន់នៃរាជធានីអង្គរធំ

សំរាប់អាគារដែលជាលំនៅដ្ឋានក្នុងព្រះបរមរាជធានីទាំងអស់ទំនង ជាសង់អំពីឈើ បច្ចុប្បន្នត្រូវបានវិនាសបាត់បង់អស់ហើយ។ ប៉ុន្តែយើង អាចឃើញនូវស្រះទឹក២ ដែលនៅក្នុងព្រះបរមរាជវាំង។ ស្រះមួយមានរូប ចំលាក់ក្នុងរចនាបថបាយ័នឆ្លាក់លើមាត់ស្រះ ជួរលើនៃចំលាក់ជារូបគ្រុឌ ឈ្នោលញីឈរជាជួរ ចំណែកនៅលើថ្នាក់ផ្នែកខាងក្រោម គេឆ្លាក់ជារូបត្រី និងសត្វទឹកក្នុងរឿងទេវកថា។

ពីមុខកំពែងព្រះរាជវាំងនិងគោបុរៈ (ក្លោងទ្វារ) ដែលកសាងឡើង នៅចុងសតវត្សទី១០ គេបានសង់ទីលានជល់ដំរីមួយដែលលាតសន្ធឹង ប្រវែងជាង៣០០ម៉ែត្រនៅពាក់កណ្តាលសតវត្សទី១៣ដោយបែរមុខទៅទិស ខាងកើត។ យើងអាចឡើងទៅដល់ផ្នែលកណ្តាលនិងចុងទីលានបាន តាមរយៈជណ្តើរទាំងឡាយដែលមានរាងជាជញ្ជាំងប្រាសាទ។ នៅសងខាង ជណ្តើរកណ្តាលគេឆ្លាក់ជារូបគ្រុឌ និងរូបតោឆ្លាស់គ្នាដើម្បីទ្រូរូបចំលាក់។ នៅលើជញ្ជាំងទីលានដែលមានជណ្តើរនៅចំកណាលនោះ គេឆ្លាក់ជាដំរីជា ជួរវែងចេញទៅទិសខាងជើងនិងទិសខាងកើត ហើយដំរីទាំងនោះខ្លះបាន ជួបប្រយុទ្ធជាមួយនិងសត្វព្រៃដែលជាសត្រូវ។

នៅខាងជើងទីលានជល់ដំរីនៅមានទីលានមួយទៀត ដែលគេបាន ដាក់ឈ្មោះថា ទីលានស្តេចកំលង់ ដែលបានឆ្លាក់លំអរដោយមនុស្សទាំង ឡាយកំពុងតែគិតបញ្ជីរ។



www.elibraryofcambodia.org

តាមការកាប់ឆ្ការព្រៃនាពេលថ្មីៗនេះបានបញ្ជាក់អោយដឹងថា មានការព្យាយាមពង្រីកទីលាននេះរហូតដល់ខាងជើងទៀត។ ទីលាននេះមាន ឈ្មោះហៅថាទីលានស្តេចកំលង់ ព្រោះស្ថាបត្យកម្មរូបបុគ្គលកំពុងលិតជង្គង់ដែលហៅជាសាមញ្ញថា ស្តេចកំលង់។




**ទីលានជល់ដំរី**



www.elibraryofcambodia.org






រូបស្តេចកំលង់

តាមពិតរូបនេះមិនមែនជារូបបុគ្គល់ដែលកើតរោគឃ្លង់ទេ តែជារូបព្រះអទិទេពដែលលំបាកសំគាល់បានថាព្រះអទិទេពអង្គណាមួយពិតប្រាកដ ដោយរូបនេះចាត់ទុកជាស្ថាបត្យកម្មដ៏ល្អបំផុតមួយ ក្នុងបណ្តាស្ថាបត្យក្នុងរចនាបថបាយ័នដែលលំអរដោយថ្មរបបូរមាត់រាងជាទំពក់ ដែលគេអាចសំគាល់បានថាព្រះអទិទេពនៃសេចក្តីស្លាប់ឬនរក (ព្រះយមរាជ)។



www.elibraryofcambodia.org

## ២.១.២ ប្រាសាទព្រះខ័ន (Prasat Preah Khan)

កំពែងខាងក្រៅរបស់ប្រាសាទព្រះខ័នមានរាងបួនជ្រុងទ្រវែង ព័ទ្ធជុំវិញផ្ទៃដីទំហំ ៧០០×៨០០ម៉ែត្រ កំពែងនេះព័ទ្ធជុំវិញទីកន្លែងមួយដែលព្រះបាទជ័យវរ្ម័នទី៧ ទ្រង់ផ្ដើមបានជ័យជំនះលើកងទ័ពចាម។ សិលាចារិកប្រាសាទព្រះខ័ន បានពោលសរសើរពីកសាងរាជធានីនេះដែលមានឈ្មោះថា ជ័យស្រី (ជោគលាភនៃជ័យជំនះ) ក្នុងគថាទី៣២ចារឹកថា «ក្នុងទីកន្លែងដែលមានការប្រយុទ្ធដែល ជាទីកន្លែងសំរាប់ទទួលលោហិតរបស់សត្រូវព្រះអង្គរទ្រង់បានទទួលជ័យជំនះ (ជ័យស្រី) ព្រះអង្គទ្រង់បានកសាងរាជធានីដែលមានឈ្មោះដូចនេះ (ជ័យស្រី) ក្នុងទីកន្លែងនេះ» សិលានិងផ្កាឈូកមាស បានប្រែពណ៌នៃផែនដីនិងចាំងមកម្ដងពួទៀតរហូតដល់បច្ចុប្បន្នប្រៀបដូចថាបានត្រូវ... ឈ្មោះសព្វថ្ងៃរបស់ប្រាសាទព្រះខ័ន។ ព្រះខ័នមានន័យថា ជាសាស្ត្រាវុធដ៏ស័ក្ដសិទ្ធដែលសព្វថ្ងៃរក្សាទុកក្នុងព្រះរាជវាំងក្រុងភ្នំពេញ។ ចាត់ទុកជាវត្ថុស័ក្តសិទ្ធសំរាប់អាណាចក្រខ្មែរ។

យើងអាចចូលទៅកាន់ប្រាសាទព្រះខ័នបានតាមច្រកចូល៤ ដែលនៅសងខាងផ្លូវមានយក្ស២ជួរកំពុងទាញនាគមួយម្ខាង។ ផ្លូវចូលទាំងនេះដូចគ្នានិងផ្លូលក្រុងអង្គរធំ។ ដូចនេះប្រាសាទព្រះខ័នមិនមែនត្រឹមតែជាសាសនស្ថានប៉ុណ្ណោះតែជាក្រុងមួយដូចគ្នានិងក្រុងអង្គរធំផងដែរ។ នៅពីមុខផ្លូវចូលនៃទិសខាងលិចនិងទិសខាងកើត មានផ្លូវដើរដែលមានសរសេរសងខាងផ្លូវខាងក្នុងប្រាសាទ។ ព្រះបាទជ័យវរ្ម័នទី៧ទ្រង់បានឆ្លាក់រូប



www.elibraryofcambodia.org

ព្រះបិតារបស់ព្រះអង្គក្នុងឆ្នាំ១១៩១ក្រោមរូបព្រះពោធិសត្វលោកេស្វរៈ (ព្រះលោកេស្វរៈ ជាព្រះពោធិសត្វដែលមិនព្រម និងត្រាស់ជាព្រះពុទ្ធជាម្ចាស់) តែទ្រង់បានបដិសេធនិងចូលនិព្វាន។ ទាំងនេះក៏ដើម្បីជួយសង្គ្រោះសត្វលោកទាំងឡាយមិនត្រឹមតែការរស់នៅប៉ុណ្ណោះ តែនៅជួយកំចាត់ភ័យវិប័តផ្សេងៗផង។ ព្រះអង្គមានព្រះនាមលោកេស្វរៈដែលប្រែថាអ្នកជាធំនៃលោកឬអវលោកិតេស្វរៈគឺអ្នកដែលសំលឹងមកពីខាងលើ ដោយសេចក្តីមេត្តា។

បដិមាកម្មដូចពោលគឺព្រះលោកេស្វរៈ អ្នកមានព្រះនាមថាស្រីជ័យវរ្ម័នស្វរៈ ដែលជាអទិទេពគ្រប់គ្រងរក្សាព្រះបាទជ័យវរ្ម័នទី៧ រូបព្រះពោធិសត្វលោកេស្វរៈមានចំនួនច្រើនណាស់ទាំងនេះព្រោះហេតុថា ការគោរពចំពោះព្រះពោធិសត្វ។ អ្នកទ្រទ្រង់នូវមហាករុណារបស់ព្រះអង្គនេះបានផ្សព្វផ្សាយចេញទៅយ៉ាងទូលំទូលាយ។ នៅក្នុងប្រាសាទឬហោជាងនៃ ប្រាសាទរមែងមានរូបរបស់ព្រះអង្គ ដែលអាចស្គាល់បានពីរូបព្រះធយានិ ឬព្រះពុទ្ធអមិតាភដែលមានពន្លឺគ្មានទីបញ្ចប់ គង់សមាធិលើផ្នួងសក់របស់ព្រះលោកេស្វរៈនៅជុំវិញរូបព្រះជ័យវរ្ម័ន លោកេស្វរៈមានការសាងរូបអទិទេពចំនួន២៨៣អង្គទៀត ក្នុងបណ្តារូបអទិទេពដែលសំខាន់៤អង្គក៏មានរូបព្រះស្រីយសោវរ្ម័នស្វរៈ និងព្រះស្រីត្រីភូវនាវរ្មេស្វរៈ ដែលបានគ្រងរាជមុនព្រះបាទជ័យវរ្ម័នទី៧ជុំវិញប្រាសាទកណ្តាលក្នុងទីលានដែលហ៊ុំព័ទ្ធដោយថែវផ្នែកខាងក្នុងមានការកសាងប្រាសាទតូចៗជាង២០ប្រាសាទ។



www.elibraryofcambodia.org

លោក G.Coedes បុរាណវិទ្យាជនជាតិបារាំងបានហៅថា ប្រាសាទទាំងនេះថាជាស្នូសាននៃគ្រួសារដែលសាងឡើងដើម្បីឧទិសចំពោះអ្នកដែលស្លាប់ទៅហើយ។ សិលាចារឹកបានរៀបរាប់អំពីជង្វាយដែលត្រូវថ្វាយចំពោះអទិទេពក្នុងប្រាសាទព្រះខ័នដែលគេយកមកថ្វាយជារៀងរាល់ថ្ងៃ។ ដែលចាប់ផ្តើមពីព្រះលោកេស្វរៈគ្រឿងជង្វាយទាំងនេះប្រកបដោយ អង្ក លូ សណ្តែក ខ្លាញ់រាវ ទឹកដោជូរ ទឹកដោះរាវ ទឹកឃ្មុំ ទឹកអំពៅ និងខ្លាញ់។ ក្នុងសិលាចារឹកនេះដែរក៏បានរៀបរាប់ផងដែរនូវការថ្វាយសំពត់ដើម្បីតុបតែងរូបបដិមាករដូចគ្នានិងក្នុងចំនួន សំពត់ទាំងនេះក៏មានសត្វរោមសត្វពណិសនិងពណ៌ណក្រហមសំរាប់ជាគ្រឿងតុបតែងអង្គអទិទេព និងសំពត់សូត្រមកពីប្រទេសចិន ដ៏ស្តើងសំរាប់ការពាររុយថ្វាយចំពោះព្រះបាទរបស់លោកេស្វរៈនិងអទិទេពផ្សេងៗទៀត។ ក្រៅពីនេះសិលាចារឹក នៅបានរៀបរាប់អំពីរបស់ទាំងឡាយ ដែលគេប្រគល់អោយមនុស្សនៅថែរក្សាប្រាសាទ របស់ទាំងនោះគឺសំរាប់តែមនុស្សក៏ដូចជាជង្វយថ្វាយចំពោះ ព្រះអទិទេផងដែរ។ ប៉ុន្តែបើពិនិត្យពីគុណភាពវិញមានតំលៃ និងមានសារៈជាងផលនេះគឺដោយសារតែមនុស្សមានចំនួនច្រើនជាងនិងអាចមានចំនួនច្រើនម៉ឺននាក់។



www.elibraryofcambodia.org

### ២.១.៣ ប្រាសាទតាព្រហ្ម (Prasat TaProhm)

ប្រាសាទនេះជា រាជវិហារ ឬជាវត្តរបស់ព្រះពុទ្ធសាសនា ដែលបច្ចុប្បន្នហៅថា តាព្រហ្ម ត្រូវបានកសាងឡើងក្នុងឆ្នាំ១១៨៦ ដើម្បីឧទិសថ្វាយចំពោះព្រះមាតាដែលបានសោយទិវង្គត់ទៅក្រោមរូបភាពរបស់ព្រះនាងប្រាជ្ញាបារមិតា (ទេពធិតានៃសេចក្ដីវៃឆ្លាតក្នុងលទ្ធិព្រះពុទ្ធសាសនាមហាយាន) ដែលព្រះអង្គជាមាតារបស់ព្រះពុទ្ធជាម្ចាស់គ្រប់ព្រះអង្គ។

លក្ខណៈពិសេសរបស់ប្រាសាទតាព្រហ្មបានបង្ហាញអោយដឹងថា សាសនស្ថានកន្លែងនេះជាវត្តព្រះពុទ្ធសាសនា គឺមានប្លង់ដែលប្រកបទៅដោយបន្ទាប់តូចៗធ្វើអំពីថ្មសំរាប់ទីជាស្នាក់អាស្រ័យរបស់ព្រះសង្ឃ។ ប្រាសាទកណ្ដាលត្រូវបានសង្កត់ធ្ងន់ដោយនៅគ្រប់ផ្ទៃខាងក្រៅទាំងអស់និងមានផុកទៅដោយជ័រថ្នាំសំរាប់លាប។ នៅចន្លោះកំពែងជាន់ទី៣និងជាន់ទី៤ (រាប់ពីខាងក្នុងមកខាងក្រៅ) មានទីលានធំមួយដែលមានផ្ទៃដីទំហំប្រមាណ៦០ហិចតា។ ទីនេះទំនងជាទីស្នាក់អាស្រ័យរបស់អ្នកបំរើប្រាសាទដែលតាមសិលាចារឹកបញ្ជាក់ថា មានចំនួនដល់១២៦៤០នាក់។ បន្ទាប់តូច ៗ ដែលធ្វើអំពីថ្មទំនងទុកប្រើសំរាប់ជាទីស្នាក់អាស្រ័យសំរាប់ព្រះសង្ឃដែលមានចំនួនកំណត់ ចំណែកអ្នកបំរើប្រាសាទទំនងជាស្នាក់អាស្រ័យនៅអាគារដែលធ្វើអំពីឈើ។ ក្រៅពីព្រះសង្ឃសំខាន់ចំនួន១៨អង្គ និងក្រុមព្រះសង្ឃចំនួន២៧៤០ នៅមានអ្នកជំនួយការ (សាមណេរ) ចំនួន២២៣២អង្គទៀត ដោយហេតុនេះប្រាសាទតាព្រហ្មទើបប្រៀបដូចជាទីក្រុងតូចមួយ ហើយ



www.elibraryofcambodia.org

ប្រាសាទនេះមានលក្ខណៈសម្បូរណ៍សប្បាយណាស់ ដោយមានការឧបត្ថម្ភពីភូមិចំនួន៣១៤០។

ហើយប្រាសាទនេះផងដែរអ្នកប្រាជ្ញខ្លះចាត់ទុកថា ជាពុទ្ធិកសកលវិទ្យាល័យដំបូងបំផុតនៅអាស៊ីអាគ្នេយ៍។



www.elibraryofcambodia.org

## ២.១.៤ ប្រាសាទនាគព័ន្ធ (Prasat Neak Pean)

សិលាចារឹកប្រាសាទនាគព័ន្ធ បានរៀបរាប់អំពីប្រាសាទជាច្រើនកន្លែង និងមាននៅច្រើនកន្លែងដែលមិនអាចដឹងថានៅកន្លែងណា? ទោះបីជាយ៉ាងណាក៏ដោយមានប្រាសាទមួយដែលអាចដឹងបានដោយងាយគឺ កោះរាជស្រី កោះនេះគឺត្រូវនិងប្រាសាទនាគព័ន្ធនោះឯង។ ដែលតាំងនៅចំកណ្តាលស្រះទឹកបុរាណ គឺជ័យតតាក (**Jayatataka**)។ ដែលចារឹកពោលថា ជាកញ្ចក់ឆ្លុះអោយដឹងនូវជោគលាភ ដែលរំលិចទៅដោយសិលាមាស និងកំរងផ្កាមាសទាំងឡាយ។



www.elibraryofcambodia.org





ប្រាសាទនាគព័ន្ធ                    សេះព្រះពោធិសត្វ

ប្រាសាទនាគព័ន្ធប្រកបដោយតួប្រាសាទ ដែលមានផ្កាឈូកទ្រពីក្រោមនិងតាំងនៅលើគ្រឹះមួយជាន់ទៀត។ មាននាគធ្វើពីថ្មពីរកំពង់រុំជុំវិញគ្រឹះនៃប្រាសាទនេះហើយក៏ដោយសត្វនាគទាំងពីរនេះ ហើយដែលជាដើមហេតុក្នុងការដាក់ឈ្មោះដល់ប្រាសាទនេះដោយស្រះមានទំរង់ជារាងបួនជ្រុងទ្រវែងហើយមានជុំវៅហាក់ដូចជាជ្រៅ ហើយព័ទ្ធជុំវិញដោយថ្មភក់ដំរៀបជាជញ្ជាំងជាកាំថ្នក់ៗ ដើម្បីសំរាប់ងូតទឹក។ គេបានសាងសាលាតូចៗ



www.elibraryofcambodia.org

៤កន្លែងដែលផតចូលទៅក្នុងខឿននៃទិសនីមួយៗ។ សាលាទាំងនេះទទួលទឹកដោយទរធ្លាក់ជារូបក្បាលមនុស្សពីទិសខាងកើតក្បាលសិង្ហ ពីទិសខាងត្បូង ក្បាលសេះពីទិសខាងលិចក្បាលដំរីពីទិសខាងជើង។ ក្រោយពីទឹកហូរឆ្លងកាត់សាលា ទាំងបួនទិសនេះហើយទឹកក៏ធ្លាក់ទៅក្នុងស្រះ៤កន្លែងដែលជីកទេឡើងតាមជ្រុងនីមួយៗនៃស្រះធំ។ នៅឆ្នាំ១៩២៣ លោក L.Finot និង Goloubew. បុរាណវិទូជនជាតិបារាំងបានស្តែងពីទស្សនៈរបស់ខ្លួនថា ប្រាសាទនាគព័ន្ធនេះ គឺរូបចម្លងនៃស្រះអនះវៈត្បតៈ ឬអនោតាត ដែលជាស្រះស័ក្តិសិទ្ធនៃភ្នំហិមាល័យ។ ពីព្រោះស្រះនេះជាកំណើតរបស់ទន្លេ៤ ដែលហូរចេញតាមទិសរៀងៗខ្លួន។

លោក.J.Boisselier. បុរាណវិទូជនជាតិបារាំងបានធ្វើការសិក្សាអំពីប្រាសាទនាគព័ន្ធទៀតក្នុងពេលថ្មីៗ ដោយបានសិក្សាពីសិលាចារិកប្រាសាទព្រះខ័ន។ និងតម្រាផ្សេងៗដែលទាក់ទងនិងស្រះអនវត្បត។ លោកបានបង្ហាញអោយដឹងថា ប្រាសាទនាគព័ន្ធនេះមានភាពសំខាន់ទាក់ទង និងនិមិត្តរបស់ក្រុងអង្គធំនិងការចាប់ផ្តើមនៃទីក្រុងនេះយ៉ាងដូចម្តេច?។ តាមតម្រាឥណ្ឌាបានបញ្ជាក់ថា ទឹករបស់ស្រះអនវត្បតៈនេះមានលក្ខណៈបរិសុទ្ធជានិច្ច។ ទាំងនេះព្រោះមិនបានទទួលពន្លឺដោយត្រង់ពីព្រះអាទិត្យ តែជាពន្លឺដែលចាំងចូលទៅត្រូវបាំងជះត្រឡប់មកវិញ។

សិលាចារឹកប្រាសាទព្រះខ័នបានអោយដឹងថា ទឹករបស់ស្រះប្រាសាទនាគព័ន្ធបានទទួលរស្មីពីរស្មីនៃប្រាសាទមាស។ ដូចនេះវាមិនមែនរស្មី



www.elibraryofcambodia.org

ដែលចាំងមកដោយត្រង់ពីព្រះអាទិត្យនោះទេ។ ក្នុងត្រៃភូមិរបស់ព្រះពុទ្ធសាសនា ស្រះអនវតប្តជាស្រះចុងក្រោយដែលនិងរីងស្ងួតពេលដល់ចុងនៃកល្ប។ ដោយហេតុនេះ អាណាចក្រដែលមានស្រះនេះនិងគង់វង្សបានយូរអង្វែងស្មើរនិងលោកនេះ។

ក្រៅពីនេះទឹកស្រះនេះនៅមានភាពស័ក្តសិទ្ធទៀតផង ពេលដល់វេលាធ្វើពិធីរាជាភិសេកត្រូវមានការស្រង់ព្រះរាជាដោយយក ទឹកពីស្រះអនវតប្តនេះ។ លោក**J.Boisseleir**បានពោលថា ការកសាងស្រះនេះមានផលពីយ៉ាងសំរាប់អាណាចក្រខ្មែរ គឺធ្វើអោយអាណាចក្រខ្មែរមានអាយុយូរអង្វែងក្នុងពេលជាមួយគ្នានេះដែរ ព្រះរាជាខ្មែរនិងមានអំណាចយ៉ាងទូលំទូលាយជាងនេទៀត។

ក្នុងស្រះដែលព័ទ្ធជុំវិញប្រាសាទកណ្តាល គេបានរកឃើញស្នាកស្នាមនៃបដិមាកររអណ្តែតខ្លួន៤អង្គ ទិសខាងត្បូងគេបានរកឃើញកំទេចសិលាដែលមិនអាចដឹងបានថាជារូបអ្វីពិតប្រាកដ។ ទិសខាងលិចគេបានរកឃើញកំទេចរូបព្រះនារាយណ៍ផ្ទុំទិសខាងជើងជារូបសិវលិង្គ ទិសខាងកើតអាចប្រកបជារូបសេះបះលះហៈ (Balaha) ដែលល្អជាងគេ។ សេះដ៏វិសេសនេះជារូបចំលងរបស់ព្រះព្រាធិសត្វអវលោកេស្វរៈដើម្បីជួយសង្គ្រោះដល់អ្នកលង់ទឹកទាំងឡាយ ដែលកំពុងអាស្រ័យនៅកោះមួយដែលពោរពេញពួកយក្ស។ ហើយមុនពេលពួកយក្សលេបពួកគេ ពួកដែលលង់ទឹកទាំងអស់ក៏បានសូត្រមន្ត បួងសួងសុំការជួយសង្គ្រោះពីព្រះពោធិសត្វ អ្នក



www.elibraryofcambodia.org

ទ្រទ្រង់ដោយសេចក្តីមហាករុណាអង្គនេះ។

គេមិនប្លែកចិត្តទេពេលឃើញរូបសេះនេះកំពុងចំលងមនុស្សលង់ទឹកហោះទៅកាន់ប្រាសាទកណ្តាល ដែលមានរូបព្រះពោធិសត្វលោកេស្វរៈគង់នៅព្រមទាំងនាំពួកលង់ទឹកកំពុងតោងនៅខាងៗសេះ។ តែគេប្លែកចិត្តដែលបានរកឃើញរូបបដិមាករក្នុងសាសនាព្រាហ្មណ៍២អង្គក្នុងស្រះនេះ។ សិលាចារឹកប្រាសាទព្រះខ័នបានអោយដឹងថា ព្រះបាទជ័យវរ្ម័នទី៧ទ្រង់បានប្រតិស្ឋានទេវរូប១៤អង្គ ក្នុងជ័យស្រី ដែលមានសិវលិង្គចំនួន ១000អង្គ។

លោក.P.Mus.បុរាណវិទូជនជាតិបារាំងបានបង្ហាញពីទស្សនៈទាក់ទងនិងរឿងនេះថា ជាសមត្ថរដែលនិងរួបរួមពិធីបូជា ដែលធ្លាប់ផ្សំគ្នាអំណាចនៃអាណាចក្រខ្មែរមកតាំងតែចាប់ផ្តើមរបបក្សត្រសម័យអង្គរ ហើយក្រោយមកបានដួលរលំដោយការឈ្លានពានដោយកងទ័ពចាម និងកាន់កាប់ក្រុងអង្គរក្នុងឆ្នាំ១១៧៧ មកទុកជុំវិញព្រះពុទ្ធជាម្ចាស់។

លោក.J.Boisselier គិតថា ជាការសមត្ថរដែលសើរើការគោរពបូជារបៀបចាស់ៗមកជារបៀបថ្មី លោកយល់ថា ការមានអទិទេពក្នុងសាសនាព្រហ្មណ៍នៅជុំវិញព្រះពុទ្ធរូបនោះជាការធ្វើស្រះមានភាពស័ក្តសិទ្ធពេញទី។ និង ធ្វើអោយស្រះនេះជាទីកន្លែងខ្ពង់ខ្ពស់ ធ្វើអោយនិមិត្តរូបនៃស្រះអនះវៈត្បតៈមានភាពគង់វង់ឡើងថែមទៀត ព្រោះហេតុថា នៅពេលក្លាយជាទីស្ថិតនៃអទិទេពផងស្រះនេះនឹងរួចផុតពីបំផ្លាញលោក។



www.elibraryofcambodia.org

## ២.១.៥ ប្រាសាទបាយ័ន (Prasat Bayon)




ប្រាសាទបាយ័ន ជាសាសនស្ថានកណ្តាលរាជធានីអង្គរធំ ដោយមានកំពូលប្រាសាទចំនួន ៥៤កំពូលឆ្លាក់ជារូបមុខធំមហិមានៅទាំង៤ទិស ដោយបង្ហាញអំពីព្រះរាជអំណាចរបស់ ព្រះរាជា ដែលប្រាកដមាននៅគ្រប់ទិសទី។

អ្នករៀបរៀងសន្និដ្ឋានថា «រូបមុខនេះជាព្រះភក្ត្ររបស់ព្រះបាទជ័យវរ្ម័នទី៧ព្រោះតាមឈ្មោះរបស់ប្រាសាទដែល បា ប្រែ ឪពុក យ័ន ប្រែថា មើល ឬ សម្លឹងមើល។

សរុបមកអាចប្រែបានថា ព្រះអង្គកំពុងទតមើលអាណាប្រជារាស្ត្ររបស់ព្រះអង្គនៅគ្រប់ទិសទីដោយសេចក្តីមេត្តា និងសេចក្តីទុក្ខព្រួយ»

សាសនស្ថានកណ្តាករាជធានីអង្គរធំ គឺប្រាសាទបាយ័នទំរង់ប្លង់ នៃប្រាសាទនេះមានលក្ខណៈចំឡែក គឺគ្មានកំពែងព័ទ្ធជុំវិញ តែយកកំពែងរាជ



www.elibraryofcambodia.org

ធានីអង្គរធំជាកំពែងព័ទ្ធជុំវិញ ដោយហេតុនេះប្រាសាទបាយ័នទើបតាំងនៅក្នុងអាណាខេត្តដែលស័ក្តិសិទ្ធ។

ប្រាសាទបាយ័នប្រកបទៅដោយបន្ទប់ដែលព័ទ្ធជុំវិញដោយថែវនិងព្រះវិហារចំនួន១៦ទៀតដែលមានទ្វារចេញទៅខាងក្រៅ។ ទំរង់ប្លង់ដ៏ចំលែកជារាងមូល ដូច្នេះទំនងជានិមិត្តសញ្ញានៃ**យ័ន**គឺអាណាខេត្តដ៏ស័ក្តសិទ្ធ។ ប្រាសាទផ្សេងៗទៀតតាំងនៅជាជួរពទ្ធ័ជុំវិញ ប្រាសាទកណ្តាលដែលខ្ពស់ត្រដែត។




ថែវផ្នែកខាងក្រៅ ឆ្លាក់ជារូបក្បួនកងទ័ពដ៏ខ្លាំងក្លារបស់ព្រះបាទជ័យវរ្ម័នទី ៧



www.elibraryofcambodia.org

## អាថ៌កំបាំងនៃប្រាសាទបាយ័ន

ប្រាសាទបាយ័នក្នុងរាជធានីអង្គរធំ ជាបុរាណស្ថានដែលគួរអោយងឿងឆ្ងល់និងបង្កអោយកើតបញ្ហា ដែលអ្នកបុរាណវិទូឆ្លើយទៅនឹងភាពអាថ៌កំបាំងនៃប្រាសាទនេះទៅក្នុងលក្ខណៈខុសៗគ្នា និងពេលខ្លះក៏មានការខ្វែងគំនិតគ្នាអំពីរឿងនេះ។

ប្រាសាទបាយ័នមានលក្ខណៈដែលមានអាថ៌កំបាំងជាច្រើនប្រការ។ ទំរង់ប្លង់ដែលសាំញាំជាលទ្ធផលពីផ្លាស់ប្តូរទំរង់ប្លង់មកជាលំដាប់មានទីលានចង្អៀតៗដែលជ្រៅស្មើរនឹងអណ្តូង។ ថែវមានភាពងងឹតដើមថ្មធំមហិមាដែលប្រើក្នុងការសាងសង់ ដែលមានកំលាំងគួរអោយខ្លាច រូបចំលាក់ខ្ពស់ទាបដែលមានចំណែកដែលនៅទាន់អធិប្បាយបាន។ ប្រាសាទនេះឆ្លាក់ជារូបមុខមនុស្សជាច្រើន ដែលជាស្ថាបត្យកម្មមិនដូចស្ថាបត្យកម្មសម័យណាៗទាំងអស់។ គ្រប់គ្នាដែលឃើញប្រាសាទបាយ័ននិងត្រូវទ្រឹងគិតដោយភាពងឿងឆ្ងល់។

លោក Delaporte យល់ថា ប្រាសាទបាយ័នជាសំណង់កសាងដូចរឿងនិទាន... ជាសំណល់បុរាណស្ថានដែលចំឡែកបំផុតក្នុងបណ្តាបុរាណស្ថានខ្មែរទាំងអស់។

លោក .Tissansier យល់ថា ជាសំណង់កសាងដែលមានលក្ខណៈចំពោះបំផុតនិងប្រណិតបំផុត។



www.elibraryofcambodia.org

លោកBiEGelaTI. មានចំណាប់អារម្មណ៍ចំពោះប្រាសាទនេះ ដោយស្ងើចសរសើរថា «ពេលខ្ញុំងើបមើលទៅកាន់ប្រាសាទដែលគ្របដណ្តប់ដោយដើមឈើពេលនោះធ្វើអោយខ្លួនខ្ញុំមានអារម្មណ៍ថា ដូចជាមនុស្សខ្សោះឈាមនិងភ្លាមៗនោះឈាមក្នុងខ្លួនខ្ញុំចាប់ផ្តើមរឹងត្រជាក់ឡើង ពេលមើលឃើញស្នាមញញឹមទំហំធំមហិមាដែលកំពុងសំលឹងមើលមកខ្ញុំ ហើយស្នាមញញឹមមួយផ្នែកទៀតនៅលើកំពែងមួយផ្នែកទៀត ហើយស្នាកញញឹមផ្នែកទី៣ហើយក៏ទី៥ ហើយក៏ទី១០... ផុសចេញពីគ្រប់ទិសទី។ រូបខ្ញុំមានអារម្មណ៍ថា ដូចមានភ្នែករង់ចាំសម្លឹងមកខ្ញុំគ្រប់ទិសទី»។

ដោយប្រាសាទបាយ័នមានលក្ខណៈអាថ៌កំបាំងជាច្រើនប្រការដូច្នេះក្នុងបញ្ហានេះអ្នករៀបរៀងនិងលើកយកចំពោះរឿងដែលទាក់ទងទៅនឹងរូបមុខនៅលើកំពូលនៃប្រាសាទនេះមកបកស្រាយតែប៉ុណ្ណោះ÷



www.elibraryofcambodia.org




កំពូលប្រាសាទបាយ័នឆ្លាក់ជារូបមុខនៅទិសទាំង៤បង្ហាញពីរាជអំណាចរបស់ព្រះមហាក្សត្រ

រូបមុខជាច្រើនដែលតុបតែងកំពូលប្រាង្គប្រាសាទ ជាវត្ថុដែលទាក់ទាញអារម្មណ៍អ្នកដែលបានមកឃើញ ហើយរូបមុខនេះហើយដែលធ្វើអោយអ្នកប្រាជ្ញចំណាយទឹកបាកាសរសេរអំពីអត្ថន័យអំពីរឿងរូបមុននេះ ដោយគំនិតដំបូងជឿថា រូបមុននេះជាដំណាងអោយព្រះភ័ក្ត្ររបស់ ព្រះព្រហ្ម។ ដែលជាទូទៅរំមែងនិយមឆ្លាក់ជាព្រះភ័ក្ត្រ៤ ទ្រឹស្តីនេះពិចារណាមើលគឺមានលក្ខណៈស្របគ្នានិងប្រពៃណីរឿងព្រេងនិទាន។ ដោយសារតែយើងបានរកឃើញរូបមុខ៤នៅលើក្លោងទ្វារប្រាសាទតាព្រហ្មគឺ «តាព្រហ្មចាស់ជរា» ដោយជំនឿត្រូវបានទទួលស្គាល់ជាទូៗទៅរហូតដល់ឆ្នាំ១៩០២ លុះដល់ឆ្នាំ១៩១១ ទ្រឹស្តីនេះត្រូវបានលុបចោលនៅពេលដែលបានរកឃើញរូបព្រះពោធិសត្វលោកេស្វរៈនៅហោជាងនប្រាសាទ ដែលភស្តុតាងនេះបង្ហាញថា លក្ខណៈដើមនៃប្រាសាទបាយ័នជាពុទ្ធសាសនស្ថាន។ រូបមុខ



www.elibraryofcambodia.org

ដូចពោលខាងលើទំនងជាព្រះភក្ត្ររបស់ព្រះពោធិសត្វដែលទ្រទ្រង់ដោយសេចក្តីមេត្តាករុណា។

លោក ElakLouisFinot ក៏មានទស្សនៈដូចពោលខាងលើ ពួមកនេះក្នុងឆ្នាំ១៩១១ ដោយសារតែគាត់គិតដល់ប្រាសាទរបស់នគរ ពួចាមកន្លែងខ្លះជាពិសេសនៅពោនគរ (Po Nagar) ក្នុងក្រុង ញាត្រាំង (Nha Trang) ដែលមានក្បាច់ចំលាក់ជារូបមុខមនុស្សជាច្រើនផងដែរ។ តាមរយៈក្បាច់ចំលាក់នេះទើបធ្វើអោយ គាត់តាំងទ្រឹស្តីថា ប្រាង្គប្រាសាទបាយ័ន មានទំរង់ជាលក្ខណៈនៃភេទប្រុសគឺលិង្គទំហំធំដែលឆ្លាក់ជារូបមុខមនុស្សជាច្រើនដើម្បីប្រមូលវត្ថុគោរពបូជាទុកក្នុងព្រះវិហារ។ ទ្រឹស្តីនេះទើបមានមូលដ្ឋានដោយមានជំនឿថា ប្រាសាទបាយ័នជាសាសនស្ថានក្នុងឥណ្ឌូដែលសង់ឡើងដើម្បីឧទិសថ្វាយចំពោះព្រះសិវៈ។

តែយ៉ាងណាក៏ដោយទ្រឹស្តីនេះត្រូវបានលុបចោលទៅវិញនៅពេលគេបានរកឃើញរូបព្រះពោធិសត្វលោកេស្វៈនៅបរិវេណហោជាង។ ភស្តុតាងនេះបញ្ជាក់អោយយើងដឹងថា លក្ខណៈទំរង់ប្រាសាទបាយ័នជាពុទ្ធស្ថាន និងរូបមុខទាំងនេះជាព្រះភត្ត្ររបស់ព្រះពោធិសត្វ។ សូម្បីតែអ្នកបុរាណវិទូនៃវិទ្យាស្ថានបារាំងបូពា៌ ក៏មិនអាចកាត់សេចក្តីបានភ្លាមៗថា រូបមុខលើប្រាសាទបាយ័នជាព្រះភ័ក្ត្រ ព្រះព្រហ្ម ព្រះសិវៈ ឬព្រះភ័ក្ត្រព្រះពុទ្ធជាម្ចាស់អង្គណាមួយពិតប្រាកដ។



www.elibraryofcambodia.org

លក្ខណៈដែលខុសគ្នាដែលប្រាកដអោយឃើញយ៉ាងច្បាស់ក្នុងបណ្ដាទេវរូបនៃភ្នំអូលិមបស្ស និងមិនសូវឃើញបានក្នុងសាសនានៃឥណ្ឌា ព្រះព្រហ្ម ជាអ្នកសាងលោក ព្រះសិវៈ ជាអ្នកទ្រទ្រង់ដោយមេត្តានៅគ្រប់ទិសទីព្រះពុទ្ធជាម្ចាស់ក្នុងទំរង់មហាបាដិហារយ៍ ដែលប្រាកដព្រះអង្គមានចំនួនរាប់មិនអស់ និងព្រះពោធិសត្វលោកេស្វរៈទតព្រះភក្ត្រទៅគ្រប់ទិសទី។ វិញ្ញាណដែលនៅពីក្រោយព្រះអទិទេពផ្សេងៗរបស់ឥណ្ឌា ដែលស្ថាបនិកព្យាយាមអោយឃើញដោយមិនបានចេញមកក្នុងឋានៈវត្ថុ ដែលមិនបច្ចេកបុគ្គលតែចេញមកក្នុងផ្នែកនាមធម៌ច្រើនជាង។

លោក Biegrelati បានចាប់ទស្សនៈបានដោយគំនិតរបស់កវី ដែលគួរអោយសង្កេតនិងសរសេរចំណាប់អារម្មណ៍បានយ៉ាងចាប់អារម្មណ៍ថា «ពីលើផ្ទៃមុខទាំង៤នៃប្រាង្គនីមួយៗបែរមុខទៅទិសទៅទិសទាំង៤សម្លឹងមើលទៅគ្រប់ទិសដោយកាត់តាមគ្របកភ្នែក មុខនីមួយៗមានអារម្មណ៍នឹកគិតដ៏អាថ៌កំបាំង សំដែងដោយសេចក្ដីមេត្តាបង្កប់ដោយអត្ថន័យដោយស្នាមញញឹមដូចៗគ្នាប្រាកដនៅគ្រប់ទិសទីនៃព្រះអទិទេពរាជធានីអង្គរធំ»។

យើងដឹងរួចហើយថា ព្រះអទិទេពរាជធានីអង្គរធំ គឺព្រះមហាក្សត្រទេវរាជា ជាអ្នកបានធ្វើពិធីជាព្រះអទិទេពតាំងតែមុន គ្រីស្តសករាជទី១២ តាមរយៈសិវលឹង្គមាស និងក្នុងសម័យព្រះបាទជ័យវរ្ម័ន៧ ព្រះអង្គមានឋានៈព្រះអង្គស្មើនិងព្រះពុទ្ធជាម្ចាស់។

តាមរយៈការស្រាវជ្រាវគេបានរកឃើញរូបចំលាក់ពីក្រោមបន្ទប់បិទ



www.elibraryofcambodia.org

ក្រោមប្រាសាទកណ្ដាល។ តាមរយៈការស្រាវជ្រាវនេះជាភស្តុតាង ដោយមិនបាច់សង្ស័យដល់ការសង្កេតរបស់សញ្ញាតញ្ញាណរបស់លោកលោទី ដែលពិសោធន៍ថា គំនិតគិតដែលជានាមធម៌គឺជាបញ្ហា ដែលជាការតាំងចិត្តរបស់បដិមាកម្មសម័យបាយ័នដែលបង្ហាញដល់ «ព្រះរាជអំណាចដែលផ្សព្វផ្សាយទៅទិសទាំង៤»។ ព្រះព្រហ្មព្រះសិរៈ ឬព្រះលោកេស្វរៈ ក៏ទ្រង់មានគុណលក្ខណៈដែលអាចផ្ទេរគំនិតដែលជានាមធម៌បានល្អដូចគ្នា តែដែលយើងទុកចិត្តថាជាព្រះលោកេស្វរៈ ក៏ព្រោះដែលផ្ទៃកផ្សេងៗរបស់ប្រាសាទបាយ័នមានលក្ខណៈដែលបង្ហាញពីពុទ្ធស្ថានយ៉ាងច្បាស់លាស់។

ពេលនេះយើងមកដល់បញ្ហាដែលថា លទ្ធិអ្វីដែលប្រតិបត្តិនៅក្នុងសាសនស្ថានកន្លែងនេះ។ រូបព្រះពោធិសត្វលោកេស្វរៈនៅត្រង់ហោជាងដែលពិសោធន៍រួចហើយថាដើមឡើយប្រាសាទបាយ័នមិនមែនសាសនស្ថានដែលប្រតិដ្ឋានសិវៈលឹង្គដូចដែលបានគិតដូច ពីមុនតែជាពុទ្ធសាសស្ថានឧទិសចំពោះព្រះពោធិសត្វលោកេស្វរៈ។

ផ្ទៃមុខដែលបន្ថែមចំនួនដ៏ច្រើនដែលបែរមុខទៅទិសទាំង៤ជានិមិត្តរូបដែលគំនិតដែលគិតថា ព្រះរាជអំណាចរបស់ព្រះមហាក្សត្រទ្រង់ផ្សព្វផ្សាយព្រះមហាករុណាធិគុណទៅទាំងចតុទិសរបស់រាជាអាណាចក្រ។ ចំណែកការឆ្លាក់ព្រះភក្ត្រដដែលៗលើកំពូលប្រាង្គគ្រប់អង្គនោះ។ លោក blmus បានអធិប្បាយថា «គាត់ជឿថា បណ្ដារូបគោរពបូជាក្នុងវិហារក្នុងប្រាង្គបើមិនមែនរូបចំលាក់នាហ្មឺនឬមន្ត្រីជាន់ខ្ពស់ ដែលបានឆ្លងកាត់ធ្វើពីធីកម្ម



www.elibraryofcambodia.org

អោយក្លាយជាព្រះអទិទេពរួចហើយទំនងជារបស់ព្រះអទិទេពប្រចាំស្រុក»

ពេលខ្លះប្រាង្គអង្គនីមួយៗអាចត្រូវនិងអាណាខេត្តនីមួយៗ របស់អាណាចក្រឬយ៉ាងហោយណាស់ ក៏ត្រូវនិងអំណាចកណ្តាល ឬអំណាចការគ្រប់គ្រងខាងសាសនាអាណាខេត្តណាមួយ។ ដូចនេះបើរូបមុខទាំង៤ទិសជានិមិត្តរូបរបស់ព្រះរាជអំណាចដែលផ្សព្វផ្សាយទៅគ្រប់ទិសទី រូបមុខទាំងអស់ដែលប្រាកដមាននៅលើប្រាង្គដែល ជាតួតំណាងអោយអាណាខេត្តនីមួយៗ រមែងមានអត្ថន័យដល់ព្រះរាជអំណាចរបស់ព្រះបាទជ័យវរ្ម័នទី៧ថា ព្រះអង្គមានរឹងមាំ និងផ្សព្វផ្សាយទៅតាមអាណាខេត្តដូចគ្នាព្រះរាជអំណាចដែលប្រាកដក្នុងរាជធានីអង្គរធំនោះផងដែរ។

ដូចនេះយើងអាចសរុបបានថាកំពូលប្រាង្គ ដែលមានព្រះភក្ត្រ៤នោះ ជានិមិត្តរូបដំណាងអោយអាណាខេត្តក្នុងរាជអាណាចក្រខ្មែរ។ ពេលនោះយើងល្មមយល់អំពីស្ថាបត្យកម្មដ៏អាថ៌កំបាំងនេះបានថា ជានិមិត្តរូបភាពអច្ឆរិយរបស់ព្រះបាទជ័យវរ្ម័នទី៧នោះឯង។ សំណង់និងការកសាងនេះប្រៀបដូចនិមិត្តរូបដំណាងអោយការគ្រប់គ្រង និងអំណាចខាងសាសនាដែលរីកក្លាយទៅគ្រប់ច្រកល្ហកក្នុងអាណាចក្រខ្មែរ ដោយអាស្រ័យនិមិត្តរូបដ៏ចំលែកមិនដូចស្ថាបត្យកម្មខ្មែរនាសម័យមុនជាដំណាងបង្ហាញចេញមក។ ចំណែករូបមុខនៅលើប្រាង្គប្រាសាទបាយ័ន ជាព្រះភក្ត្ររបស់ជ័យវរ្ម័នទី៧ដែលព្រះអង្គកំពុងទត មើលរកអាណាប្រជានុរាស្ត្ររបស់ព្រះអង្គនៅគ្រប់ទិសទីដោយសេចក្តីមេត្តា និងសេចក្តីទុក្ខព្រួយ។



www.elibraryofcambodia.org

## ២.១.៦ ប្រាសាទបន្ទាយក្ដី (Banteay Kdei) ...

ប្រាសាទបន្ទាយក្ដីមានលក្ខណៈស្រដៀងគ្នានឹងទំរង់ប្រាសាទតាព្រហ្ម និងប្រាសាទព្រះខ័នតែមានទំហំតូចជាង។ គោបុរៈទាំង៤ (ក្លោងទ្វារ) មានព្រះភ័ក្ត្រព្រះពោធិសត្វលោកេស្វរៈបែរព្រះភ័ក្ត្រទៅទិសទាំង៤ដូចគ្នានឹងប្រាសាទបាយ័ន ដោយមានកំពែងព័ទ្ធជុំវិញផ្លូវចូលប្រកបដោយក្លោងទ្វារ៤ ដោយមានទំហំ៨០០X៤០០មែត្រ។ ប្រាសាទបន្ទាយក្ដីចាត់ទុកជាវត្តខាងព្រះសាសនាដ៏សំខាន់មួយតែសព្វថ្ងៃមានសភាពទ្រុឌទ្រោមអស់ទៅហើយ។



ប្រាសាទបន្ទាយក្ដី



www.elibraryofcambodia.org

## ២.១.៧ ប្រាសាទបន្ទាយឆ្មារ (Prasat Banteay Chhmar)



ប្រាសាទបន្ទាយឆ្មារ ដោតតួប្រាសាទតាំងជំរៀបគ្នាពីកើតទៅលិច

បាសាទបន្ទាយឆ្មារជាពុទ្ធស្ថាននិកាយមហាយានដ៏ប្រណិតមួយដែលបានសាងឡើងក្នុងរាជកាលព្រះបាទជ័យវរ្ម័នទី៧ បច្ចុប្បន្នប្រាសាទនេះតាំងនៅក្នុងខេត្តបន្ទាយមានជ័យដោយប្រមាណ៦៣គមភាគខាងជើងទីរួមខេត្ត។ ប្រាសាទបន្ទាយឆ្មារមានកំពែងបុរាណ (Ancient Wall) ព័ទ្ធជុំវិញទំហំ ៣.៥x២.៥គម.។ ផ្នែកខាងក្រៅព័ទ្ធជុំវិញដោយគូទឹកប្រមាណ ១x១គម ប្រាសាទមានទំហំប្រមាណ២៥០x២៥០ម ដោយផ្នែកខាងក្រៅព័ទ្ធជុំវិញដោយថែវមានឆ្លាក់ជារូបចំលាក់ជាច្រើន។ បន្ទាប់មកជាកំពែងដែលមានឆ្លាក់ជារូបចំលាក់ដ៏វិចិត្រ។ ផ្នែកខាងក្នុងជាថែវ គោបុរៈ ព្រះវិហារទីលានសំរាប់ធ្វើពិធីកម្មខាងសាសនា និងកុដិព្រះសង្ឃ។

ក្លោងទ្វារប្រាសាទមេរុទិសកំពែងរបស់ថែវមុខភ្ជាប់អង្គប្រាសាទដែលមានការកេះឆ្លាក់រូបនាងអប្សរា និងក្បាច់ចំលាក់ដ៏វិចិត្រមានលក្ខណៈសាំ



www.elibraryofcambodia.org

ញាំ ក្រុមប្រាសាទតាំងតជាប់គ្នាពីទិសខាងកើតទៅទិសខាងលិច ចំណែកមណ្ឌលកណ្ដាលជាក្រុមប្រាសាទប្រធាន ដូចជារូបព្រះពុទ្ធ និងក្រុមព្រះពោធិសត្វដែលមានកំពូលប្រាសាទបែបសិខរៈ និងប្រាសាទដែលឆ្លាក់ជារូបព្រះពោធិសត្វលោកេស្វរៈមានព្រះភ័ក្ត្រ៤លក្ខណៈដូចគ្នានិងប្រាសាទយ័នផងដែរ។

រូបចំលាក់និទានតាមថែវរបស់ប្រាសាទបន្ទាយឆ្មារ ជាការកត់ត្រាប្រវត្តិសាស្ត្របុគ្គលសំខាន់ដែលទាក់ទងនិងព្រះបាទជ័យវរ្ម័នទី៧ យ៉ាងហោចណាស់៣នាក់គឺ ÷

១.អ្នកអង្គម្ចាស់ស្រីស្រិន្ទ្រកុមារ ដោយយើងមានហេតុផលដែលគួរអោយជឿថា ព្រះអង្គជាព្រះឱរសរបស់ព្រះបាទយសោវរ្ម័នទី២។ ដោយមានរូបចំលាក់និទានរឿងព្រះអង្គរួមធ្វើសង្គ្រាមជាមួយនិងព្រះបាទជ័យវរ្ម័នទី៧ក្នុងការកំចាត់គំកងទ័ពចាម។ និងរូបចំលាក់និទានរឿងព្រះអង្គទ្រង់បានតស៊ូនិងពួករាហូដើម្បីការពារមិនអោយពួកក្បត់ដណ្ដើមអំណាចព្រះបាទយសោវរ្ម័នទី២។ សិលាចារឹកប្រាសាទបន្ទាយឆ្មារបានកត់ត្រាពីវីរភាពរបស់ព្រះអង្គ និងសេនារបស់ព្រះអង្គចំនួន៤នាក់ទៀត ដែលហ៊ានពលីជីវិតដើម្បីការពារព្រះអង្គ។ ពេលពលីជីវិតទៅ សេនាទាំង៤នាក់ត្រូវបានទទួលការស្ថាបនាជាព្រះអទិទេព ដោយសាងរូបគោរពប្រតិស្ឋាននៅទិសទាំង៤នៃប្រាសាទប្រធានដើម្បីការពាររូបគោរពកម្ឋរតេងជតស្រីស្រិន្ទ្រទេវ។ ប្រាសាទនេះទើបសង់ឡើងជាកន្លែងបញ្ចុះព្រះសពរបស់ព្រះអង្គ។



www.elibraryofcambodia.org

២.អ្នកអង្គម្ចាស់វិទ្យានន្ទៈ របស់អាណាចក្រចម្ប៉ាដែលចូលមកចុះ

ចូលនិងព្រះបាទជ័យវរ្ម័នទី៧។ ក្នុងប្រាសាទបន្ទាយឆ្មារក៏ឆ្លាក់រូបព្រះអង្គកំ-ពុងបង្ក្រាបពួកក្បត់ក្នុងដំបន់ម៉ងយាំង ហើយក៏បានយកក្បាលអ្នកក្បត់ មកថ្វាយព្រះបាទជ័យវរ្ម័នទី៧។ ធ្វើអោយអ្នកអង្គម្ចាស់ចាមអង្គនេះ ជាទីសណ្តោះប្រោសប្រណីរបស់ព្រះបាទជ័យវរ្ម័នទី៧។ ព្រមទាំងនៅមានរូបចំលាក់របស់អ្នកអង្គម្ចាស់កំពុងដឹកនាំកងទ័ពខ្មែរទៅច្បាំងនិងព្រះបាទជ័យ-ឥន្ទ្រវរ្ម័នទី៤នៃអាណាចក្រចម្ប៉ារហូតដណ្តើមរាជធានីរបស់អាណាចក្រចាមបាន។ ទោះបីអ្នកអង្គម្ចាស់អង្គនេះបានក្បត់និងព្រះបាទជ័យវរ្ម័នទី ៧ ដោយប្រកាសឯករាជ្យពីអាណាចក្រខ្មែរ តែព្រះបាទជ័យវរ្ម័នទី៧ ក៏អាចដំណើរការខាងនយោបាយកំចាត់អ្នកអង្គម្ចាស់នេះបានសំរេចធ្វើ អោយអា-ណាចក្រចាមត្រូវធ្លាក់ជាអាណាខេត្តមួយរបស់អាណាចក្រខ្មែរ។

**៣.ព្រះនាងរាជេន្ទ្រទេវី** តាមរយៈសិលាចារឹកធ្វើអោយយើងដឹងថាព្រះបាទជ័យវរ្ម័នទី៧ មានព្រះរាជអគ្គមហេសីសំខាន់ពីរព្រះអង្គ គឺព្រះនាងជ័យរាជទេវី និងព្រះនាងឥន្ទ្រទេវី។ តែចុងក្រោយសិលាចារឹកប្រាសាទព្រះខ័នកត់ត្រាថា “ព្រះឱរសរបស់ព្រះនាងរាជេន្ទ្រទេវី ព្រះមហេសីសំខាន់របស់ព្រះបាទស្រីជ័យវរ្ម័ន (ព្រះបាទជ័យវរ្ម័នទី៧) ជាព្រះរាជបុត្រដ៏ឆ្នើមបំផុតមួយព្រះអង្គក្នុងចំណោមអ្នកដែលបានទទួលការសិក្សាអប់រំមកល្អ ជាកំពូលអ្នកចំបាំង ជាអ្នកឈ្នះសេចក្តីស្រលាញ់នៃសម្រស់របស់ព្រះអង្គ ជាទីគោរពសរសើរក្នុងបណ្តាអ្នកសិក្សាសិល្បៈផ្សេងៗ ជាអ្នកប្រព្រឹត្តិតាមធម្មល្អ



www.elibraryofcambodia.org

បំផុត»។ អ្នកអង្គម្ចាស់អង្គនេះទ្រង់ព្រះនាមថា ស្រីវីរកុមារ» ខ្លឹមសារក្នុងសិលាចារឹកនេះធ្វើអោយយើងជឿថា ព្រះនាងរាជេន្ទ្រទេវី ជាព្រះមហេសីរបស់ព្រះបាទជ័យវរ្ម័នទី៧ តែយើងអាចមិនដឹងរឿងរបស់ព្រះអង្គច្រើនជាងនេះនោះទេ។

ក្នុងប្រាសាទបន្ទាយឆ្មារ មានរូបចំលាក់ក្បួនកងទ័ពរបស់នាយទាហានពីររូបភាព មាននាហ្មឺនជាន់ខ្ពស់៣នាក់ ទើបជារឿងដែលគួរអោយជឿថា ព្រះបាទជ័យវរ្ម័នទី៧ មានព្រះមហេសី៣អង្គគឺក្រៅពីព្រះនាងជ័យរាជទេវីនិងព្រះនាងឥន្ទ្រទេវី។ ព្រះមហេសីមួយអង្គទៀតទំនងជាព្រះនាងរាជេន្ទ្រទេវី។ សិលាចារឹកប្រាសាទបន្ទាយឆ្មារបានសរសើរ ថា “ព្រះនាងទ្រង់មានបញ្ញា ជាកំពូលអ្នកចំបាំងនិងមានសម្រស់ដ៏ល្អផូផង់»។ ដូចនេះយើងសង្កេតឃើញថា ព្រះនាងរេជេន្ទ្រទេវីទំនងមានតួនាទីសំខាន់ក្នុងរាជសំណាក់ ដែលធ្វើអោយយើងដឹងពីតួនាទីស្រីក្នុងរាជសំណាក់ ដែលមិនធ្លាប់ប្រាកដមានក្នុងរាជសំណាក់ខ្មែរពីមុនមក។ យើងឃើញថា ព្រះបាទជ័យវរ្ម័នទី៧ មានព្រះមហេសីសុទ្ធសឹងដែលពោរពេញទៅដោយសមត្ថភាព ទើបធ្វើព្រះអង្គអាចដឹកនាំប្រទេសឆ្ពោះទៅរកភាពរីកចំរើនរុងរឿងបំផុតក្នុងប្រវត្តិសាស្ត្រខ្មែរ។ **រូបព្រះពោធិសត្វប្លែងរស្មី** ចំនុចលិចធ្លោមួយទៀតរបស់ប្រាសាទបន្ទាយឆ្មារ គឺរូបភាពព្រះពោធិសត្វលោកេស្វរៈប្លែងរស្មី។ ពីដើមមានទាំងអស់៨រូបភាព តែបច្ចុប្បន្ននៅសល់តែ២រូបភាពប៉ុណ្ណោះ។ រូបភាពទីមួយតាំងនៅផ្នែកខាងលើទ្វារឃ្លាប និងទ្វារថែវ



www.elibraryofcambodia.org

ទិសខាងលិច និងរូបភាពទីពីរតាំងនៅទិសខាងត្បូង។

រូបភាពទី១ ព្រះពោធិសត្វស្តេចនិមន្តទៅទេសនាគោលធម្មនៃនិពាន្ត ប្រោសសត្វក្នុងនរកអវចី។

រូបភាពទី២ ជាភាគបញ្ចប់ពេលព្រះពោធិសត្វទ្រង់បំពេញបារមីជួយ សង្គ្រោះសត្វលោកអោយផុតទុក្ខមានចំនួនដ៏ច្រើន ហើយព្រះពោធិសត្វ កំពុងនិងត្រាស់ដឹងជាព្រះពុទ្ធជាម្ចាស់។ ជារូបចំលាក់ដែលមានឈ្មោះល្បី-ល្បាយបំផុតក្នុងប្រាសាទបន្ទាយឆ្មារ។




រូបព្រះពោធិសត្វលោកេស្វរៈប្លែងរស្មីក្នុងឥរិយាបថផ្សេងៗ សព្វថ្ងៃនៅសល់ពី២អង្គ ដោយទាំងអស់មានចំនួន៨ អង្គ



www.elibraryofcambodia.org

ម្យ៉ាងទៀតមានចំនុចដែលគួរអោយសង្ស័យផងដែរនោះគឺពេលព្រះពោធិសត្វលោកេស្វរៈនិងក្លាយជាព្រះពុទ្ធជាម្ចាស់ ហេតុអ្វីព្រះអង្គទ្រង់នាំព្រះនាងប្រាជ្ញាបារមីតាទៅជាមួយផង។ រូបចំលាក់នេះមានគោលបំណងប្រាប់ពីរឿងអ្វី? តាមរយៈគម្ពីរការណ្ឌវយហៈពោលថា ព្រះពោធិសត្វលោកេស្វរៈ ព្រះអង្គបដិសេធក្នុងការចូលព្រះនិព្វានព្រោះព្រះអង្គមានព្រះទ័យក្នុងការជួយចំលងសត្វលោកអោយផុតទុក្ខ។ ព្រះអង្គបំប្លែងរស្មីរប្រកបដោយរស្មីជាច្រើនពិណ រន្ធរោមរបស់ព្រះអង្គមានចក្រវាលនៅខាងក្នុង។ ចំណែកព្រះពោធិសត្វប្រាជ្ញាបារមីតា តាមរយៈគម្ពីរប្រាជ្ញបារមីតាបានអោយដឹងថា មានព្រះពោធិសត្វភេទស្រីមួយអង្គទៀត គឺទេពីតារាជាព្រះជាយារបស់ព្រះពោធិសត្វលោកេស្វរៈ។ ដូចនេះព្រះនាងប្រាជ្ញាបារមីតានៅក្នុងព្រះហត្ថរបស់ព្រះពោធិសត្វលោកេស្វរៈទើបជានិមិត្តរូបបង្ហាញថា ព្រះពោធិសត្វទ្រង់បៀមដោយបញ្ញាចំណេះដឹង និងវិជ្ជាការ។

ខ្មែរបុរាណនិយមសាងព្រះពុទ្ធរូបសំខាន់៣អង្គប្រកបដោយ ព្រះពុទ្ធរូបនាគប្រក់ ព្រះពោធិសត្វលោកេស្វរៈ និងព្រះនាងប្រាជ្ញបារមីតា។ ខ្មែរបុរាណមានជំនឿទៅលើការបូជាបុគ្គល ទើបគេបានរកឃើញរូបចំលាក់របស់បុគ្គលដែលមានជីវិតជាព្រះអទិទេព ឬ រូបគោរព។ ដូចជាព្រះបាទយសោវរ្ម័នទី១ ទ្រង់សាងរូបគោរពយសោធរេស្វរៈ (ព្រះសិវលិង្គ ឬព្រះទេវរាជជារូបគោរពរបស់ព្រះអង្គ)។ ព្រះអង្គប្រតិស្ឋានទុកក្នុងប្រាសាទបាខែង និងទ្រង់ឆ្លាក់រូបគោរពព្រះរាជបិតាព្រះមារតាដែលទ្រង់ចូលទីវង្គត



www.elibraryofcambodia.org

ប្រតិស្ឋានទុកក្នុងប្រាសាទលលៃ។ ការសាងរូបចំលាក់ឧទិសថ្វាយចំពោះអ្នកដែលបាត់បង់ជីវិតទៅហើយដោយមានជំនឿថា ពេលធ្វើពិធីកម្មរួចរាល់ផ្លូវវិញ្ញាណអ្នកដែលស្លាប់ទៅក៏និងមកសន្ថិតនៅនិងរូបចំលាក់នោះ។

ចំណែកព្រះនាងប្រាជ្ញាបារមីតា ខ្មែរបុរាណបានយកជំនឿលទ្ធិបូជាបុគ្គលមកប្រើទើបមានជំនឿថា ព្រះនាងប្រាជ្ញាបារមីតាជាព្រះជាយារបស់ព្រះពោធិសត្វលោកេស្វរៈ។ ដូចជាព្រះបាទជ័យវរ្ម័នទី៧ ទ្រង់ឆ្លាក់រូបព្រះប្រាជ្ញាបារមីតាថ្វាយព្រះរាជមារតាទុកប្រាសាទតាព្រហ្ម និងឆ្លាក់រូបព្រះ-ពោធិសត្វស្រីជយវរេស្វរៈថ្វាយព្រះរាជបិតាទុកក្នុងប្រាសាទព្រះខ័ន។ មានបដិមាកម្មជាច្រើនអង្គរូបដូចព្រះនាងជ័យរាជទេវីក្នុងរូបព្រះនាងប្រាជ្ញាបារ-មីតា ដែលបានរកឃើញក្នុងបរិវេណរាជធានីអង្គធំ។ បច្ចុប្បន្នតម្កល់ទុកក្នុងសារៈមន្ទីរក្រុងបារីស ប្រទេសបារាំង កំពស់១៣០សម. ទ្រង់ប្រថាប់លិតជង្គង់។ បដិមាកម្មនេះមានព្រះឱរៈសំបែត ព្រះភក្ត្រស្លេកស្លាំងដែលស្តែងថា បដិមាកម្មនេះសាងឡើងចំពេលដែលព្រះនាងកំពុងប្រឈួន។ ដោយមូលហេតុមកពីព្រះនាងបាក់កំលាំងក្នុងការធ្វើសមាធិ។ នៅមានរូបចំលាក់មួយទៀតដោយខាងមុខផ្នួងព្រះកេសាមានព្រះធយានិពុទ្ធអមិតាភៈ ដែលជាការបង្ហាញថា បដិមាកម្មនេះសាងឡើងនៅពេលព្រះនាងចូលទីវង្គតទៅហើយ។ នៅបានរកឃើញរូបដូចព្រះនាងជ័យរាជទេវី ក្នុងរូបព្រះនាងប្រាជ្ញាបារមីតាក្នុងប្រាសាទព្រះគោ។ បច្ចុប្បន្នតម្កល់ទុកសារៈមន្ទីរជាតិក្រុងភ្នំពេញ។ ដោយមានកំពស់៩៨សម. ប្រថាប់ឈរតែខាងមុខផ្នួងព្រះ-



www.elibraryofcambodia.org

កេសា គ្មានព្រះធយានិពុទ្ធអមិតាភៈដែលស្តែងថា បដិមាកម្មរូបនេះសាង ឡើងខណៈពេលដែលព្រះនាងនៅមានព្រះជន្ម។ មានរូបចំលាក់ដូចព្រះបាទជ័យវរ្ម័នទី៧កំពស់១៤២សម. បានរកឃើញក្នុងប្រាសាទភីម៉ាយ ខេត្តនគររាជសីមា ប្រទេសថៃបច្ចុប្បន្ន តម្កល់ទុកក្នុងសារៈមន្ទីរជាតិភីម៉ាយ ខេត្តនគររាជសីមា។ និងមួយអង្គទៀតបានរកឃើញក្នុងប្រាសាទព្រះខ័ន បច្ចុប្បន្នតម្កល់ទុកក្នុងសារៈមន្ទីរជាតិក្រុងភ្នំពេញ។ រូបចំលាក់មានរូបរាងធាត់ប្រថាប់សមាធិ ជារូបចំលាក់ឆ្លាក់ពេលដែលព្រះអង្គនៅមានព្រះជន្ម ដោយសារព្រះហត្ថបានបាត់ទៅ។ សន្និដ្ឋានថា ព្រះហត្ថកំពុងប្រកងអញ្ជលីមុខព្រះឱរៈក្នុងឥរិយាបថសំដែងភាពគោរពចំពោះព្រះអទិទេក្នុងប្រាសាទប្រធាន។ ព្រះបដិមាករអង្គនេះទំនងជាតម្កល់នៅគូនិងរូបចំលាក់ព្រះនាងជ័យរាជទេវីប្រថាប់លិតជង្គង់ ព្រះហត្ថកាន់ភាជនៈដើម្បីថ្វាយរបស់បូជា។

ដូចនេះយើងអាចជឿថា សង្គមខ្មែរនាសម័យនោះប្រជារាស្ត្រខ្មែរជឿថា ព្រះបាទជ័យវរ្ម័នទី៧ និងព្រះនាងជ័យរាជទេវីមានឋានៈ ជាព្រះអទិពេទពោលគឺព្រះពោធិសត្វ។ សំរាប់រូបចំលាក់ព្រះពោធិសត្វប្លែងរស្មី យើងអាចសន្និដ្ឋានជំនឿក្នុងសង្គមខ្មែរនាសម័យនោះបានថា ព្រះនាងប្រាជ្ញាបារមីតាជាព្រះជាយារបស់ព្រះពោធិសត្វលោកេស្វរៈ ពេលព្រះពោធិសត្វបានទៅកើតជាព្រះពុទ្ធជាម្ចាស់ ព្រះនាងប្រាជ្ញាបារមីតាស្តេចក៏ទៅនិងទៅកើតជាព្រះពុទ្ធជាម្ចាស់ផងដែរ ទ្រង់ប្រថាប់នៅជាមួយគ្នាក្នុងពុទ្ធក្សេត្រឬឋានសួគ៌។



www.elibraryofcambodia.org

**អ្នករៀបរៀងជឿថា** ព្រះនាងឥន្ទ្រទេវី មានព្រះរាជគោលបំណង ចង់អោយព្រះនាងជ័យរាជទេវីបានរស់នៅជិតព្រះស្វាមី។ ព្រះអង្គទើបបាន បំពេញទានបារមីជំច្រើនដើម្បីថ្វាយព្រះរាជកុសលអោយព្រះនាងជ័យរាជ- ទេវី ព្រមទាំងបានឆ្លាក់រូបព្រះនាងប្រាជ្ញាបារមីតា ដោយមានចេតនាដែល ជំនឿថា ដួងវិញ្ញាណខ័ណ្ឌរបស់ព្រះនាងជ័យទេវីបានទៅកើតជាព្រះពោធិ- សត្វប្រាជ្ញាបារមីតា។ ដូចនេះរូបព្រះនាងប្រាជ្ញាបារមីតា គឺជារូបព្រះនាង ជ័យរាជទេវីប្រថាប់ក្នុងព្រះហត្ថរបស់ព្រះពោធិសត្វរួមគ្នាទៅកើតជាព្រះពុទ្ធ ជាម្ចាស់ជាមួយគ្នា។ នេះជាឆ្លុះបញ្ចាំងរឿងជំនឿនៃសេចក្ដីស្នេហាអមតៈ របស់ជនជាតិអាស៊ី ដែលជាទស្សនៈនៃសេចក្ដីស្នេហាដែលថា គូស្នេហ៍ និងនៅស្រលាញ់គ្នាហូតអស់មួយជីវិតទាំងជាតិនេះនិងជាតិខាងមុខ។

ក្នុងសង្គមខ្មែរយើងបច្ចុប្បន្នក៏នៅមានជំនឿបែបនេះ យើងបាន ឃើញប្រពៃណីធ្វើបុណ្យឧទិសបុណ្យកុសលជូនចំពោះមាតាបិតា ព្រមទាំង បុព្វការីជនដែលស្លាប់ទៅ។ ដោយជំនឿថា បុណ្យកុសលនិងបញ្ជូនទៅ ដល់គូរភរិយារស់នៅបានយ៉ាងសុខសប្បាយនាលោកខាងមុខ ឬ ឋានសួគ៌ ជាអមតៈ។

**អ្នករៀបរៀងគិតថា** យើងគួរតែយកចំនុចនេះជាយុទ្ធសាស្ត្រ ដើម្បី ឃោសនាផ្សព្វផ្សាយដើម្បីអោយប្រាសាទបន្ទាយឆ្មារជាទីកន្លែងអនុស្សាវរីនៃ សេចក្ដីស្នេហាអមតៈ ជាពិសេសមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈនិងមន្ទីរ



www.elibraryofcambodia.org

ទេសចរណ៍ខេត្តបន្ទាយមានជ័យ។ បើប្រាសាទបន្ទាយឆ្មារជាទីកន្លែងអនុស្សាវរីយ៍នៃសេចក្ដីស្នេហាអមតៈ គឺជាការជួយលើកស្ទួយផ្នែកទេសចរណ៍របស់ប្រាសាទបន្ទាយឆ្មារក៏ដូចជាខេត្តបន្ទាយមានជ័យដែរ។ ព្រមទាំងសាងកេរ្តិ៍ឈ្មោះអោយព្រះពោធិសត្វលោកេស្វរៈ និងព្រះនាងប្រាជ្ញាបារមីតា ដើម្បីអោយកូនខ្មែរបានស្គាល់ និងយល់ច្បាស់អំពីអរិយធម៌ និងវប្បធម៌ជាតិរបស់ខ្លួនអោយកាន់តែប្រសើរឡើង។ ហើយក៏អាចធ្វើអោយគូរសង្សារ ឬ គូអនាគតប្រាថ្នា និងធ្វើដំណើរទៅកាន់ប្រាសាទនេះ ដើម្បីអធិដ្ឋានសូមពរពីបាទជ័យវរ្ម័នទី៧ និងព្រះនាងជ័យរាជទេវី ដើម្បីអោយព្រះអង្គទាំងពីរព្រះទានពរជ័យដើម្បីអោយចំណងស្នេហារបស់ខ្លួនសមប្រាថ្នានៅគង់វង់ឋិតថេរ និងអមតៈជានិច្ចនិរន្តតទៅ ដូចគ្នានិងគូរស្នេហារបស់ព្រះអង្គ។



www.elibraryofcambodia.org

## ប្រាសាទបន្ទាយឆ្មារ ធ្លាប់ជាទីក្រុងដ៏សំខាន់របស់ព្រះបាទជ័យវរ្ម័នទី៧

មានចំនុចសង្កេតអំពីទីតាំងរបស់ប្រាសាទបន្ទាយឆ្មារ ដោយលោក ម៉ោនិយេ បុរាណវិទ្យាជនជាតិបារាំង។ គាត់បានធ្វើការសិក្សាអំពីប្រាសាទនេះដោយបានបង្ហាញថា ប្រាសាទបន្ទាយឆ្មារបានលើកដីព័ទ្ធជុំវិញជាកំពែងរាងបួនជ្រុងទ្រវែង មានទំហំដោយប្រមាណ២.៥គីឡូម៉ែត្រ។ បរិវេណខាងក្នុងមានផ្ទៃក្រលាទំហំប្រមាណ៦គីឡូម៉ែត្រការេនៅទិសខាងកើត បានជីកបារាយទំហំធំដោយទទឹងប្រមាណ១គីឡូម៉ែត្រនិងបណ្តោយ២គីឡូម៉ែត្រ។ នៅចំកណ្តាលបារាយគេបានសាងប្រាសាទមានបុណ្យមានរាងជារង្វង់មូលស្រដៀងគ្នានិងប្រាសាទនាគព័ន្ធនាក្រុងអង្គរធំ។ ប្រាសាទបន្ទាយឆ្មារមានកំពែងព័ទ្ធជុំវិញ ដែលជាយុទ្ធវិធីក្នុងការការពារសត្រូវដែលយុទ្ធសាស្ត្រថ្មីមួយ ទើបនិងកើតមាននៅក្នុងរជ្ជកាលព្រះជ័យវរ្ម័នទី៧ ដូចគ្នានិងការសាងកំពែងព័ទ្ធជុំវិញរាជធានីអង្គរធំ មានក្លោងទ្វារបើកបិទដើម្បីរក្សាសុវត្ថិភាពរបស់រាជធានី។ ម្យ៉ាងទៀតប្រាសាទបន្ទាយឆ្មារនៅជាជ័យភូមិ ជាចំនុចយុទ្ធសាស្ត្រគ្រប់គ្រងផ្លូវគមនាគមន៍ពីរាជធានីអង្គរធំទៅកាន់តំបន់ទន្លេចៅ-ព្រះយ៉ា (Chaopraya River) ដែលស្ថិតនៅភាគខាងលិចប្រទេស-ថៃសព្វថ្ងៃ និងដែនដីហិធរបុរៈដែលស្ថិតនៅភាគឦសានប្រទេសថៃសព្វថ្ងៃ។ ដូចនេះ ជារឿងសមគួរដែលថា ប្រាសាទបន្ទាយឆ្មារទំនងជាទីតាំងរបស់ទីក្រុងដ៏សំខាន់របស់ព្រះជ័យវរ្ម័នទី៧។



www.elibraryofcambodia.org

សិលាចារឹកប្រាសាទបន្ទាយឆ្មារបានអោយយើងដឹងថា ប្រាសាទនេះសាងឡើងដើម្បីជាទីកន្លែងបញ្ចុះព្រះសពរបស់ព្រះអង្គម្ចាស់សិស្រីន្ទ្រកុមារ។ ចំណែកសិលាចារឹកព្រះខ័នបានអោយយើងដឹងទៀតថា ព្រះបាទជ័យវរ្ម័នទី៧ទ្រង់ប្រតិស្ឋានព្រះពុទ្ធជ័យមហានាថ[៣] ក្នុងក្រុងស្រីជយរាជធានីឈ្មោះទីក្រុងនេះប្រាប់ថា ក្រុងស្រីជយរាជធានីនាអតីតកាលជាក្រុងដែលមានតួនាទីជារាជធានីទីកន្លែងប្រថាប់របស់ព្រះមហាក្សត្រពីមុនមក។ ក្រុងស្រី–ជយរាជធានី និងក្រុងយសោធរបុរៈដោយទាំងពីរនេះមាននៅក្នុងសិលា–ចារឹកប្រាសាទខ័នដូចគ្នា។ ដូចនេះបង្ហាញថា មានរាជធានីទាំងពីរនៅក្នុងប្រវត្តិសាស្ត្រហើយក៏មិនមែនរាជធានីជាមួយគ្នា។ ក្រុងស្រីជយរាជធានីទំនងជារាជធានី ដែលព្រះបាទជ័យវរ្ម័នទី៧ ធ្លាប់គង់ប្រថាប់ហើយរាជធានីនេះទំនងជានៅមិនឆ្ងាយពីរាជធានីអង្គរធំ។

សិលាចារឹកប្រាសាទវិមានអាកាសបានត្រឹមតែប្រាប់អោយយើងដឹងថា «ពេលព្រះបាទជ័យវរ្ម័នទី៧ ទ្រង់ដកកងទ័ពចេញពីអាណាចក្រចាម

---

[3] គឺជាព្រះពោធិសត្វដំណាងអោយព្រះបាទជ័យវរ្ម័នទី៧ ដែលព្រះអង្គបានស្ថាបនាឡើងចំនួន២៣អង្គ ដើម្បីយកប្រតិស្ឋានក្នុងបណ្តាខេត្តសំខាន់ៗចំនួន២៣ក្នុងអា–ណាចក្រខ្មែរនាសម័យនោះ ហើយសព្វថ្ងៃត្រូវបានគេរកឃើញមួយចំនួននៅភាគកណ្តាល ភាគខាងលិច និងភាគខាងជើងប្រទេសថៃ ព្រមទាំងមួយចំនួនទៀតត្រូវបានគេឃើញក្នុងប្រទេសខ្មែរដូចជា នៅដំបន់ព្រះសាទព្រះខ័ន ខេត្តព្រះវិហារ ភ្នំបានន្ទ ខេត្តបាត់ដំបង និងភ្នំជី សួរខេត្តតាកែវ ជាដើម



www.elibraryofcambodia.org

ព្រះអង្គទ្រង់បានប្រថាប់ក្នុងអាណាចក្រខ្មែរ» តែសិលាចារឹកមិនបានប្រាប់ដោយបានដឹងថា ព្រះអង្គទ្រង់គង់ប្រថាប់នៅទីណានោះទេ រួមទាំងដែនដីមហិធរបុរៈ ដែលជាដែនដីដើមកំណើតរាជវង្សរបស់ព្រះអង្គ (បច្ចុប្បន្នដែនដីនេះស្ថិតនៅភាគឦសានប្រទេសថៃ ដែលគ្របដណ្តប់ចំនួន១៩ខេត្តក្រុង ឬស្មើនិងមួយភាគបីនៃប្រទេសថៃទាំងមូល)។ ដូចនេះ ប្រាសាទបន្ទាយឆ្មារអាចជាទីតាំងសំខាន់របស់ព្រះបាទជ័យវរ្ម័នទី៧ ដោយរូបចំលាក់

ក្នុងប្រាសាទបន្ទាយឆ្មារ មានចំនុចខ្លះដែលបង្ហាយថា ជារូបចំលាក់បង្ហាញពីសង្គ្រាមជាមួយមហាវីរៈបុរសដើម្បីរំដោះទឹកដី។ រឿងផ្ទាល់របស់ព្រះអង្គរឿងក្នុងព្រះសំណាក់របស់ព្រះរាជសំណាក់របស់ព្រះជ័យវរ្ម័នទី៧។ រូបចំលាក់និទានរឿងទាំងនេះអាចនិងកំពុងនិទានរឿងជាច្រើនរឿងដែលកើតឡើងក្នុងប្រាសាទបន្ទាយឆ្មារ។ ដូចនេះជារឿងសមគួរដែលថា ទីតាំងប្រាសាទបន្ទាយឆ្មារ គឺក្រុងស្រីជយរាជធានីដែលបានចារឹកទុកប្រាសាទព្រះខ័ន។



www.elibraryofcambodia.org

## ខាងក្រោមនេះជារូបចំលាក់មួយចំនួនរបស់ប្រាសាទបន្ទាយឆ្មារ




ហោជាំងគោបុរៈទិសខាងកើតដោយឆ្លាក់ជារូបព្រះពោធិសត្វលោកេស្វរៈ
បង្ហាញពីអានុភាពកណ្ដាលចក្រវាល




បណ្ដាព្រះពោធិសត្វក្នុងសិរបថសមាធិក្នុងរង្វង់ផ្កាឈូក ផ្នែកក្នុងថែវ



www.elibraryofcambodia.org




ទ្វារតូច នៅខាងស្តាំក្លោងទ្វារទិសខាងកើត




រូបចំណាក់ថែវទិសខាងកើតផៀងខាងត្បូង មានឆ្លាក់ជារឿងកិត្តិយសក្នុងជ័យជំនះ

ក្នុងសង្គ្រាមជើងទឹកជាមួយអាណាចក្រ ចាមក្នុងទន្លេសាប



www.elibraryofcambodia.org




សរសេរជើងរៀងថែវដែលមានឆ្លាក់ជាក្បាច់ចំលាក់ផ្សេងៗ

និងរូបព្រះពោធិសត្វកំពុងសមាធិ




ក្លោងទ្វារទិសខាងកើត  បច្ចុប្បន្នបានបាក់បែកអស់ទៅហើយ



www.elibraryofcambodia.org




ហោជាងនៃប្រាសាទ ធ្លាក់ជាពុទ្ធប្រវត្តិ




កាព្យឆន្ទប្រកបសំលេងជន្ត្រីដ៏ពិរោះ ជារឿងរ៉ាវបស់តាឬស្សី វាល្មិក



www.elibraryofcambodia.org

អ្នកតែងគម្ពីរ រាមយណៈ ព្រះព្រហ្ម សត្វក្រៀលនិងព្រានព្រៃ




ព្រះអទិទេព «ត្រីមូរតិ» ក្នុងលទ្ធិ «ហិណ្ឌូតន្ត្រៈ» ដោយមានព្រះសិវៈនៅ
លើកំពូលព្រះនារាយណ៍នៅខាងស្តាំនិងព្រះព្រហ្មនៅខាងឆ្វេង




រូបមហាកាព្ទ «រាមាយនៈ» ដ៏ស័ក្តិសិទ្ធី ព្រះរាមកំពុងប្រល័យទស្សកណ្ឋ
លាន់ឮពេញភពទាំង ៣



www.elibraryofcambodia.org




រូបចាំលាក់ ទស្សកណ្ឋ និង កុម្ភកណ្ណ




កាព្យឆន្ទប្រកបផន្ត្រីដ៏ពិរោះ រឿងនិទានរបស់តាឬស្សីវាលមិកិ ព្រះនាងសិតា និងព្រានព្រៃ



www.elibraryofcambodia.org



រូប ព្រះនាងប្រាជ្ញាបារមិតា ព្រះទេវីនៃវជ្រយាន កំពុងប្រោសសត្វលោក



រូបភាពកាព្យឆន្ទប្រកបដន្ត្រីដ៏ពិរោះតាឬស្សីវាមិកិ អ្នកតែងគម្ពីរ រាមាយនៈ

កំពុងនិទានរឿងនារទៈនិងព្រះនារាយណ៍ប្រល័យតាឬស្សីសម្ពុកៈ



www.elibraryofcambodia.org




ដំបូលវិហារនិងថែវដែលតភ្ជាប់ក្នុងមណ្ឌលពិធីកម្មខាងក្នុងបានបាក់បែកអស់ទៅហើយ តែយើងអាចមើលឃើញរូបចំលាក់កិន្នរី និងគ្រុឌជាដំណាងអោយសត្វក្នុងព្រៃហិមពាន្ត ជាព្រៃធំព័ទ្ធជុំវិញភ្នំព្រះសុមេរុដែលជាកន្លែងប្រថាប់របស់ព្រះពោធិសត្វព្រះអទិទេព និងព្រះពុទ្ធជាម្ចាស់។



www.elibraryofcambodia.org







កំពែងប្រាសាទ រូបចំលាក់លើកំពែងជុំវិញមណ្ឌលនេះជារូបព្រះអទិទេពក្នុងសាសនា ហិណ្ឌូនិងទេវពោធិសត្វដែលមកគល់ព្រះអទិពុទ្ធៈ។



www.elibraryofcambodia.org




រូបចំលាក់ហោជាងផ្នែកខាងក្នុងប្រាសាទប្រធាន ជារូបព្រះពោធិសត្វលោកេស្វរៈព្រះហត្ថ៨ ដោយជះអានុភាពក្នុងលោកទាំង៣ ។




រូបចំលាក់ ព្រះពុទ្ធជាម្ចាស់មានព្រះហត្ថ ៤



www.elibraryofcambodia.org




រូបចំលាក់ហោជាងផ្នែកខាងក្នុងប្រាសាទប្រធានជារូបព្រះភៃសជ្ជយសុគតព័ទ្ធ
ជុំវិញដោយសព្វសត្វនិងទេវតា។




រូបព្រះពុទ្ធជាម្ចាស់ក្នុងស៊ុមវិមានកែវដោយបង្ហាញអនុភាពនៅលើកំពែងព័ទ្ធ
ជុំវិញមណ្ឌលទាំង៤ ។



www.elibraryofcambodia.org




ព្រះវិហារឬកុដិរបស់ព្រះសង្ឃដែលមានថែវរាង៤ជ្រុងទ្រវែងព័ទ្ធជុំវិញថែវក្នុងទិសនេះ
ធ្វើជាកំពែងមានបង្អួច ដំបូលប្រក់ថ្មភក់ ប្រកបដោយរូបព្រះពុទ្ធជាម្ចាស់អមិតាភៈ ។




រូបព្រះពោធិសត្វលោកេស្វារៈប្លែងរស្មីក្នុងឥរិយាបថផ្សេងៗ សព្វថ្ងៃនៅសល់២អង្គ ដោយ
ទាំងអស់មានចំនួន៨ អង្គ។



www.elibraryofcambodia.org




រូបចំលាក់បង្ហាញពីក្បួនទ័ពខ្មែរធ្វើសង្គ្រាមជាមួយអាណាចក្រចាម  នៅជញ្ជាំងថែវខាងជើង



www.elibraryofcambodia.org




រូបភាពរាជទូត ចូលគល់ព្រះមហាក្សត្រដោយមានមន្ត្រីតូចធំនៅជុំវិញព្រមទាំងមានអ្នកប្រែ
ភាសាជួយប្រែភាសាអោយព្រះរាជាផងដែរ




កំពែងទិសខាងត្បូង មានរូបភាពការហែរក្បួនទ័ព និងព្រះរាជកិច្ចរបស់ព្រះរាជា.



www.elibraryofcambodia.org

## ២.១.៨ ប្រាសាទបន្ទាយទំព (Prasat Banteay Top)

សង់ឡើងនៅក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧រចនាបថបាយ័នដើម្បីបូជាចំពោះព្រះពុទ្ធសាសនានិកាយមហាយាន ដែលមានទីតាំងនៅទិសខាងត្បូងប្រាសាទបន្ទាយឆ្មារប្រហែល៧គីឡូមែត្រ។ ជាប្រាសាទមានទំហំធំដោយមានទាំងអស់៥ប្រាសាទ សង់ឡើងនៅលើគ្រឹះជាមួយគ្នាដោយមានចំនុចដែលគួរអោយសង្កេតផងដែរនោះគឺ ពីដើមទំនងជាមាន៣ប្រាសាទប៉ុណ្ណោះ ក្រោយមកទើបសាងប្រាសាទ២បន្តទៀត ហើយយើងអាចសង្កេតឃើញថា ប្រាសាទសង់ឡើងដោយភាពប្រញាប់ប្រញាល់ដោយជញ្ជូនឧបករណ៍ពីប្រាសាទផ្សេងៗមកប្រើក្នុងការកសាង។

សន្និដ្ឋានថា ប្រាសាទបន្ទាយទ័ពទំនងជាសង់ឡើងដើម្បីជាទីកន្លែងបញ្ចុះព្រះសពរាជវង្សរបស់ព្រះបាទជ័យវរ្ម័នទី៧។ នៅក្នុងប្រាសាទនេះផងដែរ គេបានរកឃើញព្រះពុទ្ធរូបនាគប្រក់មានសិល្បៈដ៏វិចិត្រកំពស់ប្រមាណ២មែត្រ ដោយព្រះភក្ត្រស្រដៀងគ្នានិងព្រះភក្ត្រព្រះបាទជ័យវរ្ម័នទី៧។ សព្វថ្ងៃតម្កល់ទុកក្នុងវត្តខាងត្បូងទីប្រជុំជនស្រុកថ្មពួក។



www.elibraryofcambodia.org

## ២.១.៩ ប្រាសាទតាព្រហ្ម

ស្ថិតនៅស្រុកបាទីខេត្តតាកែវ ត្រូវបានសង់ឡើងក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ដើម្បីឧទ្ទិសថ្វាយចំពោះព្រះពុទ្ធសាសនានិកាយមហាយាន។ ដោយមានបណ្តោយប្រមាណ៤២មែត្រនិងទទឹងប្រមាណ៣៦មែត្រនិងកំពស់ប្រមាណ១១មែត្រ។ ប្រាសាទនេះសង់ឡើងដោយថ្មភក់ផ្សំនិងថ្មបាយក្រៀមដោយមានជញ្ជាំងខ័ណ្ឌជាបន្ទប់ៗ។ នៅខាងក្រៅមានឆ្លាក់រូបចំលាក់ទេពអប្សរ។ ផ្នែកខាងក្នុងមានបន្ទប់៥ដែលមានរូបព្រះពោធិសត្វលោកេស្វរៈពីរព្រះអង្គបែរព្រះភក្ត្រទៅទិសខាងកើត ដោយនៅចំពីមុខមានរូបគ្រុឌនៅចំពីមុខមានក្លោងទ្វារមួយ មានថែវព័ទ្ធជុំវិញតួប្រាសាទ និងមានកំពែងព័ទ្ធជុំវិញ ចំណែកខាងក្រៅមានគូរទឹកព័ទ្ធជុំវិញ។

ក្រៅពីប្រាសាទដូចពោលខាងលើនៅមានប្រាសាទជាច្រើនទៀតដែលព្រះអង្គបានកសាងទុកដូចជាប្រាសាទវត្តភ្នំបានន្ទ ក្នុងខេត្តបាត់ដំបងប្រាសាទព្រះខ័ន ខេត្តកំពង់ធំ និងប្រាសាទតាព្រហ្ម ខេត្តតាកែវជាដើម។



www.elibraryofcambodia.org

## ២.២ សមិទ្ធិផលដែលបន្សល់ទុកក្នុងប្រទេសថៃសព្វថ្ងៃ

ខាងលើបានរៀបរាប់រួចមកហើយនូវស្នាព្រះហស្តរបស់ព្រះអង្គក្នុងការសាងសង់សាសនាដើម្បីបុព្វហេតុសង្គមកិច្ច និងសាសនាដែលមាននៅក្នុងស្រុកខ្មែរនាបច្ចុប្បន្ន។ ជាបន្តយើងនឹងសិក្សាអំពីស្នាព្រះហស្តរបស់ព្រះអង្គដែលបានបន្សល់ទុកក្នុងប្រទេសថៃបច្ចុប្បន្ន ដោយលើកយកប្រាសាទសំខាន់ៗតាំងពីភាគឦសានរហូតដល់ព្រំដែនប្រទេសភូមា ដែលព្រះអង្គបានសង់ដើម្បីបំរើវិស័យសាសនា និងសង្គមកិច្ចសំរាប់ជាផលប្រយោជន៍ដល់ប្រជារាស្ត្ររបស់ព្រះអង្គ ហើយភស្តុតាងនេះដែរជាសក្ខីភាពបង្ហាញពីព្រះទ័យទុកដាក់ចំពោះអាណាប្រជានុរាស្ត្រ ដោយព្រះអង្គមិនត្រឹមតែអភិវឌ្ឍន៍នៅតំបន់រាជធានីអង្គរប៉ុណ្ណោះទេសូម្បីតែនៅតំបន់ជាយដែនដាច់ស្រយាលក៏ត្រូវបានព្រះអង្គយកព្រះទុកដាក់ផងដែរ។

ខាងក្រោមនេះអ្នករៀបរៀង នឹងលើកយកប្រាសាទសំខាន់ៗមួយចំនួននៅតាមព្រំដែនភាគខាងលិចរបស់អាណាចក្រខ្មែរសម័យបុរាណ តែសព្វថ្ងៃនេះជាព្រំដែនភាគខាងលិចរបស់ប្រទេសថៃ មកអធិប្បាយដូចខាងក្រោមនេះ÷



www.elibraryofcambodia.org

### ២.២.១ ប្រាសាទវត្តកំពែងលែង (Prasat Watkampanglang)

សព្វថ្ងៃស្ថិតនៅក្នុងស្រុកមឿង (Meuang District) ខេត្តពេជ្របុរី (Pattaburi Province) តាំងនៅភាគខាងត្បូង ឆៀងខាងលិចក្រុងបាងកកដោយរយៈផ្លូវប្រមាណ១៧៣គម។ ដោយប្រាសាទនេះអ្នកបុរាណវិទ្យាសន្និដ្ឋានថា ត្រូវនឹងក្រុងស្រីជ័យវជ្របុរីដែលបានចារឹកក្នុងប្រាសាទព្រះខ័នដែលព្រះបាទជ័យវរ្ម័នទី៧ទ្រង់យកព្រះពុទ្ធជ័យមហានាថ ទៅប្រតិស្ឋានដើម្បីអោយកើតសេរីសួរស្តីដល់អាណាប្រជានុរាស្ត្ររបស់ព្រះអង្គ

ប្រាសាទវត្តកំពែងលែង មានរាងជាចតុកោណកែងមានកំពែងថ្មបាយក្រៀមព័ទ្ធជុំវិញបែរមុខទៅទិសខាងកើត។ ផ្នែកខាងក្នុងកំពែងជាទីតាំងនៃប្រាសាទថ្មបាយក្រៀមចរនាបថបាយ័នមានទាំងអស់៤អង្គ ប្រាសាទ៣អង្គផ្នែកខាងមុខរៀងគ្នាក្នុងជួរតែមួយពីជើងទៅត្បូង ដោយប្រាសាទមានទំហំធំនិងខ្ពស់ជាងប្រាសាទប្រាសាទ២អង្គទៀត។ ចំណែកប្រាសាទអង្គទី៤តាំងនៅខាងក្រោយនៃប្រាសាទប្រធានទិសខាងកើតនិងមានគោបុរៈមួយដែលមានកំពូល ជាលក្ខណៈដូចប្រាសាទនៅខាងក្នុងកំពែងដែលព័ទ្ធជុំវិញប្រាសាទមានស្រះទឹកមួយនៅជិតកំពែងទិសខាងកើតផងដែរ។



www.elibraryofcambodia.org



ប្រាសាទវត្តកំពែងលែង

## អង្គប្រកបនៃសាសនស្ថាន

### ១. គោបុរៈ (ច្លោងទ្វារ)





www.elibraryofcambodia.org

សង់ដោយថ្មបាយក្រៀមតាំងនៅទិសខាងកើតនៃប្រាសាទប្រធាន លក្ខណៈជាប្រាសាទខ្មែរសីខរៈ ឬផ្នែកកំពូលនៅមានសភាពតាមផ្នែកនីមួយៗ នៅមានសភាពល្អ បន្ទប់ឬគូវិមានមានរាងជា៤ជ្រុងទ្រវែង មានមុខចេញពីបន្ទប់វិហារទាំង៤ទិសជាចតុមុខ។

## ២. ប្រាង្គប្រធាន



ប្រាសាទប្រធានខាងក្នុងមានតំកល់ព្រះពុទ្ធរូប

សង់ដោយថ្មបាយក្រៀមតាំងនៅលើគ្រឹះដែលត្រួតលើគ្នា២ជាន់ កំពូលប្រាសាទបានបែកទៅហើយ តែនៅសល់ថ្នាក់ក្រោមរួមទាំងមានរូបនាគនិងក្បែបក្បូរនៅតាមផ្នែកផ្សេងៗខ្លះ។ បន្ទប់ឬវិមាននៃប្រាសាទប្រធានជារាង៤ជ្រុងទ្រវែងតាំងនៅលើគ្រឹះរាង៤ជ្រុងមានទ្វារចូលទាំង៤ទិស។



www.elibraryofcambodia.org

ហោជាងលើទ្វារចូលទិសខាងជើងនិងទិសខាង កើតនៃប្រាសាទនៅមាន ក្បាច់ចំលាក់នៅសល់ដូចគ្នានិងបរិវេណគ្រឹះ។

## ៣. ប្រាង្គទិសខាងជើង

សង់ដោយថ្មបាយក្រៀមតាំងនៅទិសខាងជើងនៃប្រាង្គប្រធាន បច្ចុប្បន្នបាក់បែកនៅសល់ត្រឹមតែផ្ទៃកទិសខាងលិចប៉ុណ្ណោះលក្ខណៈទំនង ដូចគ្នានិងប្រាសាទប្រធានតែមានទំហំតូចជាង មានទ្វារចូលពីទិសខាងកើត និងទិសខាងលិចទ្វារទិសខាងត្បូងនិងទិសខាងជើងជាទ្វារបញ្ឆោត។



www.elibraryofcambodia.org




ប្រាង្គទិសខាងជើងដោយខាងក្នុងមានតំកល់ព្រះពុទ្ធរូប



www.elibraryofcambodia.org

## ៤. ប្រាង្គទិសខាងត្បូង

សង់ដោយថ្មបាយក្រៀម តាំងនៅទិសខាងត្បូងនៃប្រាសាទប្រធាន មានលក្ខណៈដូចគ្នានិងប្រាង្គអង្គផ្សេងៗនិងទំហំខ្ពស់ស្មើរគ្នានិងប្រាង្គទិសខាងជើង ចំណែកកំពូលនិងវិមាននៅគង់វង់ហាក់ដូចជាល្អនិងគ្រឹះកន្លែងខ្លះទទួលការជួសជុលនាសម័យក្រោយ។ មានទ្វារចូលពីទិសខាងកើតនិងទិសខាងលិចចំណែកទិសខាងត្បូងនិងទិសខាងជើងធ្លាក់ជាទ្វារបញ្ឆោត។ នៅត្រង់គ្រោងទ្វារសួនរូបជារូបព្រះពុទ្ធជាម្ចាស់ក្នុងឥរិយាបថប្រទានអភ័យ



ប្រាង្គទិសខាងត្បូងដោយខាងក្នុងមានតំកល់ព្រះពុទ្ធរូប



www.elibraryofcambodia.org

## ៤. ប្រាង្គទិសខាងលិច

តាំងនៅខាងក្រោយប្រាសាទប្រធានទិសខាងលិច បច្ចុប្បន្នបាក់បែកស្ទើរអស់ទៅហើយនៅសល់តែជញ្ជាំងទិសខាងជើង ចំណែកគ្រឹះមានកំពស់ខ្ពស់ជាងប្រាង្គផ្សេងៗទៀត។ លក្ខណៈស្រដៀងគ្នានិងប្រាង្គទិសខាងជើង និងប្រាង្គទិសខាងត្បូងដែរ មានទ្វាចូលពីទិសខាងកើតនិងទិសខាងលិច ចំណែកទិសខាងជើងនិងទិសខាងត្បូងជាទ្វារបញ្ឆោត។



ប្រាង្គទិសខាងលិចដោយខាងក្នុងមានតំកល់ព្រះពុទ្ធរូប



www.elibraryofcambodia.org

**៥. កំពែង**សង់ដោយថ្មបាយក្រៀមព័ទ្ធជុំវិញក្រុមប្រាង្គប្រាសាទ និង ស្រះទឹកនៅកណ្ដាលកំពែងទាំង៤ទិសមានទ្វារចូលគ្រប់ទិស។ ស្រះទឹកតាំង នៅទិសអាគ្នេយ៍នៃក្រុមប្រាសាទខាងក្នុងកំពែងជាស្រះក្រាលដោយថ្មបាយ ក្រៀមសព្វថ្ងៃរលប់អស់នៅហើយ។

## រូបបដិមាករបានរកឃើញរូបបដិមាករចំនួន ៤ប្រភេទ

១. ព្រះពោធិសត្វលោកេស្វរៈប្លែងរស្មីរមួយអង្គសភាពបាក់បែក

២. ព្រះពោធិសត្វលោកេស្វរៈព្រះហត្ថ៤ សភាពបាក់បែកនៅសល់ត្រឹម តែព្រះវរកាយ និងកំណាត់ព្រះហត្ថ៤កំណាត់។ ក្នុងសិល្បៈខ្មែរ បើនៅល្អ និងមានព្រះហត្ថ៤ ព្រះហត្ថស្ដាំខាងមុខកាន់ផ្កាឈូក ព្រះហត្ថឆ្វេងខាងមុខ កាន់ឆ្នាំងទឹក ព្រះហត្ថស្ដាំខាងក្រោយកាន់ក្លួនប្រខាំព្រះហត្ថឆ្វេងខាង ក្រោយកាន់គម្ពីរ។

៣. ព្រះពុទ្ធរូបនាគប្រក់ ជាព្រះពុទ្ធរូបទ្រង់គ្រឿងលក្ខណៈរកឃើញត្រឹម ផ្នែកនៃព្រះភ័ក្រនិងព្រះឧរៈ ផ្នែកខាងក្រោយមានផែនថ្មឆ្លាក់ជាប់ជាខ្លួននាគ បើកពពែរ។ បើនៅល្អនិងមានលក្ខណៈជាព្រះពុទ្ធរូបនាគប្រក់គង់លើស្ដេច នាគក្នុងឥរិយាបថសមាធិ។

៤. ព្រះនាងប្រាជ្ញាបារមីតារកឃើញត្រឹមតែព្រះកេសប៉ុណ្ណោះ បើនៅល្អ និងមានលក្ខណៈព្រះពោធិសត្វភេទស្ត្រីមានព្រះហត្ថពីរ ព្រះហត្ថស្ដាំកាន់ ផ្កាឈូកក្នុងឥរិយាបថប្រទានពរ។



www.elibraryofcambodia.org

## ២.២.២ ប្រាសាទប្រាង្គសាមយ៉ត (Prasat sam Yod)

សព្វថ្ងៃតាំង នៅស្រុកមឿង (Muang District) ខេត្តលពបុរី (Lopburi Province) ភាគខាងជើងឆៀងខាងលិចក្រុងបាងកក ដោយរយៈផ្លូវប្រមាណ១៨៣គម។ ប្រាសាទនេះអ្នកបុរាណវិទ្យាសន្និដ្ឋានថា ត្រូវនិងក្រុងលពបុរៈដែលបានចារឹកក្នុងប្រាសាទព្រះខ័ន ដែលព្រះបាទជ័យវរ្ម័នទី៧ទ្រង់យកព្រះពុទ្ធជ័យមហានាថទៅប្រតិស្ឋាន ដើម្បីអោយសេរីសួស្តីដល់អាណាប្រជានុរាស្ត្ររបស់ព្រះអង្គ។






www.elibraryofcambodia.org

បាសាទសាមយ៉តអង្គប្រាង សាងឡើងតាមរចនាបថបាយ័នមាន៣អង្គនិងផ្លូវដើរតជាប់គ្នាមានផ្លូវចេញចូល ដោយសង់ជណ្តើរសំរាប់ឡើងនៅជុំវិញប្រាង្គ។

ប្រាសាទប្រាង្គសាមយ៉ត ស្ថិតនៅស្រុកមឿង ខេត្តលពបុរី ជាសាសនស្ថានក្នុងរចនាបថបាយ័ន ដែលជាប្រាសាទមានឈ្មោះល្បីល្បាយមួយក្នុងបណ្តាប្រាសាទខ្មែរផ្សេងៗទៀតក្នុងប្រទេសថៃ។ ប្រាសាទនេះប្រកបដោយប្រាង្គបីអង្គរៀងគ្នាពីជើងទៅត្បូង។ ប្រាង្គនីមួយៗតភ្ជាប់គ្នាដោយឆ្នូនដែលសង់ឡើងពីថ្មក្រៀមនិងប្រដាប់ដោយក្បាច់ចំលាក់ ធ្វើអោយអ្នកប្រាជ្ញបុរាណវិទ្យាជឿថា ប្រាសាទនេះសង់ឡើងក្នុងសម័យព្រះបាទជ័យវរ្ម័នទី៧ដើម្បីឧទិសចំពោះព្រះពុទ្ធនិកាយមហាយាន ដែលប្រាង្គអង្គកណ្តាលអាចជាកន្លែងដំកល់ព្រះពុទ្ធរូបនាគប្រក់ ប្រាង្គអង្គខាងត្បូងអាចជាកន្លែងដំកល់ព្រះពោធិសត្វ និងប្រាង្គអង្គខាងជើងអាចជាកន្លែងដំកល់ព្រះនាងប្រាជ្ញាបារមីតា។

ក្នុងសម័យអាយុធ្យាប្រាសាទនេះត្រូវទទួសការបដិសង្ខរណ៍ឡើងម្តងដូចជាមានការសង់ព្រះវិហារអំពីឥដ្ឋនៅផ្នែកខាងមុខនៃប្រាង្គកណ្តាលមានការប្លូកឥដ្ឋបិតមាត់អង្គួចខ្លះ។ សន្និដ្ឋានថា ការផ្លាស់ប្តូរនេះគឺដើម្បីអោយសាសនស្ថាននេះក្លាយជាសាសនស្ថានព្រះពុទ្ធសាសនាថេរវាទ។



www.elibraryofcambodia.org




ផ្លូវដើរខាងក្នុងប្រាសាទដោយតភ្ជាប់គ្នារហូតក្នុងប្រាង្គទាំង៣ តែអង្គនីមួយៗមានភាពស្រលះទូលាយនៅត្រង់កណ្តាល មានតម្កល់ព្រះពុទ្ធរូបជាច្រើនតែគ្មានព្រះកេស។



www.elibraryofcambodia.org




ព្រះពុទ្ធរូបក្នុងប្រាសាទ ៣ យ៉ត ដោយព្រះពុទ្ធរូបនីមួយៗគ្មានព្រះកេស




ព្រះវិហារមុខប្រាសាទ សាងឡើងនៅសម័យអាយុធ្យា



www.elibraryofcambodia.org





រូបបិយវត្ថុថៃសម័យមុនដោយមានរូបប្រាសាទសាមយ៉តភ្ជាប់ជាមួយ



www.elibraryofcambodia.org

### ២.២.៣ ប្រាសាទមឿងសិង្ហ *(Prasat Muang Sing)*

ប្រាសាទមឿងសិង្ហបច្ចុប្បន្នស្ថិតនៅក្នុងស្រុកថៃយោក (Thaiyok District) ខេត្តកាញ្ចនៈបុរី (Kanchanaburi Province) ដោយតាំងនៅភាគខាងលិចក្រុងបាងកកដោយរយៈផ្លូវប្រមាណ១៦៩គម។ ជាខេត្តមានព្រំប្រទល់ជាប់និងប្រទេសភូមា។ ដែលព័ទ្ធជុំវិញដោយជួរភ្នំដោយលក្ខណៈក្រុងមឿងសិង្ហជារាង៤ជ្រុង។ កំពែងក្រុងសង់ដោយថ្មបាយក្រៀមទទឹងប្រមាណ៨០០ម៉ែត្រ បណ្តោយប្រមាណ៨៥០ម៉ែត្រ កំពស់៧ម៉ែត្រមានទ្វារចូលទាំង៤ទិសមានគូទឹកព័ទ្ធជុំវិញនិងខាងក្នុងមានស្រះទឹកចំនួន៦។

ដោយប្រាសាទនេះអ្នកបុរាណវិទ្យាសន្និដ្ឋានថា ត្រូវនឹងក្រុងស្រីជ័យសិង្ហបុរៈដែលបានចារឹកក្នុងប្រាសាទព្រះខ័ន ដែលព្រះបាទជ័យវរ្ម័នទី៧ទ្រង់យកព្រះពុទ្ធជ័យមហានាថទៅប្រតិស្ឋាន ដើម្បីអោយសេរីសួស្តីដល់អាណាប្រជានុរាស្ត្ររបស់ព្រះអង្គ។

ត្រូវបានសាងឡើងដើម្បីជាទីកន្លែងគោរពបូជាព្រះពុទ្ធសាសនានិកាយមហាយានដែលអាចចាតទុកបានថាជាសាសនាស្ថានព្រះពុទ្ធសាសនាមហាយានធំបំផុតនៅភាគខាងលិចប្រទេសថៃ។

តាមរយៈការស្រាវជ្រាវបានអោយដឹងថា ស្ថាបត្យកម្មនិងបដិមាកម្មគឺត្រូវនឹងសម័យព្រះបាទជ័យវរ្ម័នទី៧ ព្រមទាំងបានរកឃើញព្រះពុទ្ធរូបនាគប្រក់ ព្រះពោធិសត្វលោកេស្វារៈ និងព្រះនាងប្រាជ្ញាបារមីតា ថែមទាំងបានរកឃើញរូបពោធិសត្វលោកេស្វារៈប្លែងរស្មី (Radiating Avalokitewvra)



www.elibraryofcambodia.org

មួយអង្គដែលមានលក្ខណៈស្រដៀងគ្នា និងដែលបានរកឃើញក្នុងប្រទេសខ្មែរនិងប្រទេសវៀតណាមខាងត្បូងផងដែរ។ បច្ចុប្បន្នត្រូវបានយកទៅតម្កល់ទុកក្នុងសារៈមន្ទីរក្រុងបាងកក។

តាមរយៈសិលាចារឹកប្រាសាទព្រះខ័នដែលចារឹកដោយព្រះ វិរៈកុមារ ដែលជាព្រះរាជនិរសរបស់ព្រះបាទជ័យវរ្ម័នទី៧ ដោយចារឈ្មោះក្រុងចំនួន ២៣កន្លែងដែលព្រះបាទជ័យវរ្ម័នទី៧បានសាងទុក ក្នុងចំណោមនោះមានឈ្មោះស្រីសិង្ហបុរីដែលសន្និដ្ឋានថា ត្រូវនឹងប្រាសាទមឿងសិង្ហនេះឯង។



www.elibraryofcambodia.org

## អង្គប្រកបនៃប្រាសាទមឿងសិង្ហ

### ១ .បុរាណស្ថានទី ១



**សន្និដ្ឋាន**ថា សង់ឡើងដើម្បីថ្វាយឧទិសចំពោះព្រះពោធិសត្វលោកេស្វារៈ ក្នុងព្រះពុទ្ធសាសនាមហាយាន។ តួប្រាសាទតាំងនៅស្ទើរចំកណ្ដាលក្រុងសង់ដោយថ្មបាយក្រៀមបែរមុខទៅទិសខាងកើត។ នៅលើគ្រឹះបុរាណស្ថាននៅមានគោបុរៈ (ក្លោងទ្វារ) ថែវព័ទ្ធជុំវិញប្រាង្គប្រធានទាំង៤ មានបណ្ណាល័យសំរាប់រក្សាគម្ពីរខាងសាសនា និងកំពែង។ ក្នុងប្រាង្គប្រធានបានរកឃើញព្រះពោធិសត្វលោកេស្វារៈ និងព្រះនាងប្រាជ្ញាបារមីតា ព្រះពុទ្ធ



www.elibraryofcambodia.org

ប្រក់នាគ ថ្មបាយក្រៀមដែលជារូបគោរពបូជាក្នុងព្រះពុទ្ធសាសនានិកាយមហាយាន។

នៅព័ទ្ធជុំវិញប្រាង្គប្រធានទាំង៤ទិសផ្នែកខាងជើង និងទិសខាងត្បូងបានបាក់បែកអស់ទៅហើយ នៅសល់បន្ទប់ថ្មវិមានចំណែកទិសខាងលិចនៅគង់វង្សល្អបំផុត បច្ចុប្បន្នជាប្រតិស្ឋានរូបព្រះនាងប្រាជ្ញាបារមីតា។គោបុរៈគ្រប់ទិសមានថែវផ្លូវដើរតជាប់គ្នាមានជញ្ជាំងទាំងសងខាង។ ដំបូលប្រក់ដោយថ្មបាយក្រៀមរៀងត្រួតគ្នាជាខ្សែកោង។ ថែវដែលនៅល្អបំផុតគឺផ្នែកដែលតភ្ជាប់រវាងគោបុរៈ ទិសខាងជើងដែលមានរូបចំលាក់ព្រះពោធិសត្វលោកេស្វរៈ។



www.elibraryofcambodia.org





WWW.OKNATION.NET Photo by SHUTTERTD
© 2007 By SHUTTERTD : oil_cameraman@hotmail.com : www.oknation.net All right reserved. No part of this document may be reproduce or transmitted in any form or by any means mechanical,photocopying,recording, or otherwise, with out prior written permission of www.oknation.net

ព្រះពោធិសត្វលោកេស្វរៈ ព្រះនាងប្រាជ្ញាបារមីតា



www.elibraryofcambodia.org

# ច្រាងទ្វារ (គោបុរៈ)និងថែវ



គោបុរៈទិសខាងលិច



ថែវព័ទ្ធជុំវិញប្រាសាទ



www.elibraryofcambodia.org



បណ្ណាល័យ

## ២. បុរាណស្ថានទី២





www.elibraryofcambodia.org

តាំងនៅទិសខាងលិចឆៀងខាងជើងនៃប្រាសាទមៀងសិង្ហ សង់ដោយថ្មបាយក្រៀមប្រកប ដោយតួប្រាសាទប្រធានតាំងនៅចំកណ្ដាល មានគោបុរៈទាំង៤ទិសតភ្ជាប់ដោយថែវ។ គោបុរៈទិសខាងកើតនៅជិតប្រាសាទប្រធានជាងផ្នែកផ្សេងៗ តែថែវទិសខាងកើតនៅសល់ត្រឹមតែគ្រឹះគ្មានជញ្ជាំងនិងដំបូល។

**បុរាណស្ថានទី ៣**

តាំងនៅខាងក្រៅនៃកំពែងប្រាសាទ ជាបុរាណស្ថានទំហំតូច សង់ដោយថ្មបាយក្រៀម។

**បុរាណស្ថានទី ៤**

ជាសាសនស្ថាននៅជិតនិងសាសនស្ថានទី៣ ជាអាគាររាង៤ជ្រុង។



www.elibraryofcambodia.org

**២.២.៤ ប្រាសាទវត្តព្រះផាយហ្លួង** សព្វថ្ងៃស្ថិតនៅ ស្រុកមឿង ខេត្តសុខោទ័យភាគខាងជើងឆៀងខាងលិចក្រុងបាងកក ចំងាយប្រមាណ ៤៣០គម.។

ខេត្តសុខោទ័យ ជាអាណាខេត្តដ៏សំខាន់មួយរបស់អាណាចក្រខ្មែរបុរាណ ដូចប្រាកដអោយយើងឃើញពីបុរាណស្ថានជាច្រើនក្នុងនោះមានប្រាសាទវត្តព្រះផាយហ្លួងផងដែរ។

ប្រាសាទវត្តព្រះផាយហ្លួង តាំងនៅទិសខាងជើងនៃក្រុងសុខោទ័យ បរិវេណសាសនស្ថានព័ទ្ធជុំវិញដោយគូទឹកទំហំធំចំកណ្តាលបរិវេណមាន ប្រាសាទខ្មែរតាំងនៅដោយមានទាំងអស់៣អង្គ សង់ដោយថ្មបាយក្រៀម រៀងគ្នាពីជាជួរពីជើងទៅត្បូងបែរមុខទៅទិសខាងកើត។ សព្វថ្ងៃនៅគង់វង់ល្អចំពោះប្រាង្គទិសខាងជើង ចំណែកប្រាង្គទិសកណ្តាលនិងទិសខាងត្បូង បានបាក់បែកអស់ទៅហើយ។

ប្រាសាទទាំង៣អង្គនេះត្រូវបានសង់ឡើងតាមបែបសិល្បៈខ្មែរ រចនាបថបាយ័ន និងពេលតំបូងទំនងជាសង់ឡើងជាសាសនស្ថានព្រះពុទ្ធសាសនានិកាយមហាយាន។ ក្រោយត្រូវបានផ្លាស់ប្តូរជាជាសាសនស្ថានព្រះពុទ្ធសាសនានិកាយថេរវាទវិញ។



www.elibraryofcambodia.org

**២.២.៥ ប្រាសាទភីម៉ាយ** (Prasat Phimai) **ស្ថិតនៅស្រុកភីម៉ាយ** (Pimai District) **ខេត្តនគររាជសិមា** (Nakhonrattasima Province) តាំងនៅភាគឦសានក្រុងបាងកកដោយរយៈផ្លូវប្រមាណ៣៦០គម។ ប្រាសាទនេះអាចចាត់បានថាជាសាសនស្ថានព្រះពុទ្ធសាសនាមហាយានធំបំផុតនៅភាគឦសានប្រទេសថៃ។

ដោយប្រាសាទនេះអ្នកបុរាណវិទ្យាសន្និដ្ឋានថា ត្រូវនិងក្រុង វិមាយបុរៈ ដែលបានចារឹកក្នុងប្រាសាទព្រះខ័នដែលព្រះបាទជ័យវរ្ម័នទី៧ទ្រង់យកព្រះពុទ្ធជ័យមហានាថទៅប្រតិស្ថានដើម្បីអោយ សេរីសួស្តីដល់អាណាប្រជានុរាស្ត្ររបស់ព្រះអង្គ។



ប្រាសាទភីម៉ាយ



www.elibraryofcambodia.org

ក្រុងភីម៉ាយ ជាក្រុងដែលកសាងឡើងតាមទំរង់ប្លង់នៃសិល្បៈខ្មែរ ដែលមានលក្ខណៈជា៤ជ្រុង។ ឈ្មោះភីម៉ាយទំនងមកពីពាក្យថា វិមាយ ឬវិមាយបុរៈ ដែលប្រាកដក្នុងសិលាចារឹកភាសាខ្មែរលើផែនថ្មត្រង់ក្របទ្វារ ថែវខាងមុខប្រាសាទ។ តាមរយៈភស្តុតាងសិលាចារឹក និងស្ថាបត្យកម្មបាន បង្ហាញអោយដឹងថា ប្រាសាទភីម៉ាយទំនងជាសង់ឡើងក្នុងរជ្ជកាលព្រះបាទ សុរិយវរ្ម័នទី១ ប្រមាណពុទ្ធសតវត្សទី១៦ ក្នុងឋានៈជាទេវស្ថានគោរពបូជា ក្នុងសាសនាព្រាហ្មណ៍ក្នុងលក្ខណៈជាសិល្បៈខ្មែររចនាបថបាពួនផ្សំនិង សិល្បៈខ្មែររចនាបថអង្គរវត្ត ហើយសាសនស្ថានកន្លែងនេះត្រូវបានផ្លាស់ ប្តូរអោយទៅជាសាសនស្ថានព្រះពុទ្ធសាសនាមហាយានក្នុងរជ្ជកាលព្រះបាទ ជ័យវរ្ម័នទី៧។

ប្រាសាទភីម៉ាយនេះសង់បែរមុខទៅទិសខាងត្បូង ដែលខុសពីប្រាសាទ ខ្មែរផ្សេងៗទៀតដែលបែរមុខទៅទិសខាងកើត។ បញ្ហានេះសន្និដ្ឋានថាដើម្បី ទទួលស្វាគមន៍ផ្លូវថ្នល់ចេញពីក្រុងអង្គរធំ ដែលជារាជធានីរបស់អាណា ចក្រខ្មែរនាសម័យនោះដែលឆ្ពោះមករកប្រាសាទភីម៉ាយពីទិសខាងត្បូង។



www.elibraryofcambodia.org

# អង្គប្រកបនៃប្រាសាទភីម៉ាយ

**១. ព្រះពន្លា** តាំងនៅបរិវេណខាងមុខកំពែងផ្នែកខាងក្រៅនៅខាងស្តាំដៃផ្លូវចូលប្រាសាទជាអាគារ៤ជ្រុងទ្រវែង។ តាមរយៈទីតាំងនេះសន្និដ្ឋានថាទំនងជាទីកន្លែងសំរាកសំរាប់ព្រះមហាក្សត្រ ឬ មន្ត្រីជាន់ខ្ពស់ដែលស្តេចយាងមកប្រកបពិធីខាងសាសនា។

**២. ស្ពាននាគរាជ**



ស្ពាននាគរាជ

តាំងនៅបរិវេណផ្នែកខាងមុខផ្លូវចូលទ្វារទិសខាងត្បូងសង់ដោយថ្មភក់ មានទំរង់ជារាងជើងក្អែកទទឹង៤មែត្របណ្តោយ៣១.៧០មែត្រ។ បង្កាន់ដៃស្ពានធ្វើជាដងខ្លួននាគដែលនៅចុងបង្កាន់ដៃស្ពាន ធ្វើរូបនាគចេញក្បាលបើកពពារជារូបនាគ៧ក្បាល។ ស្ពាននេះជាចំនុចចាប់ផ្តើមក្នុងការដើរចូល



www.elibraryofcambodia.org

ទៅក្នុងសាសនស្ថានដ៏សក្តិសិទ្ធនេះហើយមានជំនឿថា ស្ពាននេះគឺផ្លូវតភ្ជាប់រវាងមនុស្សលោកនិងទេវលោកតាមលទ្ធិសាសនាឥណ្ឌូនិងព្រះពុទ្ធសាសនាមហាយាន។

### ៣. ក្លោងទ្វារនិងកំពែងកែវ



ក្លោងទ្វារគឺតាំងនៅចំពាក់កណ្តាលកំពែងទាំង៤ទិស គឺទិសខាងជើង ទិសខាងត្បូងក្លោងទ្វារនៅចំកណ្តាលកំពែងទិសខាងលិចនិងទិសខាងកើតហាក់ដូចជាខិតទៅទិសជើងបន្តិច។ ដោយទំរង់ជុំវិញក្លោងទ្វារមានលក្ខណៈជារូបជើងក្អែកពីកំពែងចូលមកផ្នែកខាងក្នុងជឿថា ជាដែននៃទេវលោកដែលជាទីកន្លែងគង់នៅនៃព្រះអទិទេព។



www.elibraryofcambodia.org

## ៤. ផាលា

កាលដោយថ្មខ្សាច់តភ្ជាប់រវាងក្លោងទ្វារទិសខាងត្បូងនៃថែវ ដែលព័ទ្ធជុំវិញប្រាសាទប្រធានដោយធ្វើផ្លូវដើរដោយលើកកំពស់ពីដីប្រមាណ១មែត្រ ចែកចែញជាពាចន្លោះទំរង់ជារាងជើងក្អែក។



ផាលាផ្លូវដើរប្រាសាទភិម៉ាយ



www.elibraryofcambodia.org

## ៥. ភ្លោងទ្វារនិងថែវ



ថែវនិងផ្នែកខាងក្នុងថែវ



www.elibraryofcambodia.org



ដោយចារឹកជាភាសាខ្មែរបុរាណសង់ដោយថ្មភក់តភ្ជាប់រវាងក្លោងទ្វារទិសខាងត្បូងនៃថែវដែលព័ទ្ធជុំវិញប្រាសាទប្រធាន ដោយចាក់ដីកំពស់ ១ម៉ែត្រ ចែកចេញជាពាចន្លោះផ្លូវដើរជារាងជើងក្អែក។

ជាអាគារសង់ដោយថ្មភក់តាំងនៅជុំវិញប្រាសាទប្រធានដោយថែវមានលក្ខណៈស្រដែងកំពែងទិសទាំង៤ដោយមានទីតាំងត្រង់និងជួរនៃក្លោងទ្វារក្រុង និងក្លោងទ្វារចូលប្រាសាទប្រធានដោយភស្តុតាងសំខាន់កន្លែងក្លោងទ្វារទិសខាងត្បូងបរិវេណក្របទ្វារ ចារឹកភាសាខ្មែរបញ្ជាក់សករាជត្រូវនិងពុទ្ធសករាជ១៦៥១_១៦៥៥ដោយចារពីការផ្សើរបគោរពការសាងក្រុងរហូតដល់ព្រះនាមនាហ្មឺនជាន់ខ្ពស់ និងព្រះនាមព្រះមហាក្សត្រ គឺព្រះបាទធរណេន្ទ្រវរ្ម័នទី១។



www.elibraryofcambodia.org

### ៥. ប្រាសាទប្រធាន



ប្រាសាទប្រធានប្រាសាទភីម៉ាយ

ដែលជាផ្នែកសំខាន់បំផុតនប្រាសាទភីម៉ាយជាប្រាសាទអង្គធំសង់ឡើង ប្រហែលពុទ្ធសតវត្សទី១៦_១៧ដោយសាងឡើងដោយថ្មភក់ពណ៌សរ បែរមុខទៅទិសខាងត្បូងដែលខុសផ្នែកពីប្រាសាទខ្មែរផ្សេងៗទៀតដែលរំមែងបែរមុខទៅទិសខាងកើត។ ប្រាសាទប្រធានប្រកបដោយផ្នែកសំខាន់២ផ្នែក គឺកំពូលនិងវិមាន។ ដោយមានឆ្លាក់ជាក្បាច់ចំលាក់និទានរឿងផ្សេងៗដូចជាហោជាងថ្មីមមានឆ្លាក់ជារឿងនិទានរឿងរាមកេរ និងរឿងក្នុងព្រះពុទ្ធសាសនា លើកលែងទិសខាងត្បូងឆ្លាក់ជារូបសិវនាដរាជ។ ចំណែកក្នុង



www.elibraryofcambodia.org

វិមានជាផ្នែកសំខាន់បំផុតដែលជាកន្លែងប្រតិស្ឋានរូបគោរពសំខាន់ផ្ទៃបន្ទប់ មុខទិសខាងកើតឆៀងខាងជើងមានស្នាកស្នាមទឹកដែលសន្និដ្ឋានថា ជាទឹកសំរាប់ប្រកបពិធីកម្មខាងសាសនា។

## ៦. ប្រាង្គដែង



សង់ទេឡើងប្រមាណពុទ្ធសតវត្សទី១៧ តាំងនៅខាងឆ្វេងនៃប្រាសាទប្រធានមានមុខចេញទៅទិសទាំង៤លើក្របទ្វារចូលទិសខាងជើងមានផ្ទឹមថ្មភក់ឆ្លាក់និទានរឿងមហាកាព្យមហាភារតះត្រង់កណ្ដុះដេញជ្រូកព្រៃ។



www.elibraryofcambodia.org

## ៧. រោងព្រាហ្មណ៍

ជាអាគារសង់ដោយថ្មភក់និងថ្មបាយក្រៀមតាំងនៅលើគ្រឹះជាមួយគ្នានិងប្រាង្គដែង។ នៅពុទ្ធសករាជ២៤៩៣បានរកឃើញសិវលិង្គឆ្លាក់ដោយថ្មភក់ចំនួន៧ដែលនាំអោយជឿថា អាគារនេះទំនងជាទីកន្លែងប្រកបពីធិខាងសាសនាព្រាហ្មណ៍ តែរូបបែបនៃទីតាំងដើមទំនងជាណ្ណាល័យច្រើនជាង។

## ៨. ប្រាង្គព្រហ្មណ៍ទត្ត





www.elibraryofcambodia.org




រូបព្រះបាទជ័យវរ្ម័នទី ៧ ក្នុងប្រាសាទភិមាយ

លក្ខណៈនៃប្រាង្គនេះឡើងដោយថ្មបាយក្រៀម តាំងនៅខាងមុខប្រាសាទប្រធានពីទិសខាងកើត។ ជ្រារាង៤ជ្រុងទ្រវែងទ្វារធ្វើជាមុខឈរចេញទៅទិសទាំង៤។ ផ្នែកខាងក្នុងប្រាង្គបានរកឃើញបដិមាកម្ម២ គឺបដិមាកម្មរូបបុគ្គលខ្នាតធំក្នុងឥរិយាបថសមាធិឆ្លាក់ដោយថ្មបាយក្រៀមដែលសន្និដ្ឋានថា ជារូបព្រះបាទជ័យវរ្ម័នទី៧ ចំណែកមួយទៀតជារូបស្ត្រីអង្គុយលិតជង្គង់ឆ្លាក់ដោយថ្មភក់ចំណែកដៃ និងសិរសៈបានបាត់បង់ទៅហើយ ដែលជឿថាជារូបព្រះនាងជ័យរាជទេវីដែលជាអគ្គមហេសីរបស់ព្រះបាទ ជ័យវរ្ម័នទី៧។



www.elibraryofcambodia.org

### ២.២.៦ ព្រាង្គដែង

ក្រៅពីបុរាណស្ថានដ៏ធំស្កឹមស្កៃដូចដែលបានលើកឡើងខាងលើ នៅមានសាសនស្ថានព្រះពុទ្ធសាសនានិកាយមហាយានមួយទៀត។ ប្រាសាទនេះមានទំហំតូចតែក៏មានសារៈសំខាន់ផងដែរព្រោះ មានតែមួយកន្លែងតែប៉ុណ្ណោះនៅភាគឦសានប៉ែកខាងជើងប្រទេសថៃ។ ប្រាសាទនេះតាំងនៅស្រុកណាដូន (NadounDistrisct) ខេត្តមហាសារាខាម (Mahasara-kam Province) ដោយនៅចំងាយពីក្រុងបាងកកទៅទិសឦសានប្រមាណជាង៥៥០គម.។






www.elibraryofcambodia.org




រូបព្រះពោធិសត្វ (ផ្ទឹមប្រាសាទបានដែង)



www.elibraryofcambodia.org

## ៣.ព្រះបាទជ័យវរ្ម័នទី ៧ និងវិស័យសុខាភិបាល

វិស័យសុខាភិបាលជាវិស័យដ៏ចំបងមួយសំរាប់ព្យាបាលរោគដល់ប្រជារាស្ត្រ ព្រោះថាមិនថាប្រទេសណានោះទេការអភិវឌ្ឍន៍រីកចំរើនទៅមុខបានលុះត្រាតែប្រជារាស្ត្រមានកាយសម្បទាមាំមួន។

ចំណែកប្រទេសខ្មែរនាសម័យព្រះបាទជ័តវរ្ម័នទី៧ ជាសម័យកាលមួយដែលអាណាចក្រខ្មែរមានការរីកចំរើនគ្រប់វិស័យ ក្នុងនោះវិស័យសុខាភិបាល ជាវិស័យមួយដែលត្រូវបានព្រះអង្គយកព្រះទ័យទុកដាក់បំផុតដើម្បីជាទីកន្លែងសំរាប់ព្យាបាលជំងឺជូនប្រជារាស្ត្ររបស់ព្រះអង្គ។

តាមរយៈប្រភពអត្ថបទសិលាចារឹកបានអោយយើងដឹងថា ព្រះអង្គបានកសាងមន្ទីរពេទ្យនៅគ្រប់ខេត្តក្រុងក្នុងអាណាចក្រខ្មែរនាសម័យនោះមានចំនួន១០២កន្លែង។

តាមរយៈអត្ថបទសិលាចារឹកបានប្រាប់យើងអោយដឹងថា មន្ទីរពេទ្យដែលព្រះអង្គបានសាងឡើងនោះមានពីរផ្នែកនៅជាមួយគ្នាគឺ អាគារឬ ការិយាល័យដែលប្រើជាទីកន្លែងធ្វើការរបស់ពេទ្យ ដូចជាការស្នាក់នៅនឹងកន្លែងជូនព្យាបាលជំងឺបជារាស្ត្រនិងមួយគឺសាសនស្ថាន ឬព្រះវិហារប្រចាំមន្ទីរពេទ្យដែលសព្វថ្ងៃយើងនិយមហៅថាប្រាសាទ។ តែតាមពិតសាសនស្ថាននេះ ជាទីកន្លែងសំរាប់តម្កល់ព្រះពោធិសត្វភៃសជ្ជយគុរុដែលជាគ្រូពេទ្យទិព្វតាមទស្សនៈព្រះពុទ្ធសាសនាមហាយាន។ ចំណែកអាគារ ឬការិយាល័យសំរាប់ព្យាបាលជំងឺនោះទំនងសង់ដោយឈើ បើយើងរាប់ឆ្នាំ



www.elibraryofcambodia.org

ដែលសង់គឺប្រមាណ១១៨៣មកដល់សព្វថ្ងៃ(២០១១) ឃើញថាពេលវេលាកន្លងមកជាង៨០០ឆ្នាំហើយ ពុំមានសេសសល់នៅអោយយើងឃើញទៀត។ តែយើងអាចឃើញតែដីទួលជុំព្រះវិហារ និងស្រះទឹកហើយដីទួលនេះហើយទំនងជាទីតាំងនៃអាគារទាំងនេះ។

អ្នកស្រាវជ្រាវខ្លះសន្និដ្ឋានថា អាគារសំរាប់ព្យាបាលអ្នកជំងឺនេះទំនងជាសង់នៅទិសអាគ្នេយ៍ជិតស្រះទឹក។

តែសំរាប់អ្នករៀបរៀងវិញសន្និដ្ឋានថា អាគារទាំងទំនងជាសង់នៅជុំវិញព្រះវិហាររបស់ព្រះពោធិសត្វភេសជ្ជយគុរុ ព្រោះតាមរយៈសិលាចារឹកបានប្រាប់យើងថា បុគ្គលិកដែលបំរើការងារនៅតាមមន្ទីរពេទ្យនីមួយៗមានច្រើនរហូតដល់ជាង៩០នាក់។

ក្នុងឱកាសសេសេរអត្ថបទច្បាប់នេះ អ្នករៀបរៀងបានចុះទៅសិក្សាដល់ទីកន្លែងផ្ទាល់ហើយសង្កេតឃើថា បរិវេណមន្ទីរពេទ្យនីមួយៗមានទំហំធំខ្លះមានទំហំដល់១ហិចតាទៅ៣ហិចតា។

ម្យ៉ាងទៀតដូចដែលយើងបានជ្រាបស្រាប់ហើយក្រោយពីរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧អាណាចក្រខ្មែរចាប់ផ្តើមស្រុតចុះ ហើយក្រោយមកត្រូវបានបែងចែកជាច្រើនប្រទេសហើយសព្វថ្ងៃគឺប្រទេស ខ្មែរ ថៃ ឡាវ និងវៀតណាមខាងត្បូង។ ចំពេលជាមួយគ្នានេះសាសនាដើមដែលធ្លាប់គោរពគឺសាសនាព្រាហ្មនិងព្រះពុទ្ធសាសនា និកាយមហាយានត្រូវបានប្រជារាស្ត្រប្រទេសទាំងនេះឈប់និយម ហើយបែរមកគោរពដោយសាសនាថ្មី គឺ



www.elibraryofcambodia.org

ព្រះពុទ្ធសាសនានិកាយថេរវាទជំនួសវិញ។ មនុស្សក៏កាន់ច្រើនធ្វើអោយសង់វត្តអារាមក៏កាន់ច្រើនដោយសាសនាគឺជាវត្ថុស័ក្តិសិទ្ធ ហើយបរិវេណមន្ទីរពេទ្យដែលនៅសល់ព្រះវិហារព្រះពោធិសត្វដែលជាសក្ការៈរបស់គេៗមកក៏បានយកបរិវេណនេះមកសាងវត្តអារាមព្រះសាសនានិកាយថេរវាទជំនួសវិញ។ ដោយខ្វះការយល់ដឹងវត្តអារាមខ្លះបានយករុះរើយកព្រះវិហារប្រចាំមន្ទីរពេទ្យមកធ្វើជាកុដិ ឬព្រះវិហារ។ ម្យ៉ាងទៀតវត្តអារាមខ្លះបានសង់សាសនស្ថានដូចព្រះវិហារ សាលាឆាន់ ជាដើមពីលើព្រះវិហារប្រចាំមន្ទីរពេទ្យចាស់ៗ។ ដូចនៅវត្តឈ្មោងខេត្តសុរិន្ទ្រប្រសទេសថៃ គេបានសង់ព្រះវិហារសង្កត់ពីលើគ្រឹះដែលជាគ្រឹះព្រះវិហារប្រចាំមន្ទីរទេព្យ។ ម្យ៉ាងទៀតនៅមុនគឺមិនទាន់មានច្បាប់សំរាប់ការពារសាសានស្ថានទាំងនេះ សាសនស្ថានទាំងនេះបានទទួលរងនូវការបំផ្លិញបំផ្លាញរបស់មនុស្សដូចជាការជីកគាល់រកកំណប់ទ្រព្យផ្សេងៗ ដែលជាហេតុនាំអោយសាសនស្ថានទាំងនេះដួលរលំនិងបាក់បែកយ៉ាងធ្ងន់ធ្ងរ។ ជាហេតុនាំអោយសាសនស្ថានប្រចាំមន្ទីរទេព្យមួយចំនួនត្រូវបានវិនាសបាត់បង់អស់។



www.elibraryofcambodia.org





ព្រះវិហារវត្តឈ្នាង ខេត្តសុរិន្ទ្រ បានសង់សង្កត់គ្រឹះព្រះវិហារប្រចាំមន្ទីរ



www.elibraryofcambodia.org

ការកសាងមន្ទីរពេទ្យទាំង១០២កន្លែងនេះចាត់ទុកជាសមិទ្ធផល ដ៏ធំធេងមួយក្នុងរជ្ជកាលរបស់ព្រះអង្គ ហើយព្រះរាជករណីកិច្ចដ៏ថ្លៃថ្លានេះត្រូវបានលោក L.Finot នាយកវិទ្យាស្ថានបារាំងបូព៌ាបានកំចាត់សេចក្តីងងឹតទាក់ទងនិងរឿងនេះអោយបានភ្លឺស្វាង និងបានបង្ហាញពីឥទ្ធិពលដ៏ខ្លាំងក្លារបស់ព្រះអង្គអោយកាន់ច្បាស់ឡើង។

តើហេតុផលអ្វីដែលជំរុញព្រះទ័យរបស់ព្រះបាទជ័យវរ្ម័នទី៧ អោយទ្រង់យកព្រះទ័យទុកដាក់ចំពោះវិស័យសាធារណៈសុខពាសពេញរាជអាណាចក្រ ដែលស្មើរដោយសមិទ្ធផលកសាងដែលបង្ហាញជាពុទ្ធរាជារបស់ព្រះអង្គ ?។

ក្នុងបញ្ហានេះលោក **G.Codés** បុរាណវិទ្យាជនជាតិបារាំងបានតាំងការសន្និដ្ឋានដោយអាស្រ័យរឿងការស្តេចស្វែងរកបុណ្យរបស់ព្រះរាជាដែលកើតរោគឃ្លង់។ និងរូបចំលាក់នៅលើហោជាងរបស់ព្រះវិហារប្រចាំមន្ទីពេទ្យដែលតាំងនៅទិសខាងកើតប្រាសាទតាកែវក្នុងក្រុងអង្គរ ដែលរូបភាពដូចពោលមកនេះដូចគ្នានិងរូបភាពក្នុងប្រាសាទបាយ័ន។

លោក P.Mus បុរាណវិទូជនជាតិបារាំងបានអធិប្បាយនូវរូបភាពនេះថា ជារូបភាពពីពណ៌នាអំពីការព្យាបាលរោគឃ្លង់។ និងក្នុងចំណោមមនុស្សដែលកំពុងធ្វើការព្យាបាលមានបុគ្គលម្នាក់កាន់ភាជនៈដាក់ផ្លែឈើគ្រាប់តូចៗដែលសន្និដ្ឋានថា ជាផ្លែក្របៅដែលប្រើសំរាប់ព្យាបាលរោគឃ្លង់តាមក្បួនឱសថបុរាណ។



www.elibraryofcambodia.org

ដូចនេះលោក G.Codés បានសន្និដ្ឋានថាហេតុផលដែលព្រះបាទជ័យវរ្ម័នទី៧ទ្រង់ស្ថាបនាមន្ទីរពេទ្យទូទាំងរាជអាណាចក្រអាចព្រោះព្រះអង្គទ្រង់សង្ឃឹមថា ការបំពេញព្រះរាជកុសលពេលនេះ និងញាំងអោយព្រះអង្គឬព្រះរាជវង្សានុវង្សរបស់ព្រះអង្គដែលទ្រង់ប្រឈួនដោយឃ្លង់ទ្រង់បានជាសះស្បើយពីរោគដ៏កាចកាហាវនេះ ពោលគឺរោគឃ្លង់នេះឯង។

តែក្នុងបញ្ហានេះ **អ្នករៀបរៀងយល់ថា** ទោះបីរូបចំលាក់និទានរឿងដូចពោលខាងលើជារូបភាពដែលបង្ហាញពីរក្សាឃ្លង់តាមដែលការសន្និដ្ឋានទុកក៏ពិតមែន តែរូបភាពនេះអាចជារូបភាពប្រចាំថ្ងៃរបស់មន្ទីរពេទ្យ ដែលត្រូវព្យាបាលរោគឃ្លង់ដល់អ្នកជំងឺ។ ដោយមិនចាំបាច់ត្រូវទាក់ទង និងព្រះបាទជ័យវរ្ម័នទី៧ ឬព្រះរាជវង្សានុវង្សរបស់ព្រះអង្គនោះទេ។

ជាពិសេសបំផុតបើយើងគិតតាមសភាពការពិតការសម្តែងរូបភាពទាក់ទង និងព្រះរាជជីវប្រវត្តិរបស់ព្រះបាទជ័យវរ្ម័នទី៧គួជាលក្ខណៈការលើកដំកើនព្រះកិត្តិយសរបស់ព្រះអង្គដោយគេមិនគួរសំដែងរូបភាពចំពេលដែលព្រះអង្គកំពុងទទួលទុក្ខវេទនា ដោយរោគដ៏កាចសាហាវដែលសង្គមកំពុងតែស្អប់ខ្ពើមនោះទេ។

ម្យ៉ាងទៀតរូបំលាក់និទានរឿងជីវិតប្រចាំថ្ងៃ របស់ប្រជារាស្ត្រខ្មែរសាមញ្ញក៏ប្រាកដអោយយើងឃើញតាមថែវប្រាសាទបាយ័ន ដែលមានអាយុរួមសម័យនិងការស្ថាបនាសាសនស្ថានប្រចាំមន្ទីរផងដែរ។



www.elibraryofcambodia.org

ម្យ៉ាងទៀតតាមរយៈការកត់ត្រារបស់លោកជីតាក្វាន់ ដែលបានធ្វើដំណើរមកជាមួយអ្នករាជទូតចិនក្នុងពុទ្ធសករាជ១៨៣៩ គ្រិស្តករាជ១២៩៦ ក៏បានកត់ត្រាថា នាអតីតាលក៏ធ្លាប់មានព្រះរាជាខ្មែរប្រឈួនដោយរោគឃ្លង់ តែលោកក៏មិនបានបញ្ជាក់ថា ជាព្រះបាទជ័យវរ្ម័នទី៧ ឬព្រះរាជាអង្គណាមួយនោះទេ។

ដូចនេះរឿងព្រះរាជាខ្មែរដែលប្រឈួនដោយឃ្លង់អាចត្រឹមជារឿងនិទាន ដែលប្រជារាស្ត្រខ្មែរនិយាយអោយលោកជីតាក្វាន់ស្តាប់អោយសម្បាយមាត់តែប៉ុណ្ណោះ ដូចគ្នានិងមានរឿងដែលថាព្រះរាជាខ្មែរនិងត្រូវស្តេចខ្មែរយាងទៅផ្ទំជាមួយនាងនាគលើប្រាសាទវិមានអាកាស ក៏មាននៅក្នុងការកត់ត្រារបស់លោកជីវតាក្វាន់ផងដែរ។

ដូចនេះភស្តុតាងដែលប្រាប់យើងអំពីព្រះរាជគោលបំណងរបស់ព្រះបាទជ័យវរ្ម័នទី៧ ក្នុងការស្ថាបនាមន្ទីរពេទ្យអោយបានល្អបំផុតនោះគឺ ខ្លឹមសារដែលមានក្នុងសិលាចារឹកប្រចាំមន្ទីរពេទ្យត្រង់គាថាទី១៣ និងគាថាទី៤៦ ដែលមានសេចក្តីថា **«រោគតាមរាងកាយរបស់ព្រះជារាស្ត្រនេះជារោគខាងផ្លូវចិត្តដែលមានសេចក្តីឈឺចាប់ខ្លាំងណាស់ ទោះបីមិនមែនសេចក្តីទុក្ខរបស់ព្រះអង្គ តែជាសេចក្តីទុក្ខសំរាប់អ្នកគ្រប់គ្រង» «ព្រះរាជាទ្រង់បានប្រាថ្នាសេចក្តីល្អនិងប្រយោជន៍ដ៏ធំធេងដល់សត្វលោក ព្រះអង្គបានពោលនូវពាក្យបដិជាននេះម្តងទៀតថា ព្រះអង្គនិងជួយស្រោច**



www.elibraryofcambodia.org

**ស្រង់សត្វលោកដែលលិចលង់ក្នុងមហាសមុទ្រអោយរួចផុត ដោយអំពើល្អរបស់ព្រះអង្គ»។**

ដូចនេះ ការដែលព្រះអង្គទ្រង់បានបំពេញព្រះរាជករណីដ៏ថ្លៃថ្លានេះ គឺមូលហេតុដែលព្រះអង្គកំពុងបំពេញពោធិសត្វបារមី ដែលជួយសង្គ្រោះសព្វសត្វក្នុងលោកអោយផុតទុក្ខតាមទស្សនៈព្រះពុទ្ធសាសនាមហាយាន ឬអាចតាមដែលលោក **L.Finot** សន្និដ្ឋានថា ព្រះបាទជ័យវរ្ម័នទី៧ទ្រង់ប្រតិបត្តិព្រះអង្គជាធម៌រាជាដូចព្រះបាទអសោកមហារាជនៃប្រទេសឥណ្ឌា ធ្លាប់ប្រតិបត្តិក្នុងអតិតកាល។



www.elibraryofcambodia.org

### ៣.១ អង្គប្រកបនៃមន្ទីរពេទ្យ

បណ្ដាមន្ទីរពេទ្យទាំងអស់នោះមានអង្គប្រកបដូចៗគ្នាទាំងអស់គឺ ពោលគឺ÷

**១. ចារឹកប្រចាំមន្ទីរពេទ្យ**

ចារឹកដែលរកឃើញក្នុងមន្ទីរពេទ្យបែងចែកបានពីរចំណែក

**១. ចារឹកលើវត្ថុស័រិតដែលឧទិសថ្វាយចំពោះមន្ទីរពេទ្យ**



ចារឹកលើគ្របពានប្រចាំមន្ទីរពេទ្យក្រុងស្រីមហាសថ ខេត្តប្រាជីនបុរី ប្រទេសថៃ សព្វថ្ងៃតម្កល់ទុកក្នុងសារមន្ទីរជាតិក្រុងបាងកក



www.elibraryofcambodia.org

## ១. ចារឹកលើវត្ថុសំរិតដែលឧទិសថ្វាយចំពោះមន្ទីរពេទ្យ

វត្ថុសំរិតនេះជាការចារឹកជាអត្ថបទខ្លីៗជាភាសាខ្មែរបុរាណបញ្ជាក់ឆ្នាំដែលសម្ភោធឧទិសថ្វាយវត្ថុទាំងនោះចំពោះមន្ទីរពេទ្យដូចជាគ្របផ្ទិលសំរិតដែលបានរកឃើញពីប្រាសាទគោកប្រាសាទ (Prasat Kukprasat) ខេត្តបុរីរម្យ៍ (Buriram Province) និងគ្រឿងសំរិតពីបរិវេណបុរាណស្ថានក្រុងស្រី មហាសថ ខេត្តប្រាជីនបុរី ប្រទេសថៃ។

តាមរយៈចារឹកលើវត្ថុសំរិតធ្វើអោយយើងសន្និដ្ឋានបានថា÷

១.១ មន្ទីរពេទ្យនិមួយៗគ្មានឈ្មោះ ជាលក្ខណៈចំពោះតែឈ្មោះមន្ទីរពេទ្យដាក់តាមឈ្មោះខេត្តក្រុង ដែលជាកន្លែងទីតាំងរបស់មន្ទីរទាំងនោះ។ ដូចជាមន្ទីរនៃវីរេន្ទ្របុរៈ (K.៩៧៣) មន្ទីរពេទ្យ នៃអវធ្យបុរៈ និងមន្ទីរទេព្យនៃសង្វោក ជាដើម។

១.២ ក្នុងការប្រកបពិធីកម្មដែលព្រះបាទជ័យវរ្ម័នទី៧ ដែលទ្រង់សម្ភោធដាក់អោយប្រើប្រាស់នៃមន្ទីរទេព្យនីមួយៗមិនបានធ្វើឡើងក្នុងពេលជាមួយគ្នានោះទេ ទាំងនេះព្រោះសករាជដែលប្រាកដមានលើផ្ទសំរិត ពីប្រាសាទស្រីមហោសថគឺមហាសករាជ ១១១៥ (ពុទ្ធសករាជ១៧៣៦) តែសករាជលើគ្របផ្ទិលពីប្រាសាទគោក ប្រាសាទគឺមហាសករាជ ១១២៣ (ពុទ្ធសករាជ១៧៤៤) ការដែលសករាជក្នុងការបញ្ជាក់ពីការសម្ភោធអោយប្រើប្រាស់តាមមន្ទីរពេទ្យនីមួយៗមិនគ្នាដូចនេះអាច សន្និដ្ឋានបានថា មន្ទីរពេទ្យចាប់បើកអោយប្រើប្រាស់ក្នុងការប្រកប ពិធីកម្មពិតប្រាកដក្នុងឆ្នាំ



www.elibraryofcambodia.org

ដែលបានចារឹកទុកនោះ។

## ២. សិលាចារឹកលើថ្មភក់រាងបួនជ្រុងទ្រវែង




សិលាចារឹកប្រចាំមន្ទីរប្រភាជ័យខេត្តខនកេន បច្ចុប្បន្នដំកល់ទុកសារមន្ទីរជាតិ ខេត្តខនកេន ប្រទេសថៃ

ចារឹកជាអក្សរខ្មែរបុរាណពុទ្ធសតវត្សទី១៨ដោយខ្លឹមសារក្នុងសិលាចារឹកនិពន្ធចងក្រងឆន្ទជាភាសាសំស្ក្រឹតចំនួនឆន្ទក្នុងសិលាចារឹក កន្លែងនីមួយៗមិនស្មើរគ្នា ដូចជាសិលាចារឹកប្រាសាទពោនរះយ៉ង (Prasat Ponrachang) ខេត្តរយអិត (Roiet Province) មានឆន្ទចំនួន ៤៤ គាថាសិលាចារឹកប្រាសាទតាមាន់តូច (Prasat Tameantoc)ខេត្តសុរិន្ទ្រ



www.elibraryofcambodia.org

(Surin Province) មានចំនួន៤៤គាថា សិលាចារឹកប្រាសាទសាយហ្វង (PrasatSayfon) (K.៣៦៨) ក្រុងវៀងចន្ទប្រទេសទឡាវ និងសិលាចារឹក ប្រាសាទប្រខាំ (Prasat Pracham) (K.៣៨៦) ខេត្ត បុរីរម្យ៍ មានចំនួន៤៨ សិលាចារឹកប្រាសាទគួគន្ធនាម (Prasat Kuchanthanam) ខេត្តរយអិត (Roiet Province) សិលាចារឹកពីស្រុកប្រាសាទ ខេត្តសុរិន្ទ្រសិលាចារឹក ប្រាសាទភីម៉ាយខេត្តនគររាជសីមា (K.៩៥២) សិលាចារឹកប្រាសាទតាកែពង (K.២០៩) ខេត្តបាត់ដំបងសិលាចារឹកតោករោក (K.៤៣៥) ខេត្តកំពុងធំ និងសិលាចារឹកប្រាសាទបន្ទាយភ្លើង ខេត្តកំពុងធំ (K.៦៦៧) មានចំនួនឆន្ទ៤៩គាថា ចំណែកសិលាចារឹកពីមន្ទីរទេព្យនៅទិសខាងកើតប្រាសាទតាកែវ (K.៥៣៧) មានចំនួនឆន្ទរហូតដល់៥៩គាថា។

មូលហេតុដែលសិលាចារឹកប្រចាំមន្ទីរពេទ្យនីមួយៗ មានចំនួនឆន្ទមិនស្មើរគ្នាដូចច្នេះព្រោះថា ខ្លឹមសារនៃសិលាចារឹកប្រចាំមន្ទីរប្រកបដោយខ្លឹមសារពីរ។ ផ្នែកគឺ ÷

ផ្នែកទី១គាថាទី១១-៨ មានអត្ថន័យដូចគ្នាគ្រប់ទីកន្លែងដោយចាប់ផ្តើមការសម្តែងការវន្ទាចំពោះព្រះពុទ្ធជាម្ចាស់ និងនមស្សការព្រះភៃសជ្យគុរុវៃទូរ្យដែលជាមង្គលនាមក្នុងការការពាររោគ។ព្រះស្រីសូរ្យវៃរោចនចន្ទរោចិ និងព្រះស្រីចន្ទ្រវៃរោហិណីសៈ ជាអ្នកមានបារមីអាចកំចាត់រោគបាន និងនិយាយអំពីព្រះបាទជ័យវរ្ម័នទី៧ ជាព្រះឱរសរបស់ព្រះបាទធរណីន្ទ្រវរ្ម័នថាបានទទួលរាជ្យសម្បត្តិជាព្រះរាជាដែលមានភាពខ្លាំងពូកែក្នុងការចំបាំង



www.elibraryofcambodia.org

ជាទីកោតខ្លាចរបស់ព្រះរាជានគរជិតឆ្ងាយទាំងឡាយ។ ជាព្រះរាជាដែលមានរូបសម្រស់ដ៏ល្អបវរដូចកាមទេព ជាព្រះរាជាដែលមានចិត្តមេត្តាធម៌រហូតក្លាយជាស្រលាញ់របស់ ប្រជារាស្ត្រទូទៅសូម្បីតែសត្រូវរបស់ព្រះអង្គក៏គោរពព្រះអង្គបានផងដែរ។ ព្រះអង្គបាននាំសេចក្ដីរុងរឿងដល់ព្រះនគរដោយកំចាត់សេចក្ដីទុក្ខលំបាកនិងរោគភ័យរបស់ប្រជារាស្ត្រ ដែលចាត់ទុកបានថា ព្រះអង្គបានកំចាត់ក្លិយុគអោយទៅជាភទ្រយុគបានយ៉ាងពិតប្រាកដ

ផ្នែកទី២ ជាបញ្ជីរឈ្មោះរបស់របរនិងចំនួនអ្នកបំរើការប្រចាំមន្ទីរទេព្យ ដែលមន្ទីរពេទ្យនីមួយៗមានចំនួនមិនស្មើរគ្នាដូចនេះបើមន្ទីរពេទ្យណាមានទំហំធំធ្វើអោយចំនួនឆន្នក្នុងសិលាចារឹកមានចំនួនច្រើនទៅតាមផងដែរ ដូចនេះយើងសង្កេតឃើញថា មន្ទីរពេទ្យដែលតាំងក្នុងក្រុងអង្គរមានចំនួនឆន្នរហូតដល់៥៩ គាថា។

## ខាងក្រោមនេះ ជាសេចក្ដីប្រែរបស់សិលាចារឹកប្រាសាទ

សិលាប្រាសាទជាសិលាចារឹកប្រចាំមន្ទីរទេព្យ ដែលមានលក្ខណៈដូចគ្នានិងសិលាចារឹកប្រចាំមន្ទីរទេព្យផ្សេងៗក្នុងអាណាចក្រខ្មែរសម័យបុរាណ ដែលបច្ចុប្បន្នត្រូវគេរកឃើញនៅក្នុងប្រទេសខ្មែរថៃ និងប្រទេសឡាវនិងប្រទេសវៀតណាមខាងត្បូង។

សិលាចារឹកប្រាសាទត្រូវរកឃើញក្នុងស្រុកប្រាសាទខេត្តសុរិន្ទ្រ ប្រទេសថៃ ដោយសិលាចារឹកមានលក្ខណៈដូចខាងក្រោមនេះ÷



www.elibraryofcambodia.org

| | |
|---|---|
| អក្សរ | អក្សរខ្មែរបុរាណ |
| ភាសា | សំស្រ្កឹត |
| សករាជ | ពុទ្ធសតវត្សទី ១៨ |
| ខ្នាត | ទទឹង ៣១.៥ សម |
| | កំពស់ ៧៨ សម |
| | កំរាស់ ៣០.៥ សម |
| អក្សរចារឹក | មាន ៤ ផ្នែក |
| | ផ្នែកទី ១ មាន ២៤ បន្ទាត់ |
| | ផ្នែកទី ២ មាន ២៤ បន្ទាត់ |
| | ផ្នែកទី ៣ មាន ២៤ បន្ទាត់ |
| | ផ្នែកទី ៤ មាន ២៦ បន្ទាត់ |
| វត្ថុចារឹក | ថ្មខ្សាច់ល្បិត |

លក្ខណៈជាកំណាត់ថ្មរាងបួនជ្រុងទ្រវែងខាងចុងរាបក្រចោមទីកន្លែងរកឃើញស្រុកប្រាសាទខេត្តសុរិន្ទ្រ បច្ចុប្បន្នតម្កល់ទុកក្នុងមន្ទីរបិតិកភណ្ឌ ក្រុងបាងកក ប្រទេសថៃ។



www.elibraryofcambodia.org

## ខ្លឹមសារនៃសិលាចារឹកប្រាសាទ

គាថាទី១ សូមបង្គំវន្ទាចំពោះព្រះពុទ្ធជាម្ចាស់អ្នកមាននិរមាណកាយ ធម៌កាយ និងសម្ភោគកាយព្រះអង្គរួចផុតពីភាវៈនិងអភាវៈទាំងពីរព្រះអង្គ ទ្រង់មានអាត្មន៍ពីរព្រះអង្គជាងអ្នករកអាត្មន៍ពុំបាន។

គាថាទី២ ខ្ញុំម្ចាស់សូមនមស្សការព្រះជិនៈព្រះអង្គជារាជានៃរស្មីគឺ ព្រះពុទ្ធភៃសជ្ជវៃឌូរ្យប្រភា ព្រោះព្រះអង្គទើបកើតសេចក្តីក្សេមក្សាន្ត និង សេចក្តីមិនមានរោគដល់ប្រជារាស្ត្រអ្នកស្តាប់សូម្បីតែឈ្មោះ។

គាថាទី៣ ព្រះស្រីសូរ្យវៃរោចនៈចន្ទរោចិ និងព្រះស្រីចន្ទ្រវៃរោចនៈរោហិណីសៈអ្នកកំចាត់សេចក្តីងងឹតគឺរោគរបស់ប្រជារាស្ត្រ សូមអោយឈ្នះឯជើងភ្នំគឺព្រះពុទ្ធជាម្ចាស់។

គាថាទី៤ មានស្តេចផែនដីព្រះនាមថា ស្រីជ័យវរ្ម័ន (ព្រះបាទជ័យវរ្ម័នទី៧) ព្រះអង្គជាឱរសរបស់ព្រះបាទស្រីធរណីន្ទ្រវរ្ម័ន ព្រះអង្គប្រសូត្រចេញពីព្រះនាងនៃក្រុងជយាទិតយបុរៈ ព្រះអង្គបានទទួលរាជសម្បត្តិព្រោះព្រះចន្ទដ៏ភ្លឺថ្លាលើផ្ទៃមេឃគឺព្រះវេទ។

គាថាទី៥ ព្រះអង្គទ្រង់មានព្រះបាទដូចផ្កាឈូកជាគ្រឿងប្រដាប់លើព្រះសិរសារបស់ព្រះរាជាទាំងអស់ ព្រះអង្គមានសត្រូវដែលព្រះអង្គទ្រង់ឈ្នះហើយក្នុងសង្គ្រាមបានទទួលហើយនូវស្ត្រីគឺផែនដីជាអ្នកនាំនូវព្រះកិត្តិយសរបស់ព្រះអង្គ ព្រះអង្គមានរតនៈគឺសេចក្តីល្អជាគ្រឿងប្រដាប់។



www.elibraryofcambodia.org

គាថាទី៦ ព្រះអង្គមានផ្លូវទឹកគឺទាន ដែលព្រះអង្គបានបន្ថែមអោយហើយដោយសេចក្តីភ្លើតភ្លើនក្នុងកាលគ្រប់ពេល ព្រះអង្គស្តុកស្តម្ភដោយទ្រព្យសម្បត្តិគឺទាននិងសេចចំរើនក្តីរុងរឿងទ្រង់ជាទីស្រលាញ់នៃសត្រូវរបស់អទិទេពដែលព្រះអង្គទ្រង់អោយលំបាកហើយដោយគ្រឿងដង្វាយទោះបីដូចព្រះក្រឹស្ណះតែមានវណ្ណៈស។

គាថាទី៧ ព្រះអង្គញ៉ាំងនាងលក្សីដែលព្រះរាជាទាំងឡាយប្រាថ្នាហើយដែលបានដោយកម្រនូវអ្នកទ្រទ្រង់ឧបេក្ខា ដែលចូលមកជិតហើយនិងញ៉ាំងនាងកីរតី អ្នកលេងទៅទិសទាំងឡាយអោយត្រេកអរហើយ គួរអោយអស្ចារ្យណាស់នូវសម្រស់ដ៏វិចិត្រនៃឥន្ទ្រីទាំងឡាយ។

គាថាទី៨ ស្រីទាំងឡាយអ្នកមានសត្រូវដែលខ្លួនសំពះហើយ ទោះបីស្វាមីត្រូវឈ្នះហើយរស្មីព្រោះឃើញព្រះអង្គលះបង់នូវសេចក្តីទុក្ខសោកព្រោះដូចដឹងថាកាមទេពក៏ឈ្នះដោយសម្រស់ (របស់ព្រះអង្គ) បានធ្វើហើយនូវឈ្មោះរបស់ខ្លួនអោយមានន័យ។

គាថាទី៩ ពេលប្រជារាស្ត្រមានមានរោគដល់នូវសេចក្តីវិនាសតាមភារៈនៃកម្មដោយការអស់ទៅនៃអាយុព្រោះបុណ្យព្រះអង្គជាព្រះរាជា បានធ្វើគោដែលសម្បូរណ៍ទាំងបីដើម្បីប្រកាសយុគដ៏ប្រសើរ។

គាថាទី១០ ព្រះអង្គគិតរួចហើយថាផែនដីត្រូវធ្វើឱ្យទៅជាឋានសួគ៌ដោយសេចក្តីរុងរឿងព្រមទាំងធ្វើឱ្យភាពកខ្វក់ដោយសេចក្តីស្លាប់ ទើបណែនាំទឹកអម្រិត្រគឺផ្ទៃះដល់មនុស្សដែលត្រូវស្លាប់ដើម្បីសេចក្តីមិនស្លាប់។



www.elibraryofcambodia.org

គាថាទី១១ ព្រះអង្គបានទទួលនូវផលសំរេចបានធ្វើកិច្ចដែលគួរធ្វើ ហើយគឺបានធ្វើក្លីយុគឱ្យទៅជាគោដែលមានជើងបាក់ហើយ ព្រោះទោសនៃយុគទាំងបីអោយមានរាងកាយពេញបរិបូរណ៍ដោយការរក្សារបស់ពេទ្យព្រះរាជា។

គាថាទី១២ ព្រោះគោនោះត្រូវធ្វើឱ្យសម្បូរណ៍ហើយក្រោយពីឈ្នះគោនៃនគរផ្សេងៗបន្លឺសំលេងឮកងរំពងក្នុងទីលាននៃលោកទាំងបី ដោយសេចក្តីអង់អាច។

គាថាទី១៣ រោគតាមរាងកាយរបស់ប្រជារាស្ត្រនេះ ជារោគខាងផ្លូវចិត្តដែលមានសេចក្តីឈឺចាប់ខ្លាំងណាស់ ព្រោះសេចក្តីទុក្ខរបស់ប្រជារាស្ត្រទោះបីមិនមែនជាសេចក្តីទុក្ខរបស់ព្រះអង្គ តែជាសេចក្តីទុក្ខសំរាប់អ្នកគ្រប់គ្រង។

គាថាទី១៤ ព្រះអង្គព្រមដោយគ្រូទេពទាំងឡាយអ្នកក្លាហានវៃឆ្លាត និងទំនងជារៀនចំពោះក្នុងអាយុវេទនិងអស្ត្រវេទ បានសំលាប់សត្រូវគឺរោគរបស់ប្រជារាស្ត្រដោយអាវុធគឺឱសថ។

គាថាទី១៥ ពេលព្រះអង្គបានជំរះទោសរបស់ប្រជារាស្ត្រទាំងឡាយដោយជុំវិញហើយបានជំរះទោសនៃរោគទាំងឡាយព្រោះទោសនៃយុគ។

គាថាទី១៦ ព្រះអង្គបានកសាងមន្ទីរពេទ្យនេះ និងរូបព្រះពោធិសត្វភៃសជ្យសុគតព្រមទាំងរូបព្រះជិនោរសទាំងពីរព្រះអង្គ ដើម្បីសេចក្តីស្ងប់នៃរោគរបស់ប្រជារាស្ត្រជារៀងរហូតតទៅ។



www.elibraryofcambodia.org

គាថាទី១៧ ព្រះអង្គបានកសាងមន្ទីរទេព្យនេះ និងរូបព្រះពោធិសត្វភៃសជ្យសុគតព្រមដោយព្រះវិហាររបស់ព្រះសុគត ដោយដួងចន្ទ្រគឺព្រះហឫទ័យក្នុងផ្ទៃមេឃគឺព្រះវរកាយដ៏ល្អិតល្អន់។

គាថាទី១៨ ព្រះអង្គបានកសាងរូបចំលងនៃព្រះវៃរោចនជិនជាម្ចាស់ចាប់ផ្តើមដោយសូរ្យនិងចន្ទ្រដ៏ល្អវិចិត្រនេះអោយជាអ្នកកំចាត់រោគរបស់ប្រជារាស្រ្តអ្នកមានរោគទាំងឡាយក្នុងទីនេះ។

គាថាទី១៩ ដើម្បីរក្សាការពារបាលក្នុងទីនេះទើបអោយមានអ្នកថែរក្សាបួននាក់ទេពពីរនាក់ក្នុងបណ្តាអ្នកទាំងបីនោះគឺជាបុរសម្នាក់ឬស្រ្តីពីរនាក់ជាផ្តល់ស្ថិតិ។

គាថាទី២០ អ្នកប្រគល់មន្ទីរពេទ្យនេះបានតែងតាំងអោយបុរសពីរនាក់ជា អ្នកថែរក្សាទ្រព្យ ជាអ្នកបើកថ្នាំ ជាអ្នកទទួលស្រូវនិងអុស។

គាថាទី២១ ចំណែកបុរសពីរនាក់ជាអ្នកដាំស្លរជាអ្នកថែរក្សា និងបើកទឹក ក្នុងទីនេះជាអ្នករកផ្កាឈើនិងស្មៅបូជាយញ្ញ និងជាអ្នកបោសសំអាតទេវស្ថាន។

គាថាទី២២ បុរសពីរនាក់ជាអ្នករៀបចំពលីទាន ជាអ្នកធ្វើបំណ្ណ ជាអ្នកបើកបំណ្ណឆ្លាស់ និងអ្នករកអុសដើម្បីដាំថ្នាំ។

គាថាទី២៣ បុរសទាំងដប់បួននាក់ជាអ្នកថែរក្សាមន្ទីរពេទ្យ និងជាអ្នកបញ្ជូនថ្នាំអោយពេទ្យរួមទាំងអស់ចំនួនម្ភៃពីរនាក់។



www.elibraryofcambodia.org

គាថាទី២៤ បណ្តាបុគ្គលទាំងនោះរួមបុរសម្នាក់និងស្ត្រីម្នាក់ ជាអ្នកអោយស្ថិតិចំណែកស្ត្រីប្រាំមួយនាក់ទៀតជាអ្នកបុកថ្នាំដែលត្រាំដោយទឹក។

គាថាទី២៥ ចំណែកស្ត្រីពីរនាក់ជាអ្នកដាំបបររួមស្ត្រីទាំងនោះបានចំនួនប្រាំបីនាក់ បណ្តាស្ត្រីទាំងនោះជាអ្នកអោយស្ថិតិមួយថ្ងៃៗប្រើស្ត្រីពីរនាក់

គាថាទី២៦ ចំណែកបុរសធុរការរាប់រួមគ្នាបានសាមសិបពីរនាក់រួមទាំងអ្នកបំរើការងារទាំងអស់ចំនួនកៅសិបប្រាំបីនាក់ ដែលស្មើរដោយអ្នកផ្តល់ស្ថិតិ។

គាថាទី២៧ អង្ករសំរាប់ជាសំណែនបូជាទេវរូបមួយថ្ងៃ មួយទោរណៈជារៀងរាល់ថ្ងៃ សំណែនដែលនៅសល់គប្បីអោយដល់អ្នកជំងឺជារៀងរាល់ថ្ងៃ។

គាថាទី២៨ គ្រប់ឆ្នាំរបស់ដែលគួរយកចេញពីឃ្លាំងរបស់ព្រះរាជាមានបីពេល របស់ម្យ៉ាងៗដែលគួរអោយគឺក្នុងថ្ងៃពេញបូរមីខែចែត្រ និងក្នុងពិធីបុណ្យភ្ជុំបិណ្ឌក្នុងកាលដែលព្រះអាទិត្យជ្រេរទៅទិសខាងជើង។

គាថាទី២៩ គ្រឿងដណ្តប់ដែលមានជាយពណ៌ក្រហមមួយផ្ទាំងសំពត់ពណ៌សប្រាំមួយផ្ទាំង ចំណីគោពីរបលៈ ទៀនក្រមួនប្រាំបលៈ និងក្រីស្នាក៏ស្មើរគ្នាជារបស់ដែលគួរអោយជារៀងរាល់ថ្ងៃ។

គាថាទី៣០ ទៀនក្រមួនឃ្មុំប្រាំពីរបលៈទៀត(គឺមួយបលៈ ប្រាំបលៈនិងមួយបលៈ) ទឹកឃ្មុំបួនប្រស្ថៈ និងខ្លាញ់បីប្រស្ថៈជារបស់ដែលគួរអោយជារៀងរាល់ថ្ងៃ។



www.elibraryofcambodia.org

គាថាទី៣១ ខ្លាញ់ថ្លាមួយប្រស្ថៈ ឱសថដែលធ្វើអោយក្តៅដោយម្ទេស និងប៉ុននាគក៏ស្មើរគ្នាម្យ៉ាងៗមានទំងន់បពីរបាទ និងចន្ទទេសបីផ្លែ។

គាថាទី៣២ មហាហិង្គ អំបិល ផ្លែក្រវាញតូច និងកំញានម្យ៉ាងៗទំងង់មួយបាទប្រាំ............ស្កត្នោតក្ងរពីរបលៈ។

គាថាទី៣៣ ម្យ៉ាងៗមានសត្វដែលមានឈ្មោះថា រោមរាប់អោយបានដប់ក្បាល ឈើចន្ទជំរ និងគ្រប់ផ្កាឈើមួយរយត្រួយរួបរួមអោយបានមួយបលៈ។

គាថាទី៣៤..........ម្រេច.............ម្យ៉ាងៗ ពីរប្រស្ថៈ និងត្រួយល្ពៅពីរបលៈ។

គាថាទី៣៥ អ៊ុបឈើយមួយកណ្តប់ផ្ទៃកន្លះចំណែកស្លឹកឈើកំណត់អោយមានម្ទេសខ្លីកទារវឆេទពីរម្យ៉ាងៗ អោយមានទំងន់មួយបលៈកន្លះ។

គាថាទី៣៦ ទឹកខ្ទឹមនិងសំបករបស់វាតាមដែលកំណត់ទុកមិត្រទេវៈកំណត់ទុកមួយបាទនិងមួយបលៈ។

គាថាទី៣៧ របស់ម្យ៉ាងមានទឹកឃ្មុំនិងម្ទេសអាចម៍ខ្មាំងរាប់អោយបានបីកុទុវៈចំណែកទឹកពុទ្ធាកំណត់ទុកមួយប្រស្ថៈ។

គាថាទី៣៨ អ្នកប្រកបពិធីបូជាយញ្ញពីរនាក់ អ្នកជាហោរាសាស្ត្រម្នាក់ អ្នកទាំងបីនាក់នេះជាអ្នកទ្រទ្រង់គុណធមិនៅក្រោមការគ្រប់គ្រងរបស់ព្រះរាជគ្រូនៃស្រីរាជវិហារ។



www.elibraryofcambodia.org

គាថាទី៣៩ បណ្តារបស់ទាំងនោះម្យ៉ាងៗគួរអោយបានកំទុកជារៀងរាល់ឆ្នាំ......របស់វែងដប់ពីរហត្ថចំនួនដប់គួរ។

គាថាទី៤០ សំពត់វែងប្រាំបួនចំអាមចំនួន...ភាជនៈសំណប៉ាហាំងដែលសមរម្យដែលដាក់បានដប់កដ្ដិកា និងប្រាំកដ្ដិកាចំនួនប្រាំបីសំរាប់។

គាថាទី៤១ ម្យ៉ាងៗមានអង្ករចំនួនដប់ពីរខារិកា...ទៀនក្រមួនដែលគួរអោយចំនួនបីបលៈ ចំណែកក្រឹស្នាចំនួនប្រាំមួយបលៈ។

គាថាទី៤២ ព្រះរាជាទោះបីជាអ្នកដឹកនាំក្នុងចំណោមអ្នកមានចិត្តមេត្តាទាំងឡាយអ្នកមានគំនិតនៃអ្នកមានសេចក្តីត្រូវការ ដែលត្រូវធ្វើអោយកើតឡើងហើយព្រោះសេចក្តីព្រួយបារម្ភក្នុងប្រយោជន៍របស់ព្រះជារាស្រ្តព្រះអង្គ ទើបស្មើរជាមួយនិងស្តេចរាជសិង្ហនៃក្រុងកម្ពុ និងព្រះអង្គអ្នកប្រសើរបានប្រទានអោយហើយ។

គាថាទី៤៣ វត្ថុដែលខ្ញុំម្ចាស់បានធ្វើហើយជាវត្ថុល្អហើយ វត្ថុនេះជារបស់អ្នកទាំងអស់គ្នាអ្នកទាំងអស់គ្នាគប្បីថែរក្សាព្រោះថា វត្ថុទាំងនេះអ្នកប្រាជ្ញទាំងឡាយពោលថាអ្នកថែរក្សាជាអ្នកមាន ចំណែកនៃផលបុណ្យដ៏ថ្លៃថ្លានៃអ្នកធ្វើបុណ្យ។

គាថាទី៤៤ មន្រ្តីណាក្នុងរាជធានី មន្រ្តីនោះឯងគួរទទួលការតែងតាំងក្នុងទីនេះក្នុងមុខដំណែងជាអ្នកគ្រប់គ្រងមន្រ្តីផ្សេង (មកពីកន្លែងផ្សេង) មិនគួរបញ្ជូនមកទីនេះរួមទាំងការប្រមូលពន្ធដាជាដើម និងភារកិច្ចផ្សេងៗ



www.elibraryofcambodia.org

ទៀត។

គាថាទី៤៥ ជនទាំងឡាយណាដែលចូលមកក្នុងទីនេះ (ដំបន់ដែលមានសាសនស្ថាន) ជនទាំងឡាយនោះទោះបីមានទោសធ្ងន់ក៏មិនដាក់ទោសតែជនទាំងឡាយណាដែលនៅទីនេះ (ដំបន់ដែលមានសាសនស្ថាន) ដែលចូលចិត្តធ្វើបាបអ្នកដទៃ ជនទាំងនោះគួរដាក់ទោសនិងមិនគួរលើកលែងទោសអោយ។

គាថាទី៤៦ ព្រះរាជាព្រះអង្គនោះអ្នកប្រាថ្នាសេចក្ដីសុខ និងប្រយោជនដ៏ថ្លៃថ្លា ដល់សត្វលោកបានពោលហើយនូវពាក្យបដិធាននេះម្ដងទៀតថា ព្រះអង្គនឹងចំលងសត្វទាំងឡាយទាំងពួងដែលលិចលង់ក្នុងមហាសមុទ្រ គឺភពអោយរួចផុតទៅបានដោយការធ្វើអំពើរល្អរបស់ព្រះអង្គ។

គាថាទី៤៧ ស្ដេចនៃក្រុងកម្ពុទាំងឡាយណាអ្នកយកចិត្តទុកដាក់ចំពោះកុសល្យ ជាអ្នករក្សាវត្ថុប្រតិស្ថានរបស់ខ្ញុំម្ចាស់ស្ដេចនៃក្រុងកម្ពុ ទាំងនោះព្រមទាំងក្រុមគ្រួសារ និងមន្ត្រីក្នុងរាជធានីដែលជាមិត្រសូមជាអ្នកសម្បូរណ៍ដោយមោកសៈដែលជាបរមសុខ។

គាថាទី៤៨ ដោយគ្រឿងឧបភោគដែលជារបស់ទិព្វដ៏ច្រើនដែលជាកន្លែងផ្លែតផ្លែនតុបតែងហើយដោយនាងទេពធិតាទាំងឡាយ ដែលត្រេតអរក្នុងសេចក្ដីសុខពួកគេទាំងនោះឈ្នះនូវយក្សទាំងឡាយដោយអំណាចអ្នកមានកាយទិព្វតម្បីរុងរឿងក្នុងឋានសួគ៌។



www.elibraryofcambodia.org

គាថាទី៤៩ អ្នកទាំងឡាយអ្នកគ្មានអ្វីជារបស់ខ្លួនឯងក្រោយពីបាន ធ្វើទៅហើយនូវវត្ថុដែលមានតង់វង់ឆ្ពោះទៅរកសេចក្ដីតង់វង់នាពេលខាងមុខ គម្បីថែរក្សាទាំងពេលយប់និងពេលថ្ងៃ ចំណែកអ្នកដែល និងបំផ្លាញអកុសលអោយជាមូលដ្ឋាន (នៃជីវិត) ចំនុចនេះជាបុណ្យរបស់ខ្ញុំម្ចាស់។



www.elibraryofcambodia.org

www.elibraryofcambodia.org

## ៣.២ ប្រចដិមាករដែលដំកល់ទុកក្នុងមន្ទីរពេទ្យ

តាមរយៈខ្លឹមសារក្នុងសិលាចារឹកប្រចាំមន្ទីរពេទ្យត្រង់គាថាទី១៦_១៨ ចារឹកពីការសាងរូបបដិមាក្នុងមន្ទីរពេទ្យដូចខាងក្រោមនេះ÷

«ព្រះអង្គបានកសាងមន្ទីរពេទ្យនេះ និងរូបព្រះពោធិសត្វភៃសជ្យសុគតព្រមទាំងរូបព្រះជិនោរសទាំងពីរព្រះអង្គ ដើម្បីសេចក្ដីស្ងប់នៃរោគរបស់ប្រជារាស្ត្រជារៀងរហូតតទៅ» «ព្រះអង្គបានកសាងមន្ទីរទេព្យនេះ និងរូបព្រះពោធិសត្វភៃសជ្យសុគតព្រមដោយព្រះអង្គបានកសាងមន្ទីរទេព្យនេះ និងរូបព្រះពោធិសត្វភៃសជ្យសុគត ព្រមដោយព្រះវិហាររបស់ព្រះសុគតដោយដួងចន្ទ្រគឺព្រះហឫទ័យក្នុងផ្ទៃមេឃ គឺព្រះវរកាយដ៏ល្អិតល្អន់»។

តាមរយៈខ្លឹមសារក្នុងសិលាចារឹកបានបញ្ជាក់យើងយ៉ាងច្បាស់ថា ព្រះបាទជ័យវរ្ម័នទី៧ ព្រះអង្គទ្រង់ប្រតិស្ឋានរូបពោធិសត្វភៃសជ្យគុរុសុគត ព្រះពោធិសត្វសូរ្យចនរោចិ ព្រះពោធិសត្វចន្ទ្ររោហិណិប៉ុណ្ណោះ។



www.elibraryofcambodia.org




ព្រះពោធិសត្វភៃសជ្យគុរុសុគត

បើយើងនិយាយអំពីព្រះពោធិសត្វភៃសជ្ជយគុរុសុគត ប្រជារាស្ត្រខ្មែរយើងបច្ចុប្បន្នហាក់ដូចជាមិនសូវស្គាល់ ឬ អាចមិនស្គាល់ដោយហេតុថាប្រទេសខ្មែរយើងសព្វថ្ងៃកាន់ព្រះពុទ្ធសាសនានិកាយថេរវាទ។

លក្ខណៈខុសគ្នារវាងព្រះពុទ្ធសាសនានិកាយថេរវាទចំនិងមហាយានពោលដោយសង្ខេបគឺ៖

ពាក្យប្រៀនប្រដៅរបស់ព្រះសាសនានិកាយថេរវាទពោលថា មនុស្សអាចនិងរួចផុតពីការកើត ចាស់ ឈឺ ស្លាប់ បានដោយអាស្រ័យការសិក្សាព្រះធម៌វិន័យរបស់ព្រះពុទ្ធជាម្ចាស់ និងហ្វឹកប្រព្រឹត្តិប្រតិប័ត្ររំងាប់កិលេស។ ព្រះពុទ្ធសាសនាថេរវាទបង្រៀនផ្លូវដែលមនុស្សបំពេញបាន



www.elibraryofcambodia.org

ដោយលំបាក និកាយនេះគោរពព្រះសាក្យមុនីព្រះពុទ្ធជាម្ចាស់ ដែលបានប្រសូត្រត្រាស់ដឹងនិងចូលបរិនិពាន្តជាសំខាន់។ ផ្ទុយទៅវិញនិកាយមហាយានត្រឡប់មានព្រះពោធិសត្វ គឺអ្នកដែលនិងត្រាស់ដឹងជាព្រះពុទ្ធនាអនាគត ជាច្រើនក្រៅពីនេះនៅមានព្រះធយានិពុទ្ធគឺព្រះពុទ្ធជាម្ចាស់អ្នកបំពេញឈានសមាបត្តិឡើងដ៏ច្រើនអង្គផងដែរ ដីម្បីនិងប្រាថ្នានិងចូលនិពាន្តដូចនិកាយថេរវាទ។ និកាយមហាយានបាននិយាយពីឋានទេវលោកថ្នាក់ផ្សេងៗជាច្រើន និងបានពោលពីវិញ្ញាណនឹងបានកើតទីនោះស្រេចតែបុណ្យកុសលបានធ្វើទុក។ ព្រះពោធិសត្វដែលនិយមបំផុតនៅប្រទេសខ្មែរ នោះគឺព្រះពោធិសត្វលោកេស្វរៈគឺ ព្រះពោធិសត្វជាធំនៃលោកព្រះអង្គទ្រង់ជាអ្នកគ្រប់គ្រងលើសត្វលោកទាំងអស់។ ព្រះអង្គបៀមទៅដោយព្រះទ័យអាណិតអាសូរ និងសេចក្ដីមេត្តាករុណា ដូចនេះមុនពេលព្រះអង្គចូលបរិនិពាន្តព្រះអង្គចាំបាច់ត្រូវចំលងសត្វលោកទាំងអស់អោយចូលនិពាន្តព្រមជាមួយនិងព្រះអង្គដែរ។ ព្រះពោធិសត្វលោកេស្វរៈនេះប្រសូត្រចេញពីព្រះធយានិពុទ្ធអង្គដែលទ្រង់មាននាមថា អមិតាភៈនិងមានរូបព្រះអមិតាភៈ គឺព្រះពុទ្ធទំរង់សមាធិប្រចាំនៅលើផ្នួងកេសា។ ក្នុងជ្រោយឥណ្ឌូចិនព្រះអង្គរមែងកាន់គម្ពីរកូនប្រខាំនិងផ្កាឈូក តែព្រះហត្ថរបស់ព្រះអង្គនោះមានចំនួនច្រើនផ្សេងៗគ្នាតាំងតែមានព្រះហត្ថ២ ដល់៤_៦ឬ១២និងក្នុងតម្រាខ្លះមានរហូតដល់ចំនួនព័ន្ធ។ ចំណែកជាងចំលាក់ខ្មែរបុរាណចូលចិត្តឆ្លាក់រូបព្រះអង្គកំពុងបែងភាគជាបុគ្គល់ផ្សេងៗជាច្រើនដោយក្នុងរូបចំលាក់បុគ្គលទាំងនេះព័ទ្ធជុំវិញដោយពន្លឺរស្មី(មើលរូបព្រះពោធិសត្វលោកេស្វរៈ នៅទំព័រ៣៨)។



www.elibraryofcambodia.org

ហើយយើងសូមបញ្ជាក់ផងដែរថា ព្រះបាទជ័យវរ្ម័នទី៧ ព្រះអង្គក៏ចាត់ទុកព្រះអង្គជាព្រះពោធិសត្វមួយអង្គផងដែរដូចមានដូចអត្ថបទសិលាចារឹករបស់ព្រះអង្គបានពោលថា

**«ព្រះរាជាទ្រង់បានប្រាថ្នាសេចក្តីល្អនិងប្រយោជន៍ដ៏ធំធេងដល់សត្វលោក ព្រះអង្គបានពោលនូវពាក្យបដិជាននេះម្តងទៀតថា ព្រះអង្គនិងជួយស្រោចស្រង់សត្វលោកដែលលិចលង់ក្នុងមហាសមុទ្រអោយរួចផុតដោយអំពើល្អរបស់ព្រះអង្គ»។**

ចំណែកព្រះពោធិសត្វភៃសជ្ជយគុរុសុគតឬព្រះពុទ្ធជាម្ចាស់ ដែលជាគ្រូពេទ្យទិព្វមានឈ្មោះជាភាសាចិនថា (Yao che lieou li kouang jou lai) ត្រូវនិងភាសាសំស្ក្រឹត គឺព្រះភៃសជ្ជយឌូរ្យសុគត ប្រែថាព្រះពុទ្ធជាម្ចាស់ទ្រង់ជាគ្រូនៃបណ្តាគ្រូពេទ្យទាំងឡាយដែលមានពន្លឺដូចពន្លឺកែវទិព្វដែលជាឈ្មោះប្រាកដមានក្នុងគម្ពីរមញ្ជុស្រីមូលកប្ប។

ព្រះពោធិសត្វភៃសជ្ជយគុរុជាព្រះពុទ្ធជាម្ចាស់ជាទីនិយមគោរពប្រតិបត្តិបំផុតនាបច្ចុប្បន្នក្នុងប្រទេសចិន ទីបេ កូរេ ជប៉ុន។ សំរាប់ប្រទេសកម្ពុជាព្រះពុទ្ធជាម្ចាស់អង្គនេះត្រូវបានប្រជារាស្ត្រខ្មែរគោរពប្រតិបត្តិក្នុងរជ្ជកាលពះបាទជ័យវរ្ម័នទី៧។ តាមខ្លឹមសារនៃព្រះគម្ពីរបានអោយដឹងថា ព្រះអង្គទ្រង់គង់នៅក្នុងឋានពុទ្ធក្សេមផ្នែកទិសបូព៌ាឈ្មោះថាសុទ្ធិភៃឌូរ្យ ដែលនៅផ្ទុយនិងឋានសុខាវតីពុទ្ធក្សេមរបស់ព្រះធយានិពុទ្ធអមិត្តភៈដែលនៅទិសបច្ចិម។



www.elibraryofcambodia.org

ក្នុងគម្ពីរសទ្ធម្មបុណ្ឌរិកសូត្របរិច្ឆេតទី២២ បានអធិប្បាយអំពីអតិតជាតិ និងបច្ចុប្បន្នជាតិរបស់ព្រះពោធិសត្វភៃសជ្ជយគុរុ តែក៏មិនបានអធិប្បាយថា ព្រះពោធិសត្វសជ្ជគុរុជាព្រះពុទ្ធជាម្ចាស់ត្រឹមតែពោលថាព្រះអង្គជាព្រះពោធិសត្វប៉ុណ្ណោះ ថែមទាំងព្រះអង្គក៏មិនបានទាក់ទងនិងការព្យាបាលរោគដោយប្រការណាមួយទោះទេទើបធ្វើអោយយើងសន្និដ្ឋានថាទស្សនះរឿងទាក់ទងនិងព្រះភៃសជ្ជយគុរុ ដែលទាក់ទងនិងការព្យាបាលរោគជាទស្សនះដែលតែងឡើងនៅសម័យក្រោយ និងទំនងជាតភ្ជាប់ពីចុងការបរិច្ឆេទទី២២របស់គម្ពីរសទ្ធធម៍បុរិណ្ឌកសូត្រដែលបានពោលថា ផលបុណ្យក្នុងការស្តាប់ទេសនាព្រះសទ្ធធម៍បុរិណ្ឌកសូត្រនិងធ្វើអ្នកមានក្លិនមាត់ក្រអូបដូចផ្កាឈូក និង ព្រះសទ្ធធម៍បុរិណ្ឌកសូត្របរិច្ឆេទនេះប្រៀបដូចឱសថ ដែលព្យាបាលរោគដល់អ្នកជំងឺ និងសព្វសត្វអោយផុតទុក្ខពីរោគាព្យាធិប្រកបនិងអត្ថន័យរបស់ពាក្យថា «ភៃសជ្ជយ» ដែលប្រែថា ថ្នាំរក្សារោគ ដែលតមកក្នុងគម្ពីរសតសហស្សសារិកាប្រាជ្ញាបារមិតាសូត្រចាប់ផ្តើមដោយពោលថា ជាព្រះភៃសជ្ជយគុរុទ្រង់ជាព្រះពុទ្ធជាម្ចាស់។

ចំណែកដើមច្បាប់គម្ពីរភាសាសំស្ក្រឹតដែលពោលថា ព្រះភៃសជ្ជយគុរុមានតួនាទីក្នុងការរក្សារោគត្រទឡប់ប្រាកដជាច្បាប់ប្រែភាសាចិនមានឈ្មោះថា (Fo cho ta kouan ting chen teheou king) ត្រូវនិងឈ្មោះភាសាសំស្រ្កិតគឺពុទ្ធាភាសិតមហាភិសេករទធិរណីសូត្រ គម្ពីរនេះត្រូវបានទទួលការបកប្រែជាភាសាចិនក្នុង ព.ស. ៨៦០_៨៦៥។



www.elibraryofcambodia.org

ម្យ៉ាងទៀតក្នុងគម្ពីរភៃសជ្ជយគុរុ ដូចជាសប្តពុទ្ធបូរវបណិធានគុណសូត្រសំនួនប្រែរបស់ព្រះសង្ឃចិនហៀនច័ងបានពោលថា ព្រះអង្គជាប្រធានរបស់អតិតព្រះពុទ្ធជាម្ចាស់៧ (ហៅថាព្រះពោធិសត្វភៃសជ្ជយគុរុ៧ព្រះអង្គរួមនិងព្រះភៃសជ្ជយគុរុជា៨អង្គ) គ្រប់ព្រះអង្គបានពោលពីបណីធានក្នុងការជួយសង្គ្រោះសត្វលោក។ បណិធានរបស់ព្រះភៃសជ្ជយគុរុ និងព្រះពុទ្ធជាម្ចាស់ទាំងពួងនោះដូចគ្នានិងបដិហារ្យរបស់ព្រះពោធិសត្វលោកេស្វារៈ ក្នុងបរិច្ឆេទទី២៤ ទើបជារឿងដែលអាចដែលថា ព្រះពុទ្ធជាម្ចាស់ដែលប្រាកដក្នុងគម្ពីរសទ្ធធម៌បុណ្ឌរិកសូត្រ បានទទួលឥទ្ធិពលពីបណិធានរបស់ព្រះពោធិសត្វលោកេស្វារៈក្នុងគម្ពីរសទ្ធធម៌បុណ្ឌរិកសូត្រ។ ចំណែកព្រះបណិធានរបស់ព្រះពោធិសត្វភៃសជ្ជយគុរុសុគតមានចំនួន១២ប្រការ ដោយពោលសង្ខេបដូចខាងក្រោមនេះ៖

«យើងមកទីនេះដើម្បីជួយព្យាបាលអ្នកមានរោគដែលព្យាបាល មិនជាអ្នកជំងឺដែលគ្មានពេទ្យ ឬថ្នាំព្យាបាលអ្នកជំងឺដែលគ្មានញាតិអ្នកជំងឺដែលក្រីក្រទុក្ខលំបាកពេលបានឮឈ្មោះយើងហើយរមែងរួចផុតទុក្ខទាំងនោះ និងមានជីវិតមានតែសេចក្តីសុខទាំងកាយនិងចិត្ត ដើម្បីខ្លួននិងគ្រួសារ និងជួបប្រទះតែសេចក្តីសុខ និងសំរេចនូវបញ្ញាញាណជាន់ខ្ពស់»

«យើងមកទីនេះដើម្បីអោយស្ត្រីបានទទួលទុក្ខផ្សេងៗដល់ធុញទ្រាំ និងបំផ្លាញជីវិតខ្លួនឯងមិនចង់រស់នៅក្នុងសភាពជាស្ត្រីតទៅទៀត រមែងបានទៅកើតជាមនុស្សប្រុស និងសំរេចនូចបញ្ញាខ្ពស់»



www.elibraryofcambodia.org

តាមរយៈបដិធានខាងដើមនេះ ព្រះពោធិសត្វភៃសជ្ជយគុរុសុគត មានតួនាទីជួយសង្គ្រោះសត្វលោកច្រើនជាងតួនាទីរបស់ព្រះអមិត្តាភពុទ្ធ។ តាមគម្ពីរបានអោយដឹងថា ព្រះពោធិសត្វភៃសជ្ជយគុរុសុគតបើបុគ្គលបូជាអោយត្រឹមត្រូវអ្នកបូជាអាចនិងជាសះស្បើយពីរោគាទាំងផ្លូវកាយ និងផ្លូវចិត្ត។ បើអ្នកបូជាឈឺតាមរាងកាយត្រង់ណាក៏អោយយកដៃមកស្ទាប ព្រះពោធិសត្វភៃសជ្ជយគុរុសុគតត្រង់នោះរោគនិងជាសះស្បើយ ដូចជាឈឺភ្នែកក៏អោយយកដៃទៅស្ទាបត្រង់ព្រះនេត្ររបស់ព្រះអង្គដូចនេះជាដើម។

## ទីកន្លែងស្ថិតរបស់ព្រះពោធិសត្វភៃសជ្ជយគុរុ

ព្រះអង្គទ្រង់ស្ថិតនៅក្នុងពុទ្ធក្សេមផ្នែកទិសខាងកើត ដែលសុទ្ធសឹងជាកែវចរណៃប្រាសាទនិងកំពែងមានរស្មីរតនមន្ទីភ្លឺចិញ្ចាចជានិច្ច។ ព្រះអង្គមានទីឋានដ៏ធំធេងដើម្បីនាំសត្វអោយផុតទុក្ខនិង ភាពសេចក្តីងងឹតអោយចូលដែនសីមាររបស់ព្រះអង្គ។

ព្រះអង្គក៏នៅមានព្រះពោធិសត្វ២អង្គទៀតជាជំនួយការ គឺព្រះពោធិសត្វវៃចន្ទវៃចនរោហិណិ និងព្រះពោធិសត្វសូរ្យវៃចនរោចិ តែមកដល់ពេលនេះអ្នករៀបរៀងមិនអាចរកឃើញនូវឯកសារផ្សេងៗ ដែលទាក់ទងនិងព្រះអង្គព្រមទាំងរូបបដិមាកររបស់ព្រះអង្គ។ ដោយទុកជាប្រធានបទសំរាប់សិក្សាជាបន្តទៅទៀត។



www.elibraryofcambodia.org

## ៣.៣ ឧបករណ៍និងវិធីសាងសង់មន្ទីរពេទ្យ

តាមរយៈការសិក្សាស្រាវជ្រាវបានអោយដឹងថា ការជ្រើសឧបករណ៍សាងសង់មន្ទីរពេទ្យនីមួយៗគឺអាស្រ័យទៅលើធនធានធម៌ជាតិ ដែលមានតាមតំបន់នីមួយៗ។

ជាហេតុធ្វើការជ្រើសរើសឧបករណ៍នៃការសាងសង់ក៏ជាទី តាំងមន្ទីរពេទ្យនិមួយៗក៏មានលក្ខណៈខុសៗគ្នា។ ដូចជាលក្ខណៈពិសេសនៃព្រះវិហារប្រចាំមន្ទីរដែលរកឃើញក្នុងប្រទេសថៃបច្ចុប្បន្ន ជាអាគារដែលមានគ្រោងសាងភាគច្រើនជាថ្មបាយក្រៀម តែដោយសារថ្មបាយក្រៀមសាច់ថ្មមានរូងច្រើនទើបមិនអាចឆ្លាក់ជាក្បាច់ចំលាក់ផ្សេងៗបាន។ ដូចនេះផ្នែកណាដែលត្រូវការឆ្លាក់ជាក្បាច់ចំលាក់ទើបប្រើវិធីបូកកំបោ ចំណែកថ្មខ្សាច់និងប្រើចំពោះផ្នែកដែលជាអង្គប្រកបស្ថាបត្យកម្មដែលត្រូវការឆ្លាក់ជាក្បាច់ ដូចជា ផ្ទឹម ហោជាង សរសរ ប្រអប់ជាដើម។

ដូចជាផ្ទឹមប្រាសាទគូពោនរះយ៉ង (Prasat KuraKhang) ខេត្តរយអេត (Roiet Province) មានលក្ខណៈដូចគ្នានិងប្រាសាទព្រះខ័ន ក្នុងក្រុងអង្គរដែលជារូបបែបរបស់ផ្ទឹមជំនាន់ទីពីរនៃរចនាបថបាយ័ន និងហោជាងប្រាសាទប្រាង្គគូ (Prasat Prang Ku) (Chaiyapum Province) ខេត្តជ័យភូមិ ដែលឆ្លាក់ជារូបព្រះពោធិសត្វអវលោកេស្វារៈព្រះហត្ថបួន។ តែសំរាប់ព្រះវិហារក្នុងប្រទេសខ្មែរ ជាពិសេសក្នុងបរិវេណក្រុងអង្គរ និងសង់ដោយថ្មភក់និងឆ្លាក់ក្បាច់ចំលាក់ពាសពេញតួប្រាសាទតែម្តង ដូចជា



www.elibraryofcambodia.org

ប្រាសាទ តាព្រហ្មកិលជាដើម។

បញ្ហានេះធ្វើអោយមានការសង្ស័យកើតឡើងថា ហេតុអ្វីបានជាការជ្រើសឧបករណ៍ ការតុបតែង និងភាពប្រណិតនៃព្រះវិហារតាមដំបន់នីមួយៗ មានលក្ខណៈខុសៗគ្នាដូច្នេះ?

ចំលើយក៏អាចព្រោះថា មន្ទីរពេទ្យនៅតាមដំបន់នីមួយៗមានភាពសំខាន់មិនស្មើរគ្នា ព្រះវិហារណានៅជិតក្រុងអង្គរធំដូចជាប្រាសាទតាព្រហ្មកិល ប្រាសាទនៅទិសខាងកើតប្រាសាទតាកែវ ក៏រមែងមានភាពល្អប្រណិតជាងព្រះវិហារប្រចាំមន្ទីរពេទ្យដែលនៅដំបន់ឆ្ងាយៗពីក្រុងអង្គរធំ។ ក្រៅពីឋានៈរបស់មន្ទីទេព្យដែលជាបច្ច័យសំខាន់ក្នុងការជ្រើសឧបករណ៍ក្នុងការសាងសង់ព្រះវិហារ (សាសនស្ថានប្រចាំមន្ទីរទេព្យ)។ តែពេលខ្លះការជ្រើសរើសឧបករណ៍ក្នុងសាងសង់ក៏ត្រូវអាស្រ័យតាមដំបន់និមួយៗ ដែលអាចរកឧបករណ៍បានងាយក្នុងដំបន់នោះដូចជាប្រាសាទមឿងកៅ (Prasat Meang kao) (Nakonratthasima Province) ខេត្តនគររាជសីមា ប្រើថ្មបាយក្រៀមសង់ប្រាសាទប្រធានតែប្រើថ្មភក់សង់គោបុរៈ ចំណែកប្រាសាទតាមាន់តូចខេត្តសុរិន្ទ្រប្រើថ្មភក់សង់ចំពោះតួខាងក្រោមនៃប្រាសាទ ចំណែកកំពូលប្រាសាទប្រើថ្មបាយក្រៀមក្នុងសាងសង់។

ក្រៅពីភាពប្រណិតក្នុងសាងសង់ចំនួនអ្នកបំរើការក្នុងមន្ទីរទេព្យរហូតដល់ចំនួននិងភាពសម្បូរណ៍បែបនៃរបស់របរដែលប្រើប្រាស់តាមមន្ទីទេព្យនីមួយៗជាការបង្ហាញដល់ភាពសំខាន់នៃមន្ទីរទេព្យនោះៗ ហើយក៏ជាការ



www.elibraryofcambodia.org

បង្ហាញនូវភាពសំខាន់ពោលគឺទំហំទីប្រជុំជន និង ទំហំសេដ្ឋកិច្ចដែលជាទីតាំងនៃមន្ទីរពេទ្យទាំងនោះទៀតផង។

ចំណែកទីតាំងនៃមន្ទីរពេទ្យយើងសង្កេតឃើញថា មានមន្ទីរពេទ្យបួនកន្លែងតាំងនៅក្រៅកំពែងរាជធានីអង្គរធំ។ មន្ទីរពេទ្យក្រុង ភិម៉ាយ ខេត្តនគររាជសីមាប្រទេសថៃ តាំងនៅក្រៅកំពែងក្រុងភិម៉ាយប្រាសាទតួសន្តរត្ន ខេត្ត មហាសារខាមតាំងនៅក្រៅតួទឹកក្រុងចាំប៉ាស្រី និងប្រាសាទពោនរះយ៉ង ខេត្តរយអិត តាំងនៅឆ្ងាយពីបរិវេណប្រាសាទតួកាសិង្ហជាដើម។

ដូចនេះយើងអាចសន្និដ្ឋានបានថា ស្ថានទីតាំងរបស់មន្ទីរទេព្យខ្លះទំនងជាតាំងនៅក្រៅក្រុង។ តែក៏មានករណីលើកលែងខ្លះអាចសង់នៅជិតនិងសានស្ថានដែលមានរួចទៅហើយ។ ដូចជាប្រាសាទនាងរាំ ខេត្តនគររាជសីមា សង់ជាប់ប្រាសាទតួព្រាហ្មណ៍ចាំសីលនិងប្រាសាទមានប្រាសាទ ខេត្តសុរិន្ទ្រសង់ជាប់នឹងប្រាសាទមានជ័យជាដើម។

ម្យ៉ាងទៀតប្រាសាទស្រះមរកតខេត្តប្រាជិនបុរីទោះបីសង់នៅក្រៅតួទឹកនៃក្រុងមហោសថក៏ដោយ តែក៏សង់ត្រួតពីលើសាសនស្ថានដែលមានពីមុនរួចទៅហើយផងដែរ។



www.elibraryofcambodia.org

## ៣.៤ ទំនាក់ទំនងនិងអត្ថប្រយោជន៍នៃសាលាពេទ្យនិងព្រះវិហារប្រចាំមន្ទីរ

តាមរយៈខ្លឹមសារក្នុងសិលាចារឹកត្រង់គាថាទី១៧ បានឱ្យដឹងថា "ព្រះអង្គបានសាងអរោគយសាលានេះនិងរូបព្រះពោធិសត្វភៃសជ្យសុគត ព្រមទាំងព្រះវិហាររបស់ព្រះសុគតដោយដួងចន្ទ្រគឺព្រះហឫទ័យក្នុងផ្ទៃមេឃ គឺព្រះវរកាយដ៏ល្អិតល្អន់"។

តាមអត្ថន័យក្នុងគាថានេះយើងអាចពិគ្រោះវិភាគបានថា សាសនស្ថានដែលបច្ចុប្បន្នយើងហៅថាមន្ទីរពេទ្យនោះតាមពិត សាស្ថានពីរនៅជាមួយគ្នាគឺអរោគយសាលានិងព្រះវិហារ។

អរោគយសាលាគឺសាលា ឬអាគារដែលជាផ្នែកដែលហៅ**មន្ទីរពេទ្យ** ជាទីកន្លែងសំរាប់ស្នាក់នៅរបស់គ្រូពេទ្យព្រមទាំងបុគ្គលិកទូទៅនិងជាទីកន្លែងសំរាប់ព្យាបាលជំងឺជូនប្រជារាស្ត្រដែលសន្និដ្ឋានថាសាងសង់អំពីឈើ ហើយរហូតមកដល់សព្វថ្ងៃបាក់បែកអស់ទៅហើយ។

ព្រះវិហារគឺជាកន្លែងដែលប្រតិស្ឋានព្រះភៃសជ្យគុរុគឺសាសនស្ថានប្រចាំមន្ទីរពេទ្យដែលយើងសព្វថ្ងៃនិយមហៅថាប្រាសាទដែលមនុស្សទូទៅយល់ថាជាមន្ទីរពេទ្យ តែតាមពិតមន្ទីរពេទ្យនិងព្រះវិហារប្រចាំមន្ទីរពេទ្យក៏រមែងនៅក្នុងបរិវេណជាមួយគ្នា។



www.elibraryofcambodia.org

## ៣.៥ ទំរង់ប្លង់នៃមន្ទីរពេទ្យ

ប្លង់នៃព្រះវិហារប្រចាំមន្ទីរពេទ្យទាំង១០២ មានទំរង់ស្រដៀងៗគ្នាទាំងអស់ពោលគឺ៖

១. ប្រាង្គប្រធាន

បរិវេណព្រះវិហារកន្លែងនិមួយៗមានទំហំមិនស្មើរគ្នាតែគ្រប់ទីកន្លែង និងមានទំរង់ប្លង់ដូចៗទាំងអស់ ពោលគឺមានរាងបួនជ្រុងទ្រវែង មានព្រះវិហារខ្នាតតូចតាំងនៅក្នុងកំពែងមានមុខបែរចេញទៅទិសខាងកើត និងរមែងមានទ្វារចូលចំពោះខាងមុខ (ចំណែកប្រាសាទពលសង្គ្រាម ខេត្តនគររាជសីមា ប្រាសាទប្រធានធ្វើជាចតុមុខទិសខាងកើតគ្មានមុខបែរចេញ ប្រាសាទបានមឿងកៅ ខេត្តនគររាជសីមា ប្រាសាទប្រធានមានទំរង់ជាចតុមុខ តែមានទ្វារចូលទាំងបួនទិស)។

ប្រាសាទតាព្រហ្មកិលមានការចោះបង្អួចទាំងសងខាង។ តែសំរាប់ព្រះវិហារប្រចាំមន្ទីរពេទ្យដែលបានរកឃើញក្នុងប្រទេសថៃបច្ចុប្បន្ន។ ការចោះអង្គួចទាំងសងខាងក៏មិនមានជាទូទៅព្រោះគេបានរកឃើញការចោះជញ្ជាំងនៃព្រះវិហារ ដែលចោះប្រលោះបង្អួចតែមួយដូចជាប្រាសាទកំពែងណយ ខេត្តស៊ីសះកេត ប្រាសាទប្រាង្គគូ ខេត្តជ័យភូមិជាដើម។ តែកន្លែងខ្លះក៏គ្មានការចោះបង្អួចដូចជាប្រាសាទនាងរាំ ខេត្តនគររាជសីមាជាដើម និងជាពិសេសគឺសព្វថ្ងៃនេះគេរកមិនឃើញព្រះវិហារណាមួយក្នុងប្រទេសថៃដែលមានការចោះចង្អួចពីរនោះទេ។



www.elibraryofcambodia.org




ប្រាសាទណាងប៉ូរាយ ខេត្តបុរីរម្យ៍ ប្រទេសថៃ

ក្នុងព្រះវិហារខ្លះនៅមុខប្រាសាទប្រធាននិងមានរូបជើងក្អែកតភ្ជាប់ រវាងប្រាសាទប្រធាននិងគោបុរៈ ដូចជាប្រាសាទតាមាន់តូច ខេត្តសុរិន្ទ្រ



www.elibraryofcambodia.org

និងប្រាសាទត្លូវយ៉ង ខេត្តរយអិតជាដើម។ តែប្រាសាទកុដិឬស្សីនៅជាប់ជើងភ្នំរុង ខេត្តបុរីរម្យ៍ ផ្លូវដែលតភ្ជាប់រវាងគោបុរៈ និងមុខប្រាសាទប្រធានជាខ្សែត្រង់ ។

ចំណែកបីផ្នែកនៃប្រាសាទប្រធានដែលមិនមែនខាងកើត កន្លែងខ្លះធ្វើជាទ្វារបញ្ឆោត (ទ្វារដែលគេឆ្លាក់ជាទំរង់ទ្វារបិទ) ដូចជាប្រាសាទកុដិឬស្សី ខេត្តបុរីរម្យ៍។ តែកន្លែងខ្លះក៏បូកជញ្ជាំងដោយថ្មបាយក្រៀមមិនបានធ្វើទ្វារបញ្ឆោតដោយត្រឹមតែបូកជាជញ្ជាំងប៉ុណ្ណោះ ដូចជាប្រាសាទប្រាង្គគូខេត្តរយអិត ឬមានការធ្វើគ្របទ្វារដោយថ្មខ្សាច់តែនាំយកថ្មបាយក្រៀមមកខាត់ត្រង់ប្រលោះទ្វារដូចជាប្រាសាទគូប្រផាជ័យ ខេត្តខនកេន ប្រទេសថៃជាដើម។

ម្យ៉ាងទៀតសរសេរប្រដាប់គ្របទ្វារនៃប្រាសាទតាមទំរង់គួរជាសរសេរប្រដាប់ក្នុងសិល្បៈខ្មែររចនាបថបាយ័នចំនួនមិនច្រើនប៉ុន្មាន ដោយភាគច្រើនត្រឹមតែជាការយកសរសេរថ្មខ្សាច់ដែលមិនបានដាប់ជាប្រាំបីជ្រុងមកប្រដាប់តុបតែង ដែលជាការបង្ហាញនូវភាពប្រញាប់ប្រញាល់ក្នុងការសាងសង់ ដូចជាប្រាសាទតាមាន់តូច ខេត្តសុរិន្ទ្រជាដើម។ ចំណែកសរសេរប្រដាប់ជញ្ជាំងដែលជាសិល្បៈខ្មែររចនាបថបាយ័ននោះមិនបានរកឃើញទេ

លក្ខណៈហោជាងនៃព្រះវិហារប្រចាំមន្ទីរពេទ្យភាគច្រើនសង់ដោយថ្មបាយក្រៀម លើកលែងទិសខាងកើតដែលរំមែងប្រើថ្មខ្សាច់។ក្នុងប្រាសាទខ្លះដែលលភាពនៃហោជាងដែលនៅគង់វង់ ដូចជាប្រាសាទតាមាន់តូច



www.elibraryofcambodia.org

ខេត្តសុរិន្ទ្រឃើញថា បរិវេណហោជាងទិសខាងកើតមានការបូកថ្មជាទំរសំរាប់ទ្រសំណង់ខាងលើ។ ដូចនេះក្នុងបរិវេណគោបុរៈនិងប្រាសាទប្រធានទើបគួរមានដំបូលលើប្រក់ក្បឿងតភ្ជាប់គ្នា។ តែសព្វថ្ងៃបានបាក់បែកទៅតាមកាលវេលាអស់ទៅហើយ។

ហោជាងនៃព្រះវិហារប្រចាំមន្ទីរពេទ្យ ជាហោជាងពីរជាន់ហោជាងជាន់ទីពីរនៃព្រះវិហារខ្ពស់ជាងជើងបាតជាន់ទីមួយ មានការប្រើក្ដែបខ្នុរតុបតែងតាមថ្នាក់ជើងបាតគ្រប់ថ្នាក់។ ប្រាសាទតុបតែងដោយភាជនៈសំរាប់ដាក់ទឹកពុទ្ធមន្តដ៏ស័ក្តិសិទ្ធ។

## ២. បណ្ណាល័យ



បណ្ណាល័យប្រាសាទតាមាន់តូច ខេត្តសុរិន្ទ្រ ប្រទេសថៃ



www.elibraryofcambodia.org

នៅផ្នែកខាងក្នុងកំពែងត្រង់ជ្រុងទិសខាងកើតឆៀងខាងត្បូង មានអាគារដែលជាទូទៅហៅថាបណ្ណាល័យ សង់អំពីថ្មបាយក្រៀមបែរមុខទៅទិសខាងលិចចូលមករកប្រាសាទប្រធាន។ ទីតាំងនៃបណ្ណាល័យរមែងតាំងនៅជ្រុងខាងកើតឆៀងខាងជើងជានិច្ច តែបណ្ណាល័យរបស់ប្រាសាទកុដិឫស្សីស្ថិតនៅជើងភ្នំរុង ខេត្តបុរីរម្យ៍ ប្រទេសថៃត្រឡប់សង់ជាប់និងផ្លូវដើរដែលភ្ជាប់រវាងគោបុរះនិងមុខប្រាសាទប្រធាន។

សន្និដ្ឋានអាគារនេះជាកន្លែងដំកល់ទុកនូវតម្រាឬគម្ពីរគាថា អាគមដែលទាក់ទងនិងការវិនិច្ឆ័យឬវិធីការព្យាបាលជំងឺផ្សេងៗ។

ម្យ៉ាងទៀតបណ្ណាល័យរបស់ប្រាសាទនាងរាំ ខេត្តនគររាជសីមា និងបណ្ណាល័យប្រាសាទកុដិឫស្សីជើងភ្នំរុង ខេត្តបុរីរម្យ៍ប្រទេសថៃមានការចោះបង្អួចនៅជញ្ជាំងខាងត្បូង។ ដំបូងបណ្ណាល័យភាគច្រើនប្រក់ដោយថ្មបាយក្រៀមចំណែកហោជាងក៏រមែងធ្វើអំពីថ្មបាយក្រៀម។ បណ្ណាល័យភាគច្រើនរំមែងគ្មានការឆ្លាក់ជាក្បាច់ចំលាក់ផ្សេងៗ លើកលែងប្រាសាទប្រាង្គគូខេត្តជ័យភូមិប្រទេសថៃ កន្លែងហោជាងឆ្លាក់ជារូបភាពនិទានរឿងការស្តេចយាងចេញពីមហាភិនេសក្ករមណ៍ និងធ្មឹមឆ្លាក់ជារូបនិទានរឿង។



www.elibraryofcambodia.org

## ៣. គោបុរៈ




គោបុរៈ ប្រាសាទពន្មា ខេតសកលនគរ ប្រទេសថៃ

គោបុរៈ (ក្លោងទ្វារ) មាននៅមួយកន្លែងតាំងនៅត្រង់ចំនុចកណ្ដាលនៃកំពែងផ្នែកទិសខាងកើត ជាទូទៅគោបុរៈនៃមន្ទីរទេព្យមានការចោះបង្អួចត្រង់ស្លាបគោបុរៈ ដូចជាប្រាសាទតាមាន់តូច ខេត្តសុរិន្ទ្រជាដើម។ តែប្រាសាទខ្លះដូចជាប្រាសាទបានស្ន ខេត្តបុរីរ័មយ៍ ត្រឡប់ឆ្លាក់ជាបង្អួចបញ្ឆោតយកលំនាំបង្អួចពិត។ ហោជាងនៃគេបុរៈភាគច្រើនសង់ដោយថ្មបាយក្រៀមដំបូលប្រក់ដោយសិលាលើដំបូលតុបតែងដោយប្រាលីមានលក្ខណៈដូចផ្កាឈូក ដូចជាប្រាសាទតាមាន់តូចនិងផ្នែកខាងមុខគោបុរៈកន្លែងខ្លះ ដូចជា



www.elibraryofcambodia.org

ប្រាសាទតាមាន់តូច ប្រាសាទប្រាង្គគូខេត្តរយអេតប្រទេសថៃឃើញថា មានផ្លូវដើរជារូបជើងក្អែកដែលលក្ខណៈដូចនេះរកឃើញតិចតួចបំផុត។

## ៤. កំពែង



កំពែងប្រាសាទពន្ធា ខេត្តសកលនគរ ប្រទេសថៃ

កំពែងភាគច្រើនធ្វើអំពីថ្មបាយក្រៀមព័ទ្ធជុំវិញតួប្រាសាទ (លើកលែងមានមួយកន្លែងដែលសង់អំពីថ្មភក់ គឺប្រាសាទបានប្រាសាទ ខេត្តប្រាជិនបុរី ប្រទេសថៃ។ បើកំពែងដែលព័ទ្ធជុំវិញតួប្រាសាទនៅសេសសល់អោយឃើញដល់សព្វថ្ងៃនិងសង្កេតឃើញថាមានប្រហោងទ្វារតូចៗមួយទៀតត្រង់បរិវេណកំពែងទិសខាងត្បូងជាប់និងគោបុរៈ ដូចជាប្រាសាទ



www.elibraryofcambodia.org

ត្លួគន្ធនាម ខេត្តរយអេត និងប្រាសាទប្រាង្គពលសង្គ្រាម ខេត្តនគររាជសីមា ជាដើម តែប្រាសាទប្រាង្គគួស្រុកធវជ្ជបុរី ខត្តរយអេត គ្រប់ជាំចោះទ្វារចូល ពីទិសខាងជើង។ ការចោះទវារចូលតាមកំពែងនោះសន្និដ្ឋានថាអាចព្រោះគោបុរៈ (ក្លោងទ្វារ) ជាកន្លែងដំកល់រូបបដិមាករសំរាប់បូជាទើបមិនមែនជាផ្លូវសំរាប់ចេញចូល។ និងពីការជួសជុលប្រាសាទគូកែវ ខេត្តខនកេនប្រទេសថៃរកឃើញថាទិសខាងជើងនៃគ្រឹះកំពែងមានកប់ទរសំរាប់បង្ហូរទឹកផងដែរ។

**៥. ស្រះទឹក**



ស្រះទឹកតាមាន់តូច



www.elibraryofcambodia.org

ខាងក្រៅបរិវេណកំពែងទិសខាងកេីតឆៀងខាងជេីងនិងមានស្រះមួយរាងបួនជ្រុង។ តែប្រាសាទត្ងួបានខ្មៅ ខេត្តមហាសារខាម ប្រទេសថៃគ្មានស្រះទឹកនៅខាងក្រៅកំពែង។ ទាំងនេះអាចព្រោះថានៅបរិវេណផ្នែកខាងជេីងនៃប្រាសាទមានបារាយទំហំធំរួចស្រេចទៅហេីយ។ចំណែកប្រាសាទវត្តព្រះនាង ក្រុងកំពង់ធំ ស្រះទឹករាងបួនជ្រុងតាំងនៅទិសខាងត្បូងនៃប្រាសាទ។

តាមរយៈទំរង់ប្លង់ព្រះវិហារប្រចាំមន្ទីរពេទ្យមានលក្ខណៈដូចៗគ្នាដូចនេះ។ សន្និដ្ឋានបានថា ទំរង់ប្លន់នៃព្រះវិហារទាំងអស់ត្រូវបានបញ្ជូនមកពីក្រុងអង្គរធំ។ និងមូលហេតុដែលព្រះវិហារប្រចាំមន្ទីទេព្យដែលនៅឆ្ងាយពីក្រុងអង្គធំដូចនៅ ប្រទេសថៃ និងប្រទេសឡាវបច្ចុប្បន្នមានទំហំតូច និងមានលក្ខណៈងាយៗក៏អាចព្រោះថា ចំនួនព្រះវិហារមានចំនួនច្រេីនរហូតដល់ជាមួយរយកន្លែង បេីសង់អោយមានទំហំធំទាំងអស់ក៏ហាក់ដូចជាខ្វះខ្ជាយឧបករណ៍ច្រេីនក្នុងការសាងសង់។ ម្យ៉ាងទៀតអាចមានចំនួនកំណត់ផ្នែកឧបករណ៍តាមតំបន់នីមួយៗនិងចំនួនជំនាញរបស់ជាងក្នុងការសាងសង់ព្រមទាំងទំហំទីប្រជុំជន និងចំនួនប្រជារាស្ត្រតាមតំបន់នីមួយៗដូចជាបេីតំបន់ដែលមានប្រជារាស្ត្ររស់នៅច្រេីនមន្ទីរទេព្យក៏អាចមានទំហំធំតាមផងដែរ។



www.elibraryofcambodia.org

## ៣.៦ ការគ្រប់គ្រងក្នុងមន្ទីរពេទ្យ

ក្នុងបណ្ដាមន្ទីរពេទ្យទាំង១០២កន្លែងនេះមានរបៀបនៃការគ្រប់គ្រងស្រដៀងគ្នាទាំងអស់ពោលគឺមន្ទីរពេទ្យនីមួយៗសង់ឡើងតាមព្រះរាជតម្រិះរបស់ព្រះបាទជ័យវរ្ម័នទី៧ ដោយប្រគល់អោយរាជសំណាក់កណ្ដាលក្នុងរាជធានីអង្គរធំគឺព្រះបរមគ្រូនៃស្រីរាជវិហារ (ប្រាសាទតាព្រហ្ម) ជាអ្នកគ្រប់គ្រងជាន់ខ្ពស់ដូចជា៖ ជាអ្នកកំណត់ថានិងត្រូវសង់មន្ទីរពេទ្យនៅកន្លែងណាឬចៅហ្វាយខេត្តណាត្រូវការសង់មន្ទីរពេទ្យនៅតាមខេត្តក្រុងរបស់ខ្លួនចាំបាច់ត្រូវឆ្លងកាត់ការពិចារណាយល់ព្រមពីសំណាក់ព្រះបរមគ្រូអង្គនេះ។ បន្ទាប់មកព្រះអង្គនិងចាត់តាំងមន្ត្រីពីក្រុងអង្គរចំនួន៣នាក់ដើម្បីទៅប្រកបពិធីកម្មខាងសាសនាប្រចាំមន្ទីរពេទ្យនីមួយៗ រួមមានអ្នកប្រកបពិធីបូជាយញ្ញចំនួន២នាក់និងហោរាសាស្ត្រចំនួន១នាក់អ្នកគ្រប់គ្រង ឬចៅហ្វាយខេត្តដែលមានមន្ទីពេទ្យតាំងនៅមានដំណែងជាអ្នកគ្រប់គ្រងនូវបុគ្គលិក តាមមន្ទីពេទ្យនីមួយៗព្រមទាំងការប្រមូលពន្ធដាគ្រប់គ្រងផ្នែកចំណូល និងចំណាយសំរាប់មន្ទីរពេទ្យនីមួយៗក្នុងតំបន់ការគ្រប់គងរបស់ខ្លួនចំនួនបុគ្គលប្រចាំមន្ទីរពេទ្យនីមួយៗចំនួនចំនួនមិនស្មើគ្នាគឺអាស្រ័យទៅលើទំហំនៃមន្ទីពេទ្យនីមួយៗតាមរយៈអត្ថបទសិលាចារឹក យើងអាចសរុបបានថា ចំនួនបុគ្គលិកដែលច្រើនបំផុតគឺ៩៨នាក់ ដូចជាមន្ទីរពេទ្យប្រាសាទ សាយហ្វុង (Say Fong) ស្ថិតនៅក្រុងវៀងចន្ទ ប្រទេសឡាវ។ មន្ទីរពេទ្យប្រាសាទបានប្រាសាទ (Prasat Banprasat) ស្ថិតនៅស្រុកប្រាសាទ ខេត្ត



www.elibraryofcambodia.org

ស៊ុរិន្ទ្រ មន្ទីរពេទ្យដែលមានចំនួនបុគ្គលិកតិចបំផុតគឺមន្ទីរពេទ្យប្រាសាទ តាមាន់តូចនៅជើងភ្នំដងរែកមានចំនួនតិចជាង៥០នាក់។

ចំនួនមន្ទីបុគ្គលិកប្រចាំមន្ទីរពេទ្យប្រកបដោយអ្នកថែរក្សាមន្ទីរពេទ្យ (ផ្នែកការចាត់ការមន្ទីពេទ្យ) គ្រូពេទ្យបុគ្គលិកផ្នែកបញ្ជី (អ្នកផ្តល់ស្ថិតិ)អ្នកថែរក្សាទ្រព្យសម្បត្តិ (គ្រប់គ្រងចំណូលនិងចំណាយគឺបើកថ្នាំនិងទទួលស្រូវនិងអុស)។ អ្នកបោសសំអាតព្រះវិហារព្រះពុទ្ធរូបប្រចាំមន្ទីរពេទ្យដែលមានតួនាទីជាអ្នកដាំថ្នាំបើកទឹករកផ្កាឈើនិងស្មៅសំរាប់បូជាទេវស្ថាន។ អ្នករៀបចំពលីទានធ្វើប័ណ្ណចែកប័ណ្ណដោយមានតួនាទីម្យ៉ាងទៀតគឺរកអុសសំរាប់ដាំថ្នាំ ចំណែកឱសថការីមានទាំងអ្នកផ្តល់ថ្នាំអោយពេទ្យ ដោយក្នុងផ្នែកនេះមានអ្នកចាត់ធ្វើបញ្ជីចំណែកភោជនាការដែលត្រូវត្រៀមចំណី អាហារសំរាប់អ្នកជំងឺនិងបុគ្គលិកដែលជាស្ត្រី (ជាអ្នកដាំស្ល) និង ត្រូវធ្វើបញ្ជីដូចនិងផ្នែកផ្សេងៗទៀតដែរ។

ការបែងចែកតួនាទីរបស់បុគ្គលិកប្រចាំមន្ទីរទេព្យរហូតដល់របស់របរដែលជាចំណូល និង ចំណាយប្រចាំមន្ទីរពេទ្យនីមួយៗជាភស្តុតាងប្រាប់យើងអោយដឹងថា «កាលណាមានអ្នកជំងឺចូលមកសំរាកព្យាបាលក្នុងមន្ទីរពេទ្យនីមួយៗមិនត្រឹមតែផ្តល់ការព្យាបាលដោយឱសថប៉ុណ្ណោះ តែនៅមើលថែរក្សាអ្នកជំងឺដោយបាយទឹកចំណីអាហារផ្សេងៗ ព្រមទាំងគ្រឿងប្រដាប់ប្រើប្រាស់ដែលចាំបាច់ទៀតផង» ព្រោះមន្ទីរទាំងនេះជាកំលាំងសទ្ធាមុតមាំក្នុងព្រះពុទ្ធសាសនាជាសាធារណូបការ ដែលជាការបុណ្យកុសល្យព្រះបាទ



www.elibraryofcambodia.org

ជ័យវរ្ម័នទី៧ ទើបមានព្រះបរមរាជអង្ការប្រកាសអោយសិទ្ធិពិសេសដល់អ្នកជំងឺដែលចូលព្យាបាលក្នុងមន្ទីរពេទ្យពោលគឺអ្នកទោស (មកពីតំបន់ផ្សេង) ឬមានទោសមកជាមួយប្រសិនបើមានអ្នកជំងឺធ្វើដំណើរមកព្យាបាលក្នុងមន្ទីរពេទ្យក៏សមគួរលើកលែងទោសអោយ។ តែសំរាប់ប្រជារាស្ត្រក្នុងតំបន់ដែលមានមន្ទិរពេទ្យបើចូលចិត្តធ្វើបាបអ្នកដ៏ទៃ ត្រូវដាក់ទោសនិងមិនគួរលើកលែងទោសអោយ។ ច្បាប់បែបនេះជាបង្ហាញអោយយើងឃើញថាតំបន់ដែលសង់មន្ទីរនោះត្រូវចាត់ទុកជាតំបន់ព្រះពុទ្ធសាសនាប្រជារាស្ត្រគួរតែជាប្រជារាស្ត្រល្អមានសីលធម៌ផងដែរ។ ព្រោះចាត់ទុកថា មន្ទីរពេទ្យនីមួយៗជាមជ្ឈមណ្ឌលរួកផ្នែកចិត្តគំនិត និងជំនឿដោយមានព្រះវិហារព្រះភៃសជ្ជគុរុ ដែលព្រះអង្គនិងផ្តល់នូវសេចក្តីសុខព្រមទាំងកំចាត់នូវជំងឺបៀតបៀនទាំងឡាយ។

ឧទាហរណ៍ការចាត់ការបំរើការងារនៅប្រាសាទតាមាន់តូចអាចសរុបបានដូចខាងក្រោមនេះ÷

១. មន្ត្រី៣នាក់ ដែលបញ្ជូនមកពីរាជធានីអង្គរធំ២នាក់មានតួនាទីជាអ្នករៀបចំប្រកបពិធីកម្មខាងសាសនា និង១នាក់ទៀតជាហោរាចារ្យ។

២. ពេទ្យធំ២នាក់ ជាអ្នកជំនាញការគឺគ្រូពេទ្យអាយុវេជ្ជនិងគ្រូពេទ្យអស្ត្រវេជ្ជ (ពេទ្យព្យាបាលជំងឺទូទៅ)។

៣. បុគ្គលិកដាំបាយមានប្រធាន២នាក់និងសហការី៦នាក់ទៀតរួម៨នាក់២នាក់ជាធ្វើស្លិតិ។



www.elibraryofcambodia.org

៤. បុគ្គលិកធ្វើស្ថិតិ(ធ្វើបញ្ជី)បុរស១នាក់និងស្ត្រី២នាក់ (រួម៨នាក់)។

៥. បុគ្គលិកប្រុស២នាក់ជាអ្នកថែរក្សាទ្រព្យនិងបើកថ្នាំ ព្រមទាំងតួនាទីទទួលនិងរកអុស (ទំនងជាមានអ្នកស្រុកឬសម្បុរសជនមកបរិចាគចំនួនច្រើន ទើបបង្កើតអោយមានរង់ចាំទទួល)។

៦. បុគ្គលិកបុរស២នាក់ជាអ្នកថែរក្សាទ្រព្យសម្បត្តិនិងបើកទឹក មានតួនាទីរកស្មៅនិងផ្កាមកបូជាព្រះបដិមាការនិងសំអាតសាសនស្ថាន។

៧. បុគ្គលិក២នាក់ជាអ្នកចាត់ធ្វើពលីទានធ្វើប័ត្រ ធ្វើប័ត្រផ្លាស់ និងមានតួនាទីរកអុសសំរាប់ដាំថ្នាំ។

៨. បុគ្គលិកដែលជាអ្នកជំនួយការពេទ្យមានបុរស១៤នាក់ ជាអ្នកថែរក្សាមន្ទីរពេទ្យនិងបុរស៨នាក់ទៀតជាអ្នកជួយយកថ្នាំពេទ្យ (រួម២២នាក់)

៩. បុគ្គលិកបុកថ្នាំ៦នាក់ និងអ្នកធ្វើស្ថិតិ មានប្រធានជាស្ត្រី១នាក់និងបុរស១នាក់ (រួម៨នាក់)។

១០. ក្រៅពីនេះនៅមានអ្នកបំរើការងារផ្សេងៗទៀតចំនួន ៣២នាក់។

រួមបុគ្គលិកដែលបំរើការងារនៅក្នុងមន្ទីពេទ្យនេះទាំងអស់ចំនួនប្រមាណ៥០នាក់។ ចំណែកមន្ទីរពេទ្យផ្សេងៗទៀតក៏ដូចគ្នានេះផងដែរគ្រាន់មានចំនួនច្រើន ឬតិចទៅតាមទំហំរបស់មន្ទីរពេទ្យនីមួយៗតែប៉ុណ្ណោះ។



www.elibraryofcambodia.org

## ៣.៧ ឧបករណ៍ផលិតឱសថបុរាណដែលរកឃើញនៅក្នុងមន្ទីរពេទ្យ

តាមរយៈការស្រាវជ្រាវយើងមិនអាចរកឃើញឧបករណ៍ផ្សេងៗក្រៅពីថ្មបុកថ្នាំជាច្រើនប្រភេទដូចជាថ្មបុកថ្នាំត្បាល់បុកថ្នាំជាច្រើនប្រភេទ ព្រមទាំងអង្រែរខ្នាតតូចៗជាច្រើន។ សន្និដ្ឋានថា ទាំងនេះជាឧបករណ៍សំរាប់ផលិតថ្នាំព្យាបាលអ្នកជំងឺ





www.elibraryofcambodia.org

តាមរយៈអត្ថបទក្នុងសិលាចារឹក យើងអាចសរុបឱសថដែលប្រើប្រាស់ក្នុងមន្ទីរពេទ្យរបស់ព្រះបាទជ័យវរ្ម័នទី៧បានដូចខាងក្រោមនេះ÷

ត្រីស្លា ទៀនក្រមួន ទឹកឃ្មុំ ខ្លាញ់ ស្រូបសាលី ប៊ុននាគ ចន្ទទេស ក្រវានតូច ក្រវានធំ កាំញាន អំបិល មហាហិង្គ សណ្តែកវែង ទឹកត្នោតក្ងួរ ឈើចន្ទ ជ័រឈើ ផ្កាឈើមួយរយមុខ ម្រេច ទឹកខ្ទឹម ស្លឹកជី ត្រកួន ត្របកខ្ទឹម ផ្លែពុទ្រា ។ល។



www.elibraryofcambodia.org

## ៣.៨ ចំនួនបន្ទីរបន្ទៀវដែលបានកេឃើញតាមបន្ទប្រទ្ធ

### ១. ក្នុងព្រះរាជាណាចក្រកម្ពុជាមានដូចជា

១. ប្រាសាទតាព្រហ្មកិល



២. ប្រាសាទគោគរោគ ខេត្តកំពង់ធំ

៣. ប្រាសាទបន្ទាយភ្លើង ខេត្តកំពង់ធំ

៤. ប្រាសាទនៅខាងកើតប្រាសាទរាកែវ (មិនស្គាល់ឈ្មោះ)

៥. ប្រាសាទតុកកែពង ខេត្តបាត់ដំបង

៦. ប្រាសាទវត្តព្រះនាង ខេត្តកំពង់ធំ

៧. ព្រមទាំងមានប្រាសាទ ៤កន្លែងនៅក្រៅរាជធានីអង្គរធំ។



www.elibraryofcambodia.org

បើសិនជាឈ្មោះប្រាសាទខាងលើមានការខុសឆ្គងយ៉ាងណានោះ អ្នករៀបរៀងសូមអភ័យទោសក្នុងឱកាសនេះផងដែរព្រោះអ្នករៀបរៀងសរសេរអត្ថបទនេះ គឺកំពុងសិក្សានៅប្រទេសថៃនៅឡើយអ្នករៀបរៀងមានឯកសារតិចតួចបំផុតស្តីពីប្រាសាទ ដែលជាសាសនស្ថានប្រចាំមន្ទីរពេទ្យ នៅប្រទេសខ្មែរ។

**២. ក្នុងសាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវចំនួន១** កន្លែង គឺប្រាសាទសាយហ្វុង (sayfong) សព្វថ្ងៃស្ថិតនៅជាប់ វៀងចន្ទរដ្ឋធានីរបស់ប្រទេសឡាវ ក្នុងប្រាសាទនេះផងដែរត្រូវបានគេរកឃើញសិលាចារឹកប្រចាំមន្ទីរដំបូងបំផុត ហើយត្រូវបានបកប្រែដំបូងបំផុតដែលធ្វើអោយយើងដឹងអំពីការសាងសង់មន្ទីរនៅសម័យព្រះបាទជ័យវរ្ម័នទី៧។ ដូចនេះអាចចាត់បានថា សិលាចារឹកនេះជាប្រភពឯកសារដ៏សំខាន់មួយស្តីអំពីរជ្ជកាលរបស់អង្គ។ ហើយតាមរយៈអត្ថបទសិលាចារឹកនេះផងដែរបានបង្ហាញថា មន្ទីរពេទ្យនេះជាមន្ទីរពេទ្យដែលមានទំហំធំបំផុតមួយក្នុងចំណោមមន្ទីរពេទ្យផ្សេងៗទៀតក្នុងអាណាចក្រខ្មែរនាសម័យនោះ ព្រោះបានបញ្ជាក់ថា មានបុគ្គលិកបំរើការងាររហូតដល់៩៨នាក់។



www.elibraryofcambodia.org



រូបព្រះបាទជ័យវរ្ម័នទី៧ក្នុងទំរង់ពុទ្ធរាជា ក្នុងប្រាសាទសាយហ្វង
សព្វថ្ងៃដំកល់ទុកនៅសារៈមន្ទីរជាតិក្រុងវៀងចន្ទ



www.elibraryofcambodia.org

## ៣. ក្នុងព្រះរាជាណាចក្រថៃ

ចំណុចដែលដែលគួរអោយយើងពិចារណាផងដែរនោះ គឺបណ្តាមន្ទីរពេទ្យដែលបានរកទាំងនោះភាគច្រើននៅភាគឦសានប្រទេសថៃបច្ចុប្បន្ន ដែលគ្របដណ្តប់ចំនួន១៩ខេត្តក្រុង ដែលសន្និដ្ឋានបានថា ដំបន់នេះមជ្ឈមណ្ឌលដ៏សំខន់មួយរបស់ព្រះបាទជ័យវរ្ម័នទី៧។

សព្វថ្ងៃសាសនស្ថានប្រចាំមន្ទីរទាំងនេះមួយភាគធំបានតាំងនៅជាមួយវត្តអារាម ហើយពុទ្ធបរិស័ទក៏ព្រះសង្ឃបានចាត់ទុកសាសនស្ថានជាកន្លែងស័ក្តិសំរាប់គោរពប្រតិបត្រ។



www.elibraryofcambodia.org

*ខាងក្រោមនេះជាចំនួនសាសនស្ថានប្រចាំមន្ទីរពេទ្យដែលមាននៅប្រទេសថៃ÷*

**១. ប្រាសាទមឿងកៅ** (Prasat Muang Kao) ស្ថិតនៅក្នុងស្រុកស្ទឹងនើន (Soungnoeun District) **ខេត្តនគររាជសីមា** (Nakhonrattasima Province)




ប្រាសាទមឿងកៅ នៅចំកណ្តាលជាប្រាសាទប្រាធាន ចំពីមុខជាគោបុរះ និងនៅទិសខាងកើតឆៀងខាងត្បូងជាបណ្ណាល័យ។



www.elibraryofcambodia.org



ស្រះទឹកប្រាសាទមៀងកៅក្រាលដោយថ្មបាយក្រៀមចំកណ្ដាលប្រាសាទមានប្រាសាទប្រធានមួយសង់ដោយថ្មបាយក្រៀម ដែលព័ទ្ធជុំវិញដោយកំពែងថ្មបាយក្រៀម។ និងមានទ្វាចូលពីទិសខាងកើត ចំណែកពាទិសទៀតជាទ្វារបញ្ឆោត។ នៅទិសខាងខាងកើតឆៀងខាងត្បូងមានបណ្ណាល័យមួយ និងនៅខាងក្រៅកំពែងទិសខាងកើតឆៀងខាងជើងមានស្រះទឹកមួយ។



www.elibraryofcambodia

២. **ប្រាសាទពលសង្គ្រាម** (Prasat Pornsangkram) ស្ថិតនៅក្នុងស្រុកស៊ូងនើន (Soungnoeun District) **ខេត្ត នគររាជសីមា** (Nakhonrattasima Province)

ជាប្រាសាទសង់ដោយថ្មបាយក្រៀមព័ទ្ធជុំវិញដោយកំពែងថ្មបាយក្រៀម និងមានទ្វាចូលពីទិសខាងកើត តែសព្វថ្ងៃប្រាសាទនេះបានដួលរលំស្ទើរតែអស់ទៅហើយ។ នៅនៅទិសខាងខាងកើតឆៀងខាងត្បូងមានបណ្ណាល័យមួយ និងនៅខាងកំពែងទិសខាងកើតឆៀងខាងជើងមានស្រះ ទឹកមួយរាង៤ជ្រុងទ្រវែង។



www.elibraryofcambodia.org

**៣. ប្រាសាទប្រាង្គគូ** (Prasat Prangku) **ស្ថិតនៅក្នុងស្រុកមឿង** (Muang District) **ខេត្តជ័យភូមិ** (Chaiyapum Province) -



ប្រាសាទប្រាង្គគូ

ជាប្រាសាទសង់ដោយថ្មបាយក្រៀមព័ទ្ធជុំវិញដោយកំពែងថ្មបាយក្រៀម មានទ្វារចូលពីទិសខាងកើតចំណែកទ្វារពាទិសទៀតជាទ្វារបញ្ឆោត។ នៅទិសខាងខាងកើតឆៀងខាងត្បូងមានបណ្ណាល័យមួយ និងនៅខាងកំពែងទិសខាងកើតឆៀងខាងជើង មានស្រះទឹកមួយរាងបួនជ្រុងទ្រវែង។



www.elibraryofcambodia.org

**៤. ប្រាសាទប្រាង្គគូ** (Prasat Prangku) **ស្ថិតនៅស្រុកបានថែន** (BanthanDistrict) **ខេត្តជ័យភូមិ** (Chaiyapum Province) ជាប្រាសាទសង់ដោយថ្មបាយក្រៀមព័ទ្ធជុំវិញដោយកំពែងថ្មបាយក្រៀម។ និងមានទ្វារចូលពីទិសខាងកើត ចំណែកទ្វារពាទិសទៀតជាទ្វារញ្ញោត។ នៅទិសខាងខាងកើតឆៀងខាងត្បូងមានបណ្ណាល័យមួយនិងនៅខាងកំពែងទិសខាងកើតឆៀងខាងជើង មានស្រះទឹកមួយរាងបួនជ្រុងទ្រវែង។



ប្រាសាទប្រាង្គគូ



www.elibraryofcambodia.org

**៩. ប្រាសាទគូកែវ** (Prasat kukao) **ស្ថិតនៅក្នុងស្រុកមឿង** (Muang District) **ខេត្តខនកែន** (Konken Province)

ជាប្រាសាទសង់ដោយថ្មបាយក្រៀមព័ទ្ធជុំវិញដោយកំពែងថ្មបាយក្រៀម និងមានទ្វារចូលពីទិសខាងកើតនៅទិសខាងខាងកើតឆៀងខាងត្បូងមានបណ្ណាល័យមួយ និងនៅទិសខាងកើតឆៀងខាងជើងមានស្រះទឹកមួយ សព្វថ្ងៃប្រាសាទនេះកំពុងទទួលរងនូវខូចខាតយ៉ាងធ្ងន់ធ្ងរផងដែរ។ នៅប្រាសាទនេះគេបានរកឃើញសិលាចារឹកប្រចាំមន្ទីរពេទ្យ ព្រមទាំងរូបព្រះពោធិសត្វជាច្រើនអង្គទៀត។



www.elibraryofcambodia.org

**៦. ប្រាសាទគូប្រផាជ័យ** (Prasat kuprapachai) ស្ថិតនៅក្នុងស្រុកណាមផង (Nampong District) ខេត្តខនកេន (Konken Province)

ជាប្រាសាទសង់ដោយថ្មបាយក្រៀមព័ទ្ធជុំវិញដោយកំពែងថ្មបាយក្រៀម និងមានទ្វារចូលពីទិសខាងកើតចំណែកទ្វារ៣ទៀតជាទ្វារបិទ។ នៅទិសខាងខាងកើតឆៀងខាងត្បូងមានបណ្ណាល័យមួយនិងនៅទិសខាងកំពែងទិសខាងកើតឆៀងខាងជើង មានស្រះទឹកមួយរាងបួនជ្រុងទ្រវែងក្រាលដោយថ្មបាយក្រៀម។



ប្រាសាទគូប្រផាជ័យ



www.elibraryofcambodia.org

### ៧. ប្រាសាទគូកែវបានជីត (Prasatkukeovbanchet) ស្ថិតនៅស្រុកគូកែវ (Kukao District)

ជាប្រាសាទសង់ដោយថ្មបាយក្រៀមព័ទ្ធជុំវិញដោយកំពែងថ្មបាយក្រៀម និងមានទ្វារចូលពីទិសខាងកើតនៅទិសខាងខាងកើតឆៀង ខាងត្បូងមានបណ្ណាល័យមួយនិងនៅទិសខាងកំពែងទិសខាងកើតឆៀងខាងជើងមានស្រះទឹកមួយរាងបួនជ្រុងទ្រវែង សព្វថ្ងៃនេះប្រាសាទបានបាក់បែកស្ទើរអស់ទៅហើយ។



www.elibraryofcambodia.org

**៨. ប្រាសាទគូពន្នា** (Prasat Kupana) **ស្ថិតនៅស្រុកស្វាងដែនឌិន (Prasat** Svangdebden District) **ខេត្តសកលនគរ** (Sakolnakhon Province)




ជាប្រាសាទសង់ដោយថ្មបាយក្រៀមព័ទ្ធជុំវិញដោយកំពែងថ្មបាយក្រៀម និងមានទ្វារចូលពីទិសខាងកើតចំណែកទ្វារ៣ទៀតជាទ្វារបញ្ឆោត នៅទិសខាងខាងកើតឆៀងខាងត្បូងមានបណ្ណាល័យមួយ និងនៅខាងកំពែងទិសខាងកើតឆៀងខាងជើងមានស្រះទឹកមួយរាងបួនជ្រុងទ្រវែង។



www.elibraryofcambodia.org

៩. **ប្រាសាទប្រាង្គគូ** (Prsasat Prangku) ស្ថិតនៅស្រុកធវ្របុរី (Thavahtaburi District) ខេត្តរយអិត (Roi et Province)

ជាប្រាសាទសង់ដោយថ្មបាយក្រៀមព័ទ្ធជុំវិញដោយកំពែងថ្មបាយក្រៀម និងមានទ្វារចូលពីទិសខាងកើតកើតចំណែកទ្វារ៣ទៀត ជាទ្វារបញ្ឆោត នៅទិសខាងខាងកើតឆៀងខាងត្បូងមានបណ្ណាល័យមួយ និងនៅទិសខាង កំពែងទិសខាងកើតឆៀងខាងជើងមានស្រះទឹកមួយរាងបួនជ្រុងទ្រវែង។



www.elibraryofcambodia.org

**១០. ប្រាសាទបានវៅ** (Prasat BanKvao) ស្ថិតនៅក្នុងស្រុកមឿង (Muang District) ខេត្តមហាសារខាម (Mahasarakam Proving)




ប្រាសាទបានវៅ

ជាប្រាសាទសង់ដោយថ្មបាយក្រៀមព័ទ្ធជុំវិញដោយកំពែងថ្មបាយក្រៀម និងមានទ្វារចូលពីទិសខាងកើតចំណែកទ្វារពាទៀតជាទ្វារបញ្ឆោត។ នៅទិសខាងខាងកើតឆៀងខាងត្បូង មានបណ្ណាល័យមួយនិងនៅទិសខាងកំពែងទិសខាងកើតឆៀងខាងជើង មានស្រះទឹកមួយរាងបួនជ្រុងទ្រវែង។



www.elibraryofcambodia.org

**១១. ប្រាសាទគូសន្តរតន៍** (Prasat Kusantaratana) ស្ថិតនៅក្នុងស្រុកណាដូន (Nadoun District) ខេត្តមហាសារាខាម ( Mahasarakam Province)




ជាប្រាសាទសង់ដោយថ្មបាយក្រៀមព័ទ្ធជុំវិញដោយកំពែងថ្មបាយក្រៀម និងមានទ្វារចូលពីទិសខាងកើតចំណែកទ្វារ៣ទៀតជាទ្វារបញ្ឆោត។ នៅទិសខាងខាងកើតឆៀងខាងត្បូង មានបណ្ណាល័យមួយនិងនៅទិសខាងកំពែងទិសខាងកើតឆៀងខាងជើង មានស្រះទឹកមួយរាងបួនជ្រុងទ្រវែង។



www.elibraryofcambodia.org

**១២. ប្រាសាទគូពោនរគំង** (Prasat Kuponrakang) ស្ថិតនៅក្នុងស្រុកក្សេត្រវិស័យ (Ksetvesai District) ខេត្តរយអិត (Roiet Province)



ជាប្រាសាទសង់ដោយថ្មបាយក្រៀមព័ទ្ធជុំវិញដោយកំពែងថ្មបាយក្រៀម និងមានទ្វារចូលពីទិសខាងកើតចំណែកទ្វារ៣ទៀតជាទ្វារបញ្ឆោត។ នៅទិសខាងកើតឆៀងខាងត្បូងមានបណ្ណាល័យមួយ និងនៅទិសខាងកំពែងទិសខាងកើតឆៀងខាងជើងមានស្រះទឹកមួយរាងបួនជ្រុងទ្រវែង។



www.elibraryofcambodia.org

**១៣. ប្រាសាទគូគន្ធានាម** (Prasat Kuchantanam) ស្ថិតនៅក្នុងស្រុកពោនសាយ (Ponsay District) ខេត្តរយអិត (RoietProvince)។

ជាប្រាសាទសង់ដោយថ្មបាយក្រៀមព័ទ្ធជុំវិញដោយកំពែងថ្មបាយក្រៀម និងមានទ្វារចូលពីទិសខាងកើតចំណែកទ្វារ៣ទៀតជាទ្វារបញ្ឆោត។ នៅទិសខាងខាងកើតឆៀងខាងត្បូងមានបណ្ណាល័យមួយ និងនៅទិសខាងកំពែងទិសខាងកើតឆៀងខាងជើងមានស្រះទឹកមួយរាងបួនជ្រុងទ្រវែង។



www.elibraryofcambodia.org

**១៤. ប្រាសាទចមព្រះ** (Prasat chompra) ស្ថិតនៅក្នុងស្រុកចមព្រះ (Chompra District) ខេត្តសុរិន្ទ្រ (Surin Province)។



ស្រះទឹកប្រាសាទចមព្រះ

ជាប្រាសាទសង់ដោយថ្មបាយក្រៀមព័ទ្ធជុំវិញដោយកំពែងថ្មបាយក្រៀម និងមានទ្វារចូលពីទិសខាងកើតចំណែកទ្វារ៣ទៀតជាទ្វារបញ្ឆោត។ នៅទិសខាងខាងកើតឆៀងខាងត្បូងមានបណ្ណាល័យមួយ និងនៅទិសខាងកំពែងទិសខាងកើតឆៀងខាងជើងមានស្រះទឹកមួយរាងបួនជ្រុងទ្រវែង។



www.elibraryofcambodia.org

**១៥. ប្រាសាទកំពែងណយ** (Prasat Kompengnoi) ស្ថិតនៅក្នុងស្រុកមឿង (Muang District) ខេត្តស៊ីសះកេត(Sisaket Province)



ជាប្រាសាទសង់ដោយថ្មបាយក្រៀមព័ទ្ធជុំវិញដោយកំពែងថ្មបាយក្រៀម និងមានទ្វារចូលពីទិសខាងកើតកើតចំណែកទ្វារពាទៀតជាទ្វារបញ្ឆោត នៅទិសខាងកើតឆៀងខាងត្បូងមានបណ្ណាល័យមួយ និងនៅទិសខាងកំពែងទិសខាងកើតឆៀងខាងជើងមានស្រះទឹកមួយរាងបួនជ្រុងទ្រវែង។



www.elibraryofcambodia.org

**១៦. ប្រាសាទបានឈ្នាង** (Prasat BanChnien) ស្ថិតនៅក្នុងស្រុកមឿង (Muang District) ខេត្តសុរិន្ទ្រ (Surin Province)។ ប្រាសាទនេះសព្វថ្ងៃគេធ្វើព្រះវិហារសង្កត់ពីលើគ្រឹះដែលជាព្រះសាសនស្ថានប្រចាំមន្ទីរពេទ្យ (មេត្តាមើលរូបនៅទំព័រទី១១៨)ទិសខាងកើតឆៀងខាងជើងមានស្រះទឹកមួយរាងបួនជ្រុងទ្រវែង។

**១៧. ប្រាសាទបានឆាងពី** (Prasat Babchangpee) ស្ថិតនៅក្នុងស្រុកស៊ីខរភូមិ (Sicharapom District) ខេត្តសុរិន្ទ្រ (Surin Province)

ជាប្រាសាទសង់ដោយថ្មបាយក្រៀមព័ទ្ធជុំវិញដោយកំពែងថ្មបាយក្រៀម និងមានទ្វារចូលពីទិសខាងកើតចំណែកទ្វារពាទៀតជាទ្វារបញ្ឆោត។ នៅទិសខាងខាងកើតឆៀងខាងត្បូងមានបណ្ណាល័យមួយ និងនៅទិសខាងកំពែងទិសខាងកើតឆៀងខាងជើងមានស្រះទឹកមួយរាងបួនជ្រុងទ្រវែង។



www.elibraryofcambodia.org

**១៨. ប្រាសាទបានស្នោ** (Prsat bansno) ស្ថិតនៅស្រុកបានប្រាងគូ (Prangku District) ខេត្តស៊ីសះកេត (Sisaket Province)។



ជាប្រាសាទសង់ដោយថ្មបាយក្រៀមព័ទ្ធជុំវិញដោយកំពែងថ្មបាយក្រៀម និងមានទ្វារចូលពីទិសខាងកើតកើតចំណែកទ្វារពាទៀតជាទ្វារបញ្ឆោត។ នៅទិសខាងខាងកើតឆៀងខាងត្បូងមានបណ្ណាល័យមួយ និងនៅទិសខាងកំពែងទិសខាងកើតឆៀងខាងជើងមានស្រះទឹកមួយរាងបួនជ្រុងទ្រវែង។



www.elibraryofcambodia.org

**១៩. ប្រាសាទកំងអេន** (Prasat kanan) ស្ថិតនៅក្នុងស្រុកសង្ខះ (Sanka District) ខេត្តសុរិន្ទ្រ (Surin Province)។

ជាប្រាសាទសង់ដោយថ្មបាយក្រៀមព័ទ្ធជុំវិញដោយកំពែងថ្មបាយក្រៀម និងមានទ្វារចូលពីទិសខាងកើតចំណែកទ្វារពាទៀតជាទ្វារបញ្ឆោត។ នៅទិសខាងកើតឆៀងខាងត្បូងមានបណ្ណាល័យមួយ និងនៅទិសខាងកំពែងទិសខាងកើតឆៀងខាងជើងមានស្រះទឹកមួយរាងបួនជ្រុងទ្រវែង។



www.elibraryofcambodia.org

**២០. ប្រាសាទមាន់តូច** (Prasat Tamuantoc) ស្ថិតនៅលើភ្នំដងរែក ខេត្តសុរិន្ទ្រ



ទិដ្ឋភាពពីទិសពាយ័ព្យសាទដោយមានស្រះទឹកភ្ជាប់មកជាមួយ



ទិដ្ឋភាពពីទិសអាគ្នេយ៍នៅទិសចំមុខជាគោបុរៈ ទិសអាគ្នេយ៍ជាបណ្ណាល័យ



www.elibraryofcambodia.org

ជាសាសនស្ថានដែលនៅល្អបំផុតក្នុងបណ្ដាសាសនស្ថានដែលបានរកសព្វថ្ងៃ។ ជាប្រាសាទសង់ដោយថ្មបាយក្រៀមនិងថ្មភក់ព័ទ្ធជុំវិញដោយកំពែងថ្មបាយក្រៀមនិងមានទ្វារចូលពីទិសខាងកើត ចំណែកទ្វារពាទៀតជាទ្វារបញ្ឆោត នៅទិសខាងខាងកើតឆៀងខាងត្បូងមានបណ្ណាល័យមួយ និងនៅទិសខាងកំពែងទិសខាងកើតឆៀងខាងជើងមានស្រះទឹកមួយរាងបួនជ្រុងទ្រវែង។



www.elibraryofcambodia.org

**២១. ប្រាសាទបានគោគងិវ** (Prasat Kukngev) ស្ថិតនៅក្នុងស្រុកប្រាខាំ (Prachum District) ខេត្តបុរីរម្យ៍ (Burirum Province)។



ជាប្រាសាទសង់ដោយថ្មបាយក្រៀមព័ទ្ធជុំវិញដោយកំពែងថ្មបាយក្រៀម និងមានទ្វារចូលពីទិសខាងកើតចំណែកទ្វារ៣ទៀតជាទ្វារបញ្ឆោត។ នៅទិសខាងខាងកើតឆៀងខាងត្បូងមានបណ្ណាល័យមួយ និងនៅទិសខាងកំពែងទិសខាងកើតឆៀងខាងជើងមានស្រះទឹកមួយរាងបួនជ្រុងទ្រវែង។



www.elibraryofcambodia.org

**២២. ប្រាសាទគោកមឿង** (Prasat Kukmuang) ស្ថិតនៅក្នុងស្រុកប្រគោនជ័យ (PraChonchai District) ខេត្តបុរីរម្យ (Burirum Province)

ជាប្រាសាទសង់ដោយថ្មបាយក្រៀមព័ទ្ធជុំវិញដោយកំពែងថ្មបាយក្រៀម និងមានទ្វារចូលពីទិសខាងកើតចំណែកទ្វារ៣ទៀតជាទ្វារបញ្ឆោត។ នៅទិសខាងខាងកើតឆៀងខាងត្បូងមានបណ្ណាល័យមួយ និងនៅទិសខាងកំពែងទិសខាងកើតឆៀងខាងជើងមានស្រះទឹកមួយរាងបួនជ្រុងទ្រវែង។



www.elibraryofcambodia.org

**២៣. ប្រាសាទណាងប៊ូរាយ** (Prasat noibouray) ស្ថិតនៅក្នុងស្រុកប្រគោនជ័យ (PraChonchai District) ខេត្តបុរីរម្យ (Burirum Province)។



ជាប្រាសាទសង់ដោយថ្មបាយក្រៀមព័ទ្ធជុំវិញដោយកំពែងថ្មបាយក្រៀម និងមានទ្វារចូលពីទិសខាងកើតចំណែកទ្វារ៣ទៀតជាទ្វារបញ្ឆោត។ នៅទិសខាងខាងកើតឆៀងខាងត្បូងមានបណ្ណាល័យមួយ និងនៅទិសខាងកំពែងទិសខាងកើតឆៀងខាងជើងមានស្រះទឹកមួយរាងបួនជ្រុងទ្រវែង។



www.elibraryofcambodia.org

**២៤. ប្រាសាទគរបុរី** (Prasat Konburi) ស្ថិតនៅស្រុកគរបុរី (Konburi Dstrict) ខេត្តនគររាជសីមា (Nakhonratasima Province)។

ជាប្រាសាទសង់ដោយថ្មបាយក្រៀមព័ទ្ធជុំវិញដោយកំពែងថ្មបាយក្រៀម និងមានទ្វារចូលពីទិសខាងកើតចំណែកទ្វារ៣ទៀតជាទ្វារបញ្ឆោត។ នៅទិសខាងខាងកើតឆៀងខាងត្បូងមានបណ្ណាល័យមួយ និងនៅទិសខាងកំពែងទិសខាងកើតឆៀងខាងជើងមានស្រះទឹកមួយរាងបួនជ្រុងទ្រវែង។






www.elibraryofcambodia.org

**២៥. ប្រាសាទស្រះផ្លែង** (Prasat saplang) ស្ថិតនៅក្នុងស្រុក ជោគជ័យ (Chorkchai District) ខេត្ត នគររាជសីមា (Nakhonratasima Province)

ជាប្រាសាទសង់ដោយថ្មបាយក្រៀមព័ទ្ធជុំវិញដោយកំពែងថ្មបាយក្រៀម និងមានទ្វារចូលពីទិសខាងកើតចំណែកទ្វារ៣ទៀតជាទ្វារបញ្ឆោត។ នៅទិសខាងខាងកើតឆៀងខាងត្បូងមានបណ្ណាល័យមួយ និងនៅខាងក្រៅកំពែងទិសខាងកើតឆៀងខាងជើងមានស្រះទឹកមួយរាងបួនជ្រុងទ្រវែង។

**២៦. ប្រាសាទបានប្រាង្គ** (Prasat Banprang) ស្ថិតនៅក្នុងស្រុកហួតថ្លែង (Tuoythlang District) ខេត្តនគររាជសីមា (Nakonratasima Province)។

ជាប្រាសាទសង់ដោយថ្មបាយក្រៀមព័ទ្ធជុំវិញដោយកំពែងថ្មបាយក្រៀម និងមានទ្វារចូលពីទិសខាងកើតចំណែកទ្វារ៣ទៀតជាទ្វារបញ្ឆោត។ នៅទិសខាងខាងកើតឆៀងខាងត្បូងមានបណ្ណាល័យមួយ និងនៅខាងក្រៅកំពែងទិសខាងកើតឆៀងខាងជើងមានស្រះទឹកមួយរាងបួនជ្រុងទ្រវែង។



www.elibraryofcambodia.org

**២៧. ប្រាសាទកុដិឫស្សី** (Prasatkuterisi) ស្រុកភិម៉ាយ (Pimai District) ខេត្តនគររាជសីមា (Nakhonratasima Province)

ជាប្រាសាទសង់ដោយថ្មបាយក្រៀមព័ទ្ធជុំវិញដោយកំពែងថ្មបាយក្រៀម និងមានទ្វារចូលពីទិសខាងកើតចំណែកទ្វារ៣ទៀតជាទ្វារបញ្ឆោត។ នៅទិសខាងខាងកើតឆៀងខាងត្បូងមានបណ្ណាល័យមួយ និងនៅខាងក្រៅកំពែងទិសខាងកើតឆៀងខាងជើងមានស្រះទឹកមួយរាងបួនជ្រុងទ្រវែង។

**២៨. ប្រាសាទនាងរាំ** (Prasat Nangram) ស្ថិតនៅក្នុងស្រុក ប្រផាយ (Prapay District) ខេត្តនគររាជសីមា (Nakhonratasima Province)

ជាប្រាសាទសង់ដោយថ្មបាយក្រៀមព័ទ្ធជុំវិញដោយកំពែងថ្មបាយក្រៀម និងមានទ្វារចូលពីទិសខាងកើតចំណែកទ្វារ៣ទៀតជាទ្វារបញ្ឆោត។ នៅទិសខាងកើតឆៀងខាងត្បូងមានបណ្ណាល័យមួយ និងនៅទិសខាងកំពែងទិសខាងកើតឆៀងខាងជើងមានស្រះទឹកមួយរាងបួនជ្រុងទ្រវែង។



www.elibraryofcambodia.org

**២៩. ប្រាសាទកុដិឬស្សី** (Prasat kuteris) ស្ថិតនៅក្នុងស្រុកបាមមៃថៃយាផុត (Banmaithaiyapuch District) ខេត្តបុរីរម្យ (Buriram Province)





ជាប្រាសាទសង់ដោយថ្មបាយក្រៀមព័ទ្ធជុំវិញដោយកំពែងថ្មបាយក្រៀម និងមានទ្វារចូលពីទិសខាងកើតចំណែកទ្វារពាទៀតជាទ្វារបញ្ឆោត។ នៅទិសខាងកើតឆៀងខាងត្បូងមានបណ្ណាល័យមួយ និងនៅខាងក្រៅកំពែងទិសខាងកើតឆៀងខាងជើងមានស្រះទឹកមួយ រាងបួនជ្រុងទ្រវែង។



www.elibraryofcambodia.org

៣០. **ប្រាសាទប្រផាជ័យ** (Prasat Prapachai) ស្ថិតនៅក្នុងស្រុកប្រាសាទ ខេត្តនគររាជសិមា (Nakhonrattasima Province)

ជាប្រាសាទសង់ដោយថ្មបាយក្រៀមព័ទ្ធជុំវិញដោយកំពែងថ្មបាយក្រៀម និងមានទ្វារចូលពីទិសខាងកើតចំណែកទ្វារ៣ទៀតជាទ្វារបញ្ឆោត។ នៅទិសកើតឆៀងខាងត្បូងមានបណ្ណាល័យមួយ និងនៅខាងក្រៅកំពែងទិសខាងកើតឆៀងខាងជើងមានស្រះទឹកមួយរាងបួនជ្រុងទ្រវែង។

៣១. បុរាណស្ថានបុរាណក្រុងស្រីមហោសថស្ថិតនៅខេត្តប្រាជិនបុរីនៅភាគខាងកើតក្រុងបាងកក ជាសាសនាមន្ទីរមន្ទីរពេទ្យដ៏សំខាន់មួយរបស់ព្រះបាទជ័យវរ្ម័នទី៧។



www.elibraryofcambodia.org

ទំរង់ប្លង់ជាទូទៅរបស់សាសនស្ថានប្រចាំមន្ទីរពេទ្យ






www.elibraryofcambodia.org

## ៤. គមនាគមន៍និងធម្មសាលា

ក្រៅពីវិស័យសុខាភិបាលដូចដែលយើងបានសិក្សារួចមកហើយ តែនៅមានវិស័យដ៏សំខាន់មួយទៀត ដែលសព្វថ្ងៃគេចាត់ទុកជាបណ្តាញសរសៃរឈាម។ បើក្នុងខ្លួនមនុស្សយើងសរសៃរឈាមត្រូវ ឬពិការដោយប្រការណាមួយនោះ វាអាចបណ្តាលខ្លួនយើងស្លាប់ឬពិការបានយ៉ាងណាមិញប្រទេសមួយក៏ដូចគ្នាបើសិនខ្វះនូវផ្លូវគមនាគមន៍ហើយនោះ វាប្រៀបដូចជាប្រទេសពិការដែរ ព្រោះវាអោយចរាចរណ៍ផ្សេងត្រូវរាំងស្ទះ ឬមិនអាចប្រព្រឹត្តិទៅបានស្រួល។

អាណាចក្រខ្មែរនាសម័យព្រះបាទជ័យវរ្ម័នទី៧ វិស័យគមនាគមន៍ជាវិស័យមួយដែលត្រូវបានព្រះអង្គយកព្រះទ័យទុកដាក់ ព្រមទាំងបានស្ថាបនាឡើងកាត់ខ្វាត់ខ្វែងទូទាំងរាជអាណាចក្រ ដើម្បីជាមូលដ្ឋានមួយសំរាប់អភិវឌ្ឍន៍ប្រទេសជាតិ។

ហើយសូមបញ្ជាក់ផងដែរថា ព្រះអង្គមិនត្រឹមតែបានសង់នូវផ្លូវថ្នល់នេះតែម្យ៉ាងនោះទេ តែព្រះអង្គនៅបានសង់ធម្មសាលា ឬធម្មសាលាថែមទៀតនៅតាមដងផ្លូវទាំងនេះសំរាប់អោយអ្នកធ្វើដំណើរតាមដងផ្លូវទាំងនោះបានឈប់ព្រមទាំងមានគប់ភ្លើងសំរាប់បំភ្លឺផ្លូវផង។

សំរាប់ធម្មសាលានេះអ្នកប្រាជ្ញខ្លះហៅថា ធម្មសាលា ខ្លះហៅថាអគ្គិសាលា (ព្រោះសាលានេះមានគប់ភ្លើងសំរាប់អោយអ្នក ធ្វើដំណើរបំភ្លឺផ្លូវនៅពេលយប់)។



www.elibraryofcambodia.org

សំរាប់អត្ថបទច្បាប់នេះអ្នករៀបរៀងហៅសាលានេះថា ជាធម្មសាលា ហើយធម្មសាលាទាំងនេះត្រូវបានសង់ឡើងនៅតាមដងផ្លូវនានា ដោយចំងាយពីធម្មសាលាទៅធម្មសាលាមួយមានចំងាយប្រហែល ១២គម_១៨ គម.។

ធម្មសាលានេះទំនងមានបរិវេណសំខាងពីរផ្នែកគឺផ្នែក ដែលជាទីកន្លែងសំរាប់អ្នកធ្វើដំណើរឈប់សំរាក ប្រហែលជាសង់អំពីឈើទើបមិននៅសល់អោយយើងឃើញនាបច្ចុប្បន្ន និងមួយផ្នែកទៀតជាសាសនស្ថានប្រចាំទីកន្លែងសំរាករបស់ធ្វើដំណើរ។ ហើយសាសនៈស្ថាននេះ សព្វថ្ងៃយើងក៏និយមហៅថាប្រាសាទផងដែរ។ ធម្មសាលានេះជាទីកន្លែងប្រតិស្ឋានរូបគោពដូចជារូបព្រះពោធិសត្វជាដើម ដើម្បីជាវត្ថុស័ក្តិសិទ្ធសំរាប់កាពារបីបាច់ដល់អ្នកធ្វើដំណើរ។

សំរាប់ធម្មសាលាដែលជាសាសនស្ថានប្រចាំទីកន្លែងសំរាករបស់អ្នកធ្វើដំណើរនេះ ត្រូវបានសង់ឡើងក្នុងទំរង់ប្លង់ៗដូចគ្នាទាំងអស់។ ខុសគ្នាគឺនៅត្រង់ទំហំនិងការតុបតែងព្រមទាំងឧបករណ៍ក្នុងការសាងសង់ប៉ុណ្ណោះ ដូចជានៅប្រទេសខ្មែរនិយមសង់ដោយថ្មភក់ ចំណែកនៅប្រទេសថៃនិយមសង់ដោយថ្មបាយក្រៀម។ ហើយបញ្ហាដែលគួរអោយសង្កេតផងដែរនោះ គឺធម្មសាលាដែលនៅជិតក្រុងអង្គរតែមានទំហំធំនិងប្រណិតជាងធម្មសាលាដែលនៅឆ្ងាយ។ បញ្ហានេះវាជារឿងធម៌តាដូចជាសព្វថ្ងៃនេះផងដែរ ការអភិវឌ្ឍន៍គេតែងតែអភិវឌ្ឍន៍តំបន់ទីក្រុងជាមុខសិន ទើបទៅដល់តំបន់ដែលនៅដាច់ស្រយាល។



www.elibraryofcambodia.org

ធម្មសាលាដែលព្រះអង្គបានសង់ឡើងមានទាំងអស់១១២កន្លែង ដោយធម្មសាលាទាំងនេះមានទំរង់ប្លង់ដូចៗគ្នាទាំងអស់ពោលគឺជាអាគាររាង ៤ជ្រុងទ្រវែងបែរមុខទៅទិសខាងកើត ចោះបង្អួចនៅជញ្ជាំងខាងត្បូង ចំនួន៥ ចំណែកជញ្ជាំងទិសខាងជើងបួកជញ្ជាំងជិត។




ទំរង់ប្លង់របស់ធម្មសាលា



www.elibraryofcambodia.org



ធម្មសាលាក្នុងប្រាសាទព្រះខ័ន  ជាធម្មសាលាគំរូដែលនៅគង់វង្សល្អ



ទិដ្ឋភាពខាងក្នុងធម្មសាលាក្នុងប្រាសាទព្រះខ័ន



www.elibraryofcambodia.org




ប្រាសាទតាមានធំ ខេត្តឧត្តមមានជ័យ





ថ្មមានរូបព្រះពោធិសត្វ រូបភាពខាងធម្មសាលាប្រាសាទតាមាន់ធំ



www.elibraryofcambodia.org

ចំណែកផ្លូវថ្នល់ទាំងនេះយើងមានឯកសារតិចតួចបំផុតសំរាប់សិក្សា រឿងថ្នល់ទាំងនេះហើយយើងសន្និដ្ឋានថា ផ្លូវទាំងនេះត្រូវបានរលប់អស់ទៅវិញនៅពេលព្រះអង្គចូលរទៅវង្គត់ទៅ ព្រោះប្រទេសជាតិជួបនូវភាពចលាចល ខ្វះការថែទាំនិងជួសជុលបន្ត។

ចំណែកធម្មសាលាវិញត្រូវបានបាត់អស់មួយចំនួនដោយកត្តាមនុស្សដូចជាការជីកតាស់រកកំណប់ទ្រព្យផ្សេងៗ ដែលជាហេតុធ្វើសាសនស្ថាននេះដួលរលំបាក់បែកអស់ព្រមទាំងកត្តធម៌ជាតិដូចជាទឹកជំនន់ជាដើម។ ហើយធម្មសាលានេះក៏ដូចគ្នានិងព្រះវិហារប្រចាំមន្ទីរពេទ្យផងដែរពោលគឺក្រោយរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧មក សាសនស្ថានត្រូវបានប្រជារាស្ត្រនៅតាមតំបន់នីមួយៗកែច្នៃអោយទៅជាសាសនស្ថានព្រះពុទ្ធសាសនាថេរវាទវិញ។

សព្វថ្ងៃធម្មសាលានេះត្រូវបានគេរកឃើញមួយចំនួន១៧កន្លែង នៅតាមដងផ្លូវពីរាជធានីអង្គរទៅកាន់ក្រុងភិម៉ាយ សព្វថ្ងៃស្ថិតនៅភាគឦសានប្រទេសថៃ។ ក្រៅពីនេះគេបានរកឃើញធម្មសាលាមួយចំនួនទៀត ដូចជានៅខេត្តកំពង់ធំ ចំណែកនៅប្រទេសថៃគេបានរកឃើញធម្មសាលាមួយចំនួននៅក្រៅដងផ្លូវពីក្រុងអង្គរធំមកក្រុងភិម៉ាយ ដូចធម្មសាលា២នៅខេត្តរយអិត គឺប្រាសាទតួក្រាដួន និងប្រាសាទជនតួបានមឿងប៊ួ ដោយធម្មសាលានៅចំងាយពីគ្នាប្រមាណ១២គមទៅ១៦គម។ ធម្មសាលា១ទៀតនៅខេត្ត សកលនគរ ជាខេត្តនៅជាប់ដងទន្លេមេគ្គប្រទេសឡាវ



www.elibraryofcambodia.org



បាសាទគូក្រាជូន

ចំណែកនៅស្រុកខ្មែរគេបានរកឃើញធម្មសាលា១នៅស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ធម្មសាលា២ទៀតនៅនៅបរិវេណប្រាសាទព្រះខ័ន ខេត្តសៀមរាម និងមួយទៀតនៅពីមុខប្រាសាទបន្ទាយឆ្មារ។ ខាងក្រោមនេះជាខ្លឹមសារអត្ថបទសិលាចារឹកប្រាសាទតាព្រហ្មស្តីពីផ្លូវថ្នល់ និងធម្មសាលាដែលព្រះអង្គបានសាងសង់÷

គាថាទី១២២ នៅតាមដងផ្លូវពីរាជធានីអង្គរធំទៅកាន់ក្រុងវិជ័យ (រាជធានីអាណាចក្រចម្ប៉ា សម័យព្រះជ័យវរ្ម័នទី៧ អាណាចក្រចម្ប៉ាគឺជាខេត្តមួយរបស់អាណាចក្រខ្មែរ) ព្រះអង្គបានសង់ធម៌សាលាចំនួន៥៧កន្លែងព្រមទាំងមានគប់ភ្លើងសំរាប់បំភ្លឺផ្លូវផង។

គាថាទី១២៣ តាមដងផ្លូវពីរាជធានីអង្គរធំទៅកានក្រុងភីម៉ាយ ព្រះអង្គបានសង់ធម្មសាលាចំនួន១៧កន្លែងព្រមទាំងមានគប់ភ្លើង សំរាប់



www.elibraryofcambodia.org

បំភ្លឺផ្លូវផង។ ពីរាជធានីអង្គធំទៅកាន់ក្រុងជយវតី (សព្វថ្ងៃមិនដឹងនៅទីណា) ទៅក្រុងជយសិង្ហវតី (សព្វថ្ងៃមិនដឹងនៅទីណា)។

គាថាទី១២៤ ពីទីនោះទៅកាន់ក្រុងជយវីរវតីពីក្រុងនេះទៅកាន់ ជយរាជគិរិ ពីជយរាជគិរិទៅកាន់ស្រីសុវិរបុរី (សព្វថ្ងៃមិនដឹងនៅទីណា)។

គាថាទី១២៥ ពីក្រុងនេះ (ស្រីសុវិរបុរី) ទៅកាន់យសោធរបុរៈ (តាមផងផ្លូវដ៏វែងនេះព្រះអង្គបានសង់ធម្មសាលាចំនួន១៤កន្លែង) ១កន្លែងនៅស្រីសូរ្យបពិត សព្វថ្ងៃគឺភ្នំជីសូរខេត្តតាកែវតែសព្វថ្ងៃបានបាក់បែកអស់ទៅហើយ។

គាថាទី១២៦ ព្រះអង្គបានសង់ធម្មសាលាមួយនៅស្រីវិជ្យាទិត្យបុរៈ (សព្វថ្ងៃមិនដឹងនៅទីណា) និងមួយទៀតនៅកល្យាណសិទ្ធកៈ (សព្វថ្ងៃមិនដឹងនៅទីណា) រួមទាំងអស់១២១កន្លែង។



www.elibraryofcambodia.org

# ផ្លូវរាជទៅកាន់ក្រុងភីម៉ាយ

## (Royal Road from Angkor to Phimai)

ក្នុងបណ្តាផ្លូវព្រមទាំងធម្មសាលាទាំងនោះ មានតែផ្លូវទៅកាន់ក្រុងភីម៉ាយមួយប៉ុណ្ណោះដែលគេបានរកឃើញនូវធម្មសាលាគ្រប់ចំនួន១៧កន្លែងដូចដែលសិលាចារឹកប្រាសាទតាព្រហ្មបានកត់ត្រាទុក។

បញ្ហានេះយើងសន្និដ្ឋានថា ក្រុងភីម៉ាយសម័យព្រះបាទជ័យវរ្ម័នទី៧ជាមជ្ឈមណ្ឌលខាងសេដ្ឋកិច្ចនិងសាសនាដ៏សំខាន់មួយ។ ម្យ៉ាងទៀតក្រុងភីម៉ាយក៏ជាដើមកំណើតរាជវង្សរបស់ព្រះអង្គផងដែរ ដោយហេតុនេះទើបព្រះអង្គស្ថាបនាផ្លូវថ្នល់ព្រមទាំងធម្មសាលានេះអោយពិសេសជាងកន្លែងផ្សេងៗទៀត ដោយសង់ធម្មសាលាមួយទៅធម្មសាលាមួយទៀតចំងាយប្រមាណ១២គម. ទៅ១៦គម. រួមរយៈផ្លូវពីក្រុងអង្គរធំទៅកាន់ក្រុងភីម៉ាយមានចំងាយប្រមាណ៣៥៥គម.

ដោយចាប់ផ្តើមពីរាជធានីអង្គរក្នុងខេត្តសៀមរាប (Siem Reap province) និងខេត្តព្រះវិហារ (Udommeanchai province) មុនចូលមកក្នុងខេត្តសុរិន្ទ្រ (Surin province) ខេត្តបុរីរម្យ៍ (Buriram province) និងខេត្តនគររាជសីមា (Nakhorn Rat chasima province) ក្នុងប្រទេសថៃ។



www.elibraryofcambodia.org

នៅតាមដងផ្លូវនេះគេបានរកឃើញធម្មសាលាគ្រប់ចំនួនតាមកាត់ត្រាក្នុងប្រាសាទព្រះខ័នដែលមានទាំងអស់១៧កន្លែង ដោយនៅក្នុងព្រះរាជាណាចក្រកម្ពុជាចំនួន៩កន្លែង និងក្នុងព្រះរាជាណាចក្រថៃ៨កន្លែង។

ខាងក្រោមនេះជាធម្មសាលាពីរាជធានីអង្គរទៅកាន់ទីក្រុងភីម៉ាយ ដោយធម្មសាលាទាំងនេះមានទំរង់ប្លង់ដូចៗគ្នាទាំងអស់រួមមាន៖

ក្នុងព្រះរាជាណាចក្រកម្ពុជាមាន ៩ ប្រកបដោយ

១. ប្រាសាទភ្លី ខេត្តសៀមរាប
២. ប្រាសាទសំពៅ ខេត្តសៀមរាប
៣. ប្រាសាទស្ពានដឹង ខេត្តសៀមរាប
៤. ប្រាសាទស្ពានដឹង ខេត្តសៀមរាប
៥. ប្រាសាទអូរជ្រើង ខេត្តសៀមរាប
៦. ប្រាសាទគោកមន ឧត្តមានជ័យ
៧. ប្រាសាទអំពិល ឧត្តមានជ័យ



www.elibraryofcambodia.org



ប្រាសាទអំពិល

៨. ប្រាសាទព្រហ្មគិល ឧត្តមានជ័យ



បាសាទព្រហ្មគិល



www.elibraryofcambodia.org

៩_ប្រាសាទតាមាន់ធំ ខេត្តឧត្តមមានជ័យ




បាសាទតាមាន់ធំ នៅលើភ្នំដងរែក ខេត្តឧត្តមមានជ័យ



www.elibraryofcambodia.org

ក្នុងព្រះរាជាណាចក្រថៃ មាន៨ កន្លែង ប្រកបដោយ

១. ប្រាសាទថ្ម ខេត្តបុរីរម្យ




២. ប្រាសាទបានបុ ខេត្តបុរីរម្យ






www.elibraryofcambodia.org

៣. ប្រាសាទគោគប្រាសាទ ខេត្តបុរីរម្យ




ប្រាសាទគោគប្រាសាទ

៤. ប្រាសាទណាងប្លុង ខេត្តបុរីរម្យ






www.elibraryofcambodia.org

៦. ប្រាសាទទេពស្ថិត ខេត្តបុរីរម្យ




៧. ប្រាសាទបានសាំរោង ខេត្តបុរីរម្យ






www.elibraryofcambodia.org

៧. ប្រាសាទហ្វយថ្លែង ខេត្តនគររាជសីមា



បាសាទហ្វយថ្លែង

៨. ប្រាសាទគួសិលា ខេត្តនគររាជសីមា




ប្រាសាទគួសិលា



www.elibraryofcambodia.org

## ផែនទីបង្ហាញពីផ្លូវបុរាណនិងធម្មសាលា






www.elibraryofcambodia.org




វ៉ូនវិថីជាឈ្មោះដែលអ្នករៀបរៀងបានដាក់សំរាប់ហៅឈ្មោះផ្លូវបុរាណដែលងាយស្រួលក្នុងការកំណត់សាសនស្ថានផ្សេងៗ ដោយអាស្រ័យឯកសារប្រវត្តិសាស្ត្រ និងបុរាណវិទ្យា ព្រមទាំងសិលាចារឹក ដែលមានដូចខាងក្រោមនេះ៖



www.elibraryofcambodia.org

វ៉ូនវិថីទី១ គឺផងផ្លូវពីរាជធានីអង្គរឆ្ពោះទៅក្រុងវិជ័យ រាជធានីអាណាចក្រចម្ប៉ា (Binh Dinh នាបច្ចុប្បន្ន) នៅតាមផងផ្លូវនេះមានធម្មសាលាចំនួន៥៧កន្លែង។

វ៉ូនវិថីទី២ ពីរាជធានីអង្គរធំទៅកាន់សេដ្ឋបុរៈ (វត្តភូខេត្តចំប៉ាស័កប្រទេសឡាវនាបច្ចុប្បន្ន)។

វ៉ូនវិថីទី៣ ពីរាជធានីអង្គរធំទៅកាន់ប្រាសាទភីម៉ាយនៅភាគឦសានប្រទេសថៃបច្ចុប្បន្នមានធម្មសាលាចំនួន១៧កន្លែង ដោយឆ្លងកាត់តាមខេត្តសៀមរាប ឧត្តរមានជ័យ ភ្នំដងរែក ខេត្តសុរិន្ទ្រ ខេត្តបុរីរម្យ៍ និងខេត្តនគររាជសីមា។

វ៉ូនវិថីទី៤ ពីរាជធានីអង្គរធំទៅកាន់ភាគខាងខាងកើតប្រទេសថៃក្នុងខេត្តប្រាជិនបុរី ស្រះកែវ មានប្រាសាទតូចៗមិនតិចជាង៣០កន្លែង។



www.elibraryofcambodia.org

## ៥. ការធ្វើដំណើររបស់រាជទូតចិន (ជីតាក្វាន់)

ការកត់ត្រារបស់ជីតាក្វាន់ ជាឯកសារដ៏សមខាន់បំផុតស្ដីពីប្រវត្តិសាស្ត្រខ្មែរនាសម័យព្រះបាទជ័យវរ្ម័នទី៧ ព្រោះការកត់ត្រានោះមានលក្ខណៈប្រហាក់ប្រហែលគ្នានិងរូបចំលាក់ទាំងឡាយដែលយើងឃើញនាបច្ចុប្បន្ន។

មួយឆ្នាំក្រោយមកបន្ទាប់ពីដាក់រាជរបស់ព្រះបាទជ័យវរ្ម័នទី៧ គណៈរាជទូតចិនបានអញ្ជើញមកអាណាចក្រខ្មែរ។ ក្នុងចំណោមរាជទូតទាំងនោះមានលោកជីតាក្វាន់ពេលត្រឡប់ទៅប្រទេសចិនវិញ បានសរសេរអត្ថបទមួយស្ដីពីប្រពៃណីខ្មែរ។ ក្នុងការកត់ត្រានេះដែរ លោកជីតាក្វាន់បានពិពណ៌នាអំពីរឿងរ៉ាវផ្សេងៗដែលគាត់បានឃើញបានឮក្នុងអំឡុងពេលដែលស្នាក់នៅក្នុងអាណាចក្រខ្មែរ។

ការកត់ត្រានេះធ្វើអោយយើងបានដឹងអំពីរាជធានីអង្គរធំក្នុងចុងសតវត្សទី១៣ ដែលក្នុងពេលនោះប្រាកដថារាជធានីអង្គរធំស្ថិតសភាពប្រណិតនៅឡើយ។ រាជពិធីផ្សេងៗនៃព្រះមហាក្សត្រខ្មែរធ្វើអោយអ្នកធ្វើដំណើរចិនរូបនេះមានការចាប់អារម្មណ៍យ៉ាងខ្លាំង។ ប្រពៃណីរបស់ជនជាតិខ្មែរធ្វើអោយជីតាក្វាន់មានការភ្ញាក់ផ្អើល សម្បាយរីករាយនិងពេលខ្លះគាត់មានអារម្មណ៍ថាជារឿងគួរធ្វើ។

គួររំលឹកផងដែរថា លោកជីតាក្វាន់រមែងឃើញជីវិតរបស់ជនជាតិខ្មែរតាមរយៈជនជាតចិនដែលស្នាក់នៅក្នុងអង្គរធំមានជនជាតិចិនអាស្រ័យនៅក្នុងអាណាចក្រខ្មែរជាយូរលង់ណាស់មកហើយពួក នេះរស់នៅយ៉ាង



www.elibraryofcambodia.org

សុខសម្បាយ ព្រោះលោកជីតាក្វាន់បានអោយដឹងថា ស្រូវជារបស់ដែលរកបានយ៉ាងអាយស្រួលព្រមទាំងប្រពន្ធស្រួលរក្សួមទាំងព្រមទាំងផ្ទះសំបែងការលក់ដូរក៏មានលក្ខណៈងាយស្រួល ជាហេតុនាំអោយមានអ្នកចូលមករស់នៅក្នុងប្រទេសនេះជាច្រើន។

យ៉ាងណាក៏ដោយលោកជីតាក្វាន់ គាត់បានស្នាក់នៅក្នុងផ្ទះរបស់ជនជាតិខ្មែរ។ ដោយហេតុនេះគត់អាចឃើញប្រពៃណីផ្សេងៗបានច្រើន។ ការអធិប្បាយរបស់គាត់ទាក់ទងនិងក្រុងអង្គរធំត្រូវគ្នានិងសភាពដែលយើងបានឃើញនាបច្ចុប្បន្ន។ មានអ្វីៗជាច្រើនយ៉ាងដែលគាត់បានកត់ទុកត្រូវគ្នានិងរូបចំលាក់ដែលគេឆ្លាក់ក្នុងប្រាសាទបាយ័នឬដែលមានកត់ត្រាទុកក្នុងសិលាចារឹក។



www.elibraryofcambodia.org

## ១. លក្ខណៈរៀងក្រុងអង្គរធំ

ការរៀបរាប់អំពីក្រុងអង្គរធំរបស់លោកជីតាក្វាន់ធ្វើអោយយើងដឹងអំពីប្រាសាទអង្គរវត្ត កំពែង និង កោងទ្វារនៃរាជធានីបានរួមទាំងប្រាសាទបាពួននិងប្រាសាទបាយ័ន។ តែក្នុងពេលបច្ចុប្បន្នយើងមិនអាចមើលឃើញច្រើននូវគ្រប់សំណង់ដែលបាក់បែកទាំងអស់បានទេ។ លោកជីតាក្វាន់ក៏បានចូលទៅក្នុងរាជធានីដែលមានមនុស្សរស់នៅពិតប្រាកដ។ តាមពាក្យអធិប្បាយរបស់គត់ពេលមកដល់រាជធានីអង្គរធំ ក៏ចូលទៅតាមដងផ្លូវមួយដែលមានយក្សពីរជួរនៅអមសងខាងផ្លូវ។ បន្ទប់មកក៏មកដល់ក្លោងទ្វារដែលមានបន្ទើតដោយមុខមនុស្សសំរាប់យើងផ្លូវដើរនាបច្ចុប្បន្ននេះ ផ្លូវចូលនេះដុះព័ទ្ធដោយព្រៃ។

លោកជីតាក្វាន់បានឃើញទ្វារធំដែលបិទនៅពេលយប់ និងបើកនៅពេលនៅពេលព្រឹក។ ព្រមទាំងឆ្មាំទ្វារដែលរង់ចាំហាមមិនអោយចូលសូម្បីតែឆ្កែមួយក្បាល។ ក្រៅពីនេះអ្នកដែលហាមនិមអោយចូលទៅក្នុងចូលទៅក្នុងរាជធានីគឺអ្នកទោសដែលត្រូវកាត់ម្រាមជើងចោល។

ពេលដើរតាមផ្លូវក្នុងរាជធានីលោកជីតាក្វាន់ក៏អាចឃើញកន្លែងតុបតែងរបស់ចៅហ្វាយនាយនិងលំនៅដ្ឋានរបស់មន្ត្រីជាន់ខ្ពស់ដែលលំនៅដ្ឋានទាំងអស់នេះបែរមុខទៅទិសខាងកើត។ លំនៅដ្ឋានខ្លះក៏មានការប្រក់ក្បឿង តែលំនៅដ្ឋានជនសាមញ្ញក៏ប្រក់ដោយស្បូវ។ រូបចំលាក់ក្នុងប្រាសាទបាយ័នក៏បង្ហាញពីលក្ខណៈនៃសំណង់ដូចគ្នានេះផងដែរសំរាប់ក្បឿងដែលរបក្លនោះ



www.elibraryofcambodia.org

ជាគ្រឿងរាងស្រទបចេករាងមូល ចំណែកជាន់ក្រោមជាទីស្នាក់អាស្រ័យរបស់អ្នកបំរើ។ ចៅហ្វាយនាយអាស្រ័យនៅជាន់ខាងលើនៅចំពីមុនផ្ទះចៅហ្វាយនាយទាំងឡាយមានផ្ទះតូចៗធម៌តាសំរាប់ជួយលំអរគេហដ្ឋានធំៗ។

លោកជីតាជជាន់បានពិពណ៌នាអំពីសាសស្ថានខ្មារពួតធំផងដែរ។ សំរាប់ប្រាសាទបាយ័ន គាត់ពោលថា តាំងនៅចំកណ្ដាលអាណាចក្រខ្មែរមានប្រាសាទមាសព័ទ្ធជុំវិញដោយសប្រាសាទសិលាជាង២០ទៀត និងមានព្រះវិហារដ្ឋានដូចៗដោយថ្មភក់រាប់រយទៀត។ ទិសខាងកើតមានស្ពានមាសមានតោមាសពីក្បាលតាំងនៅតាមជ្រុងនៃស្ពាន។

តាមការពិតផ្លូវខាងកើតយើងអាចចូលទៅដល់ប្រាសាទបាយ័ន បានដោយទីលានធំដែលតាំងនៅខាងជើងសរសេរ និងធ្វើអោយយើងអាចដើរឆ្លងកាត់គូទឹកទៅបានដោយមានរូបតោនៅសងខាងផ្លូវនេះ។

លោកជីតាក្វាន់បានកត់ត្រាទៀតថា ប្រហែល១លីទិសខាងជើងមានប្រាសាទស្ពាន់មួយ មានប្រាសាទមាសដែលមានកំពស់ខ្ពស់ជាងប្រាសាទស្ពាន់។ និងរូបភាពដែលយើងមើលឃើញនោះគួរអោយចាប់ចិត្តយ៉ាងពិតប្រាកដ។

ប្រាសាទមាសនេះទំនងជាប្រាសាទបាពួនដែលលោកជីតាក្វាន់ បានឃើញពីចំងាយនូវត្តប្រាសាទកណ្ដាល។ ដែលសព្វថ្ងៃយើងមិនអាចដឹងបានថារូបរាងដើមនៃប្រាសាទយ៉ាងដូចម្ដេច។



www.elibraryofcambodia.org

## ២.ព្រះរាជវាំង

ចុងក្រោយលោកជីតាក្វាន់ក៏បានមកដល់ព្រះរាជវាំងនិងសាសនស្ថាន ក្នុងនោះគឺប្រាសាទវិមានអាកាស។ ខាងមុខព្រះរាជវាំងជិតនិងទីលានធំនៃរាជធានីមានរូបដំរីដែលប្រើសំរាប់រងរាប់អាគារដែលសង់ដោយឈើ។

អាគារទាំងនេះសព្វថ្ងៃបានបាក់បែកអស់ទៅហើយ តែក្នុងសម័យដែលលោកជីតាក្វាន់អញ្ជើញមកក៏នៅគង់វង់ល្អទំនងក្នុងទីនោះ ដែលជាបន្ទប់ប្រជុំ (សាលាមន្ត្រី? អ្នករៀបរៀង) និងខាងក្រោមមានឆ្លាក់រូបដំរីប្រាកដនៅបន្ទប់ទាំងនោះទំនងជាល្អប្រណិតណាស់ ដោយលោកជីតាក្វាន់បាននិយាយពីសរសរទាំងឡាយរាងបួនជ្រុងដែលភ្ជាប់ដោយបញ្ចក់និងស៊ុមបង្គួចដោយមាស។

សំរាប់ព្រះរាជវាំងនោះលោកជីតាក្វាន់សារភាពថា គាត់មិនអាចចូលទៅខាងក្នុងបាន។ ដោយគត់កត់ត្រាទុកថា "ខ្ញុំបានឮក្នុងព្រះរាជវាំងមានទីកន្លែងដែលប្រណិតជាច្រើនកន្លែងតែការការពារក៏មានការពារតឹងតែងខ្លាំងណាស់ខ្ញុំមិនអាចចូលទៅខាងក្នុងបាន"។

ដោយហេតុនោះក៏ទំនងជាពាក្យដែលប្រជារាស្ត្រខ្មែរនិយាយប្រាប់ដែលគាត់បានស្តាប់។ ដែលអាចធ្វើអោយគាត់អាចពិពណ៌នាអំពីរូបរាងដ៏ប្រណិតនៃអាគារ។ មានរានហាលវែងនិងថែវមានដំបូលច្រកទ្វារទាំងឡាយខាងក្នុងបិទជិត។ គាត់មិនអាចូលទៅក្នុងរាជវាំងបាននិងសង្ស័យថាមនុស្សក្នុងវាំងគេរស់នៅយ៉ាងដូចម្តេច? លោកជីតាក្វាន់បានស្តាប់ត្រឹមតែការ ឮ



www.elibraryofcambodia.org

តត្ថាដែលដំណាលអោយស្ដាប់ដោយប្រជារាស្ត្រធម្មតាទាក់ទងនិងការគង់នៅរបស់ព្រះរាជាខ្មែរ។ ហេតុដូចនេះគាត់ទើបអាចដឹងបានថា ជារាល់រាត្រីព្រះរាជាខ្មែរស្ដេចបានយាងទៅប្រាសាទមាសខាងក្នុងព្រះរាជវាំង គឺប្រាសាទវិមានអាកាសបានយ៉ាងដូចម្ដេច?

គាត់បានពិពណ៌នាថា ប្រជារាស្ត្រដែលនៅក្នុងស្រុកអ្នួតថា ក្នុងប្រាសាទមានព្រលឹងសត្វនាគក្បាល៩ ដែលជាម្ចាស់ទីដីនៃអាណាចក្រខ្មែរ។ នាគនេះនិងបង្ហាញខ្លួនជារៀងរាល់រាត្រីក្នុងរូបភាពជាស្ត្រីដ៏ស្អាត។ ព្រះរាជាខ្មែរចាំបាច់ត្រូវទៅផ្ដុំរួមជាមួយព្រះនាង...និងក្នុងយាមទីពាន់រាត្រីទើបអាចយាងត្រឡប់ទៅផ្ទុំជាមួយព្រះអគ្គមហេសីបាន។

ប្រសិនបើរាត្រីណាវិញ្ញាណរបស់នាគនេះមិនបង្ហាញអោយឃើញ ក៏បានសេចក្ដីថាថ្ងៃចូលទីវង្គត់របស់ព្រះរាជានិងជិតចូលមកដល់ហើយ។ បើព្រះរាជាមិនស្ដេចមិនយាងមកក្នុងរាត្រីណាមួយក៏និងមានគ្រោះអាក្រក់កើតឡើង។

លោកជីតាក្វាន់អាចពិពណ៌នាបានយ៉ាងសម្បាយទាក់ទងនិងការស្ដេចយាងចេញទទួលភ្ញៀវរាជធានីនៃព្រះរាជាខ្មែរ ដែលលោកជីតាក្វាន់ក៏ចូលទៅគាល់ជាមួយនិងរាជទូតចិនក្នុងមួយថ្ងៃព្រះរាជាខ្មែរស្ដេចចេញធ្វើសាវនាការ២ដងមន្ត្រីឬប្រជារាស្ត្រដែលត្រូវចូលគាល់ ត្រូវអង្គុយចាំនៅលើដីបន្ទាប់មកនឹងបានឮសំលេងតន្ត្រីពីចំងាយ និងផ្នែកខាងក្រៅក៏និងមានការផ្លុំសង្ខសំដែលការទទួលព្រះរាជា។ ក្រោយពីនោះបន្តិចក៏និងឃើញស្រីស្នំ



www.elibraryofcambodia.org

ក្នុងរាជសំណាក់២នាក់ លើករាំងននឡើងដោយដៃនិងព្រះរាជា ដែលទ្រង់កាន់ព្រះខ័នហើយយាងចេញមកតាមបង្អួចមាស។ សេនាបតីនិងប្រជារាស្ត្រក៏លើកដៃសំពះនិងក្រាបផ្ទាល់និងដី។ ក្រោយពីនោះសំលេងសង្ខបានស្ងប់ចុះពួកដែលមកគាល់ទាំងឡាយទើបអាចងើបឡើងបាន។ បើព្រះរាជាទ្រង់ព្រះករុណាប្រោសគេក៏អាចទៅជិតនិងអង្គុយចុះ... ពេលធ្វើសវនាការរួចរាល់ហើយ ព្រះរាជាស្តេចនិងយាងឡើងស្រីស្នំក្នុងរាជសំណាក់២នាក់ និងបិទរាំងនន ចំណែកអ្នកមកគាល់ទាំងអស់ក៏ក្រោកឡើង។

ក្នុងរូបចំលាក់យើងអាចមើលឃើញព្រះរាជាទ្រង់ប្រថាប់នៅក្នុងអាគារដ៏ប្រណិតព័ទ្ធជុំវិញដោយមន្ត្រីរាជសំណាក់ទ្រង់ទទួលគ្រឿងបណ្ណាការឬដីការពីប្រជារាស្ត្រដែលកំពង់ចូលគាល់។ លោកជីតាក្វាន់មានអារម្មណ៍ជ្រាលជ្រៅក្នុងប្រពៃណីនេះណាស់។ ដោយគាត់សរុបថា “ប្រជារាស្ត្រខ្មែរទាំងឡាយមិនបានបោះបង់ចោលពីចំណេះដឹង តើអ្វីទៅដែលហៅ ព្រះមហាក្សត្រ និងទ្រង់បំពេញតួនាទីនេះយ៉ាងដូចម្តេច?

លោកជីតាក្វាន់បានពិពណ៌នាអំពីព្រះរាជាខ្មែរថា ទ្រង់តែងព្រះកាយយ៉ាងល្អមានតែព្រះរាជាប៉ុណ្ណោះដែលទ្រង់តែងព្រះអង្គ ដោយក្រណាត់ដែលមានផ្កាភ្ញីលើកលើសាច់ក្រណាត់ ដោយមានរាងរឹតរួតហើយព្រះអង្គទ្រង់ពាក់មកុដមាស...ពេលព្រះអង្គទ្រង់មិនពាក់មកុដមាសព្រះអង្គក៏ទ្រង់ម្វរសក់ នៅជុំវិញកំរងផ្កាដែលសាយភាយក្រអូបបែបផ្កាម្លិះ។ នៅជុំវិញព្រះមានពាក់ដោយគុជ៣គ្រប់ធំៗនៅម្រាមដៃមេដៃកជរបស់ព្រះរាជាពាក់ដោយ



www.elibraryofcambodia.org

ខ្សែដៃនិងចញ្ចៀនមាសដោយមានដាំត្បូងពេជ្រភ្នែកឆ្មាជាច្រើនគ្រប់។ ព្រះយាងដោយបាតជើងទទេ ហើយបាតជើងនិងបាតដៃមានលាបថ្នាំក្រហមដោយគ្រឿងផ្សំនុសថពណ៌ក្រហម ពេលណាព្រះអង្គយាងចេញពីព្រះរាជវាំងព្រះអង្គនិងកាន់ដាវមាសនៅនិងព្រះហត្ថផង។

**៣.សង្គម**

របបសង្គមខ្មែរមិនបានប្រែប្រួលច្រើនទេនៅរវាងសតវត្សទី១២_១៣ តែយ៉ាងណាដោយការកត់ត្រារបស់លោកជីតាក្វាន់ ធ្វើអោយយើងដឹងសភាពនៃសង្គមខ្មែរដែលយើងមិនអាចដឹងបានពីខ្លឹមសារក្នុងសិលាចារឹក។ ក្នុងការកត់ត្រារបស់ជីតាក្វាន់បានផ្តល់នូវភាពសំខាន់ចំពោះព្រះសង្ឃក្នុងព្រះពុទ្ធសាសនាច្រើនជាងពួកព្រាហ្មណ៍ ដែលគាត់ហៅថាបន្តី (Pan ki) ព្រោះគាត់ជាជនជាតិចិន។ លោកជីតាក្វាន់ទើបទំនងគ្មានសម្ព័នភាពជាមួយពួកព្រាហ្មណ៍ច្រើនទេ។ តែយ៉ាងណាក៏ដោយពួកព្រាហ្មណ៍ក៏នៅអំណាចនៅឡើយទោះបីព្រះពុទ្ធសាសនានិកាយថេរវាទ ក៏ក្លាយជាទីនិយមរបស់ប្រជារាស្ត្រខ្មែរកាន់តែច្រើនក៏ដោយ។

លោកជីតាក្វាន់ព្រមទទួលស្គាល់ថា គាត់មិនដឹងរឿងទាក់ទងនឹងព្រះអទិទេពដែលពួកព្រាហ្មណ៍គោរពបូជារួមទាំងគម្ពីរដ៏ស័ក្តិសិទ្ធ។ គាត់ពោលថាពួកបន្តីតែងខ្លួនដូចជនជាតិខ្មែរផ្សេងៗទៀត តែពួកគេបានកំណត់ខ្សែសរសៃរត្ងចរបស់សាសនាព្រហ្មណ៍ដែល ពួកគេបានចងជាប់និងកហើយពួកចាកចេញពីជីវិតធម្មតា។ គាត់បានពិពណ៌នាពីភាពសំខាន់របស់



www.elibraryofcambodia.org

ពួកព្រាហ្មណ៍ក្នុងសង្គមដោយពោលថា ពួកបន្ទីទាំងឡាយដែលបំរើរាជការបានជារាជការជាន់ខ្ពស់ការពិពណ៌នានេះត្រូវគ្នានិងខ្លឹមសារក្នុងសិលាចារឹកដែលទាក់ទងនិងការទទួលមន្ត្រីរាជការ។

លោកជីតាក្វាន់នៅពោលពីភាពសំខាន់របស់មន្ត្រីរាជការ និងរបបមន្ត្រីរាជការក្នុងសង្គមខ្មែរថា «ក្នុងប្រទេសនេះមានទីប្រឹក្សាឧត្តមសេនីយ៍និងអ្នកហោរាស្រ្តជាច្រើននាក់។ល។ និងនៅពីក្រោមអ្នកទាំងនេះនៅមានមន្ត្រីរាជការតូចៗជាច្រើនទៀត......ភាគច្រើនចៅហ្វាយនាយនិងត្រូវជ្រើសរើសជាមន្ត្រី។ ហើយអ្នកដែលត្រូវជ្រើសជាមន្ត្រីនោះនិងត្រូវយកកូនស្រីរបស់ទៅថ្វាយស្តេចធ្វើជាស្ត្រីស្នំ។ គ្រឿងឥស្សរិយយសទាំងឡាយនិងបរិវារដែលនៅក្រោមបន្ទប់ពីចៅហ្វាយនាយនិងបរិវារ ក៏រំមែងស្ថិតនៅតាមលំដាប់ថ្នាក់ផងដែរ»។

ជនវណ្ណៈកណ្តាលដែលរស់នៅយ៉ាងស្រួល លោកជីតាក្វាន់បាននិយាយពីប្រជាជនធម្មតាថា «មានមាឌធំសម្បុរខ្មៅហើយពួកគេរស់នៅក្នុងដំបន់ដែលដាច់ស្រយាលនៅលើកោះនៃមហាសមុទ្រ ឬនៅតាមផ្លូវទាំងឡាយដែលគេទៅមកញឹកញាប់»អ្នកដែលអោនលំទោនខ្លាំងជាទាសករសំរាប់អ្នលបំរើគេបានទិញមនុស្សព្រៃមកធ្វើការប្រភេទនេះ អ្នកមានទាសករជាចំនួនច្រើនអាចមានច្រើនជាង១០០នាក់ ចំណែកអ្នកដែលមានចំនួនតិចក៏មានចំនួនតាំងតែ១០នាក់ដល់២០នាក់។ ចំពោះអ្នកក្របុំណ្ណោះដែលគ្មានទាសករ។ ពួកមនុស្សព្រៃទាំងនេះជាមនុស្សដែលរស់នៅក្នុងល្អាងភ្នំ ជាពួជ



www.elibraryofcambodia.org

មួយដែលខុសប្លែកពីអ្នកស្រុកពួកទាសករទាំងនោះ គឺគេអោយដេកអង្គុយនៅតែក្រោមផ្ទះ។ លុះតែមានភាពចាំបាច់ប៉ុណ្ណោះទើបអាចឡើងទៅលើផ្ទះបាន ហើយត្រូវលិតជង្គង់លើកដៃសំពះចៅហ្វាយនាយជាមុនសិន ទើបគេអាចចូលទៅក្នុងផ្ទះបានប្រសិនពួកគេមានកំហុស និងវាយដំធ្ងន់ធ្ងរហើយពួកគេនិងសុខចិត្តអោយគេវាយតាមចិត្តដោយមិនហ៊ានរើបំរះឡើយ។

## ៤.សកម្មភាពប្រជារាស្ត្រ

យើងស្ទើរតែមិនដឹងសោះឡើយនូវរឿងរ៉ាវដែលទាក់ទង និងជីវិតរបស់ប្រជារាស្ត្រខ្មែរក្នុងក្រុងអង្គរចន្លោះសតវត្សទី១១_១២ ព្រោះហេតុថាចំណេះដឹងស្ទើរតែទាំងអស់យើងបានមកពីសិលាចារឹក ដែលមិនទាក់ទងនិងប្រជារាស្ត្រធម្មតាតែយ៉ាងណាក៏ដោយ តាំងតែដើមសតវត្សទី១២រហូតដល់សតវត្សទី១៣រូបចំលាក់ទាំងការកត់ត្រារបស់ជីតាក្វាន់ យើងក៏បានចំណេះដឹងដែលគួរអោយចាប់អារម្មណបំផុត ដែលទាក់ទងទៅនឹងជីវិតប្រចាំថ្ងៃរបស់ប្រជារាស្ត្រសាមញ្ញ។ អាចពោលបានថា ការកត់ត្រារបស់ជីតាក្វាន់នោះត្រូវគ្នានិងរូបចំលាក់ដែលប្រាកដមាននៅប្រាសាទបាយ័ន។

ការលក់ដូរជាភារកិច្ចចំបងមួយរបស់អ្នកដែលរស់ក្នុងក្រុង លោកជីតាក្វាន់បានពោលថា ការលក់ដូរភាគច្រើនលក់ដូរដោយស្ត្រី ការលក់ដូរបានធ្វើឡើងយ៉ាងងាយៗ គេគ្មានរានដាក់លក់ប្រចាំតែប្រើកន្ទេលក្រាលលើដីហើយក៏នាំគ្នាធ្វើការលក់ដូរ។ ខ្ញុំបានឮគេនិយាយគ្នាថា ដំលៃថ្នួលទីកន្លែងនោះត្រូវបង់អោយមន្ត្រីអ្នកលក់តូចតាច ពួកគេជួញអង្គប្រភេទ



www.elibraryofcambodia.org

ផ្សេងៗនិងរបស់ដែលនាំមកពីប្រទេសចិន បន្ទាប់ពីនោះក៏មានការលក់ក្រណាត់ផ្សេងៗបើការលក់ដូរធំៗទើបគេប្រើមាសនិងប្រាក់។

អ្នកជនបទនិងនាំផលិតផលរបស់ខ្លួនមកលក់ដូចជា ខ្ទឹមបារាំង ត្រប់ ឪឡឹក ឃ្លោក និងផ្លែឈើផ្សេងៗទៀត។ ពេលជិតាក្វាន់ដើរលេងនៅក្នុងក្រុងគាត់បានឃើញការត្បាញអំបោះ ដែលជាទីនិយមជាច្រើនតែក៏មានសំពត់ដែលនាំចូលពីបរទេស ដូចជាចាមជាដើមនិងសំពត់ដែលនិយមបំផុតដែលនាំចូលពីសមុទ្រ ខាងលិចដែលមានគុណភាពខាងសាច់ក្រណាត់ម៉ត់ល្អ។

លោកជីតាក្វាន់ចាប់អារម្មណ៍បំផុតនូវមុខទំនិញ ដែលប្រជារាស្ត្ររួមជាតិរបស់គាត់ចូលចិត្តទិញនៅអាណាចក្រខ្មែរដូចជា៖ ភ្លុកដំរី កុយមាស ក្រមួនឃ្មុំ ក្រវាញ ម្រេច ជ័រឈើ ។ល។

## ៥.ជីវភាពផ្ទាល់ខ្លួន

ទោះបីជនជាតិបរទេសត្រូវបានគាបសង្កត់អោយចេញពីព្រឹត្តិការណ៍ក្នុងជីវិតប្រចាំថ្ងៃរបស់ជនជាតិខ្មែរក៏ដោយ។ តែលោកជីតាក្វាន់ក៏បានដឹងទាក់ទងនិងប្រពៃណីជាច្រើនយ៉ាង ដែលគាត់អាចសង្កេតឃើញបានចន្លោះពេលដែលគាត់បានស្នាក់នៅជាមួយក្រុមគ្រួសារខ្មែរ ឬអ្វីដែលគាត់បានដឹងពីមិត្តរួមពីមិត្តរួមដំណើររបស់គាត់ ដែលដឹងរឿងរ៉ាវនេះច្រើនខ្លះតិចខ្លះ។

ពេលគាត់ចូលទៅក្នុងផ្ទះរបស់ជនជាតិខ្មែរ ដែលមិនសូវមានប៉ុន្មានក៏និងឃើញថាមានត្រឹមតែពាងទឹក២_៣តាំងនៅលើដី។ មានភាជនះ និង



www.elibraryofcambodia.org

ចង្ក្រានដែលធ្វើដោយដីឥដ្ឋដុតយ៉ាងធំ។ ឧបករណ៍ប្រើប្រាស់ទាំងនេះយើងអាចឃើញបានក្នុងផ្ទះតាមភូមិដែលប្រាកដមានក្រោមរូបភាព ការច្បាំងគ្នារបស់កងទ័ពជើងទឹកខ្មាតធំ ដែលឆ្លាក់នៅលើជញ្ជាំងថែវផ្នែកខាងត្បូង នៃប្រាសាទបាយ័ននិងយើងអាចឃើញបានទៀតក្នុងសម័យនេះក្នុងផ្សារ ក្រុងភ្នំពេញឬក្រុងកំពង់ឆ្នាំ។ ពេលខ្លះឧបករណ៍ជាគ្រឿងបន្ទប់បន្សំជនជាតិខ្មែរថ្នាក់កណ្តាលមានផ្ទះតែគ្មាន តុ កៅអី ភាជនៈលោហៈ ឬធុងទឹកសំរាប់ប្រើប្រាស់ទេ គេប្រើឆ្នាំងដីដើម្បីដាំបាយ គេប្រើចានទាបបាតរាក់សំរាប់ដាក់ទឹកជ្រលក់ដោយដាក់លើដីគេយកថ្មពាដុំមកកល់ធ្វើជាចង្ក្រាន។ ហើយយកត្រឡោកដូងមកធ្វើជាវែកដួសសំឡ។ គេប្រើចានទាបមកពីស្រុកចិនដែលធ្វើអំពីឥដ្ឋឬស្ពាន់សំរាប់ដាក់បាយគេយកស្លឹកឈើមកកេវ ខ្ទាស់ធ្វើជាកន្តោងមិនអាចលិចទឹកបានសំរាប់ដាក់សំឡ និងទឹកជ្រលក់។

លំនៅដ្ឋានរបស់មន្ត្រីទាំងឡាយ មានអចលនៈវត្ថុដ៏សម្បូរណ៍បែប «លំនៅដ្ឋានរបស់មន្ត្រីឬអភិជនជួនកាលប្រើភាជនៈធ្វើដោយប្រាក់ខ្លះ ធ្វើដោយមាសផងដែរ។ ក្នុងប្រទេសនេះពេលមានពិធីផ្សេងៗពួកគេនិងប្រើភាជនៈជាច្រើនប្រភេទដែលធ្វើដោយមាស...នៅលើដីក្រាលកន្ទេល... ឬ ក្រាលស្បែកខ្លាធំ ខ្លារខិន ស្បែកប្រើស ស្បែករមាំង ឬប្រើកន្ទេលដែលធ្វើពីផ្តៅ។ ពេលមិនយូរមកនេះជនជាតិខ្មែរក៏ចាប់ផ្តើមប្រើតុតឿៗកំពស់ប្រហែល១ហត្ថ។ ពេលគេដេកគេមិនប្រើកន្ទេលទេគេដេកលើរនាបពេលថ្មីៗនេះមានអ្នកខ្លះចាប់ផ្តើមប្រើគ្រែទាបៗ សំរាប់ដេកផងដែរដែល



www.elibraryofcambodia.org

នាំចូលពីប្រទេសចិន។

មិនថាអ្នកមានឬក្រជនជាតិខ្មែរ រមែងស្លៀកពាក់ដោយក្រណាត់ក្រាស់ៗនិងថ្លៃបំផុតសំលៀកបំពាក់ ដែលកត់ត្រាដោយជីតាក្វាន់នោះវាដូចគ្នានិងអ្វីដែលយើងឃើញនៅតាមរូបចំលាក់ ដែលមានមនុស្សស្រីក៏ដូចជាមនុស្សប្រុសដែរ គឺតែស្លៀកពាក់មិនស្លៀកពាក់ក្រៅពីកន្លែងបិទបាំងកេរ្តិ៍ខ្មាស់របស់គេបន្តិចប៉ុណ្ណោះ ពួកគេដើរដោយជើងទទេសក់របស់ពួកគេនិងបួងឡើង។ លោកជីតាក្វាន់បានអធិប្បាយបន្តទៀតថា ស្ត្រីតាមធម្មតាមិនតែងពាក់គ្រឿងប្រដាប់នៅក្បាល តែពួកគេពាក់កងដៃ ឬចិញ្ចៀនធ្វើអំពីមាស។

លោកជីតាក្វាន់បានរៀបរាប់បន្តិចបន្តួចអំពីរឿងរ៉ាវដែលទាក់និងពិធីបុណ្យខាងសាសនា ដែលធ្វើជាការចំពោះសំរាប់គ្រួសានីមួយៗដូចជាការកើតរៀបអាពាពិពាហ៍និងការស្លាប់ តែគាត់គាត់ក៏បានរៀបរាប់អំពីការបំផ្លាញព្រហ្មចារីយ៍របស់ស្ត្រី និងបោះសាកសពអោយទានដល់ត្មោត ឬឆ្កែប៉ុណ្ណោះ។

## ៦.ពិធីបុណ្យប្រពៃណីជាតិខ្មែរនាសម័យបុរាណអង្គរ

ក្នុងបណ្តាពិធីបុណ្យប្រចាំឆ្នាំដែលសំខាន់បំផុតនាសម័យអង្គរគឺទំនងជាពិធីបុណ្យចូលឆ្នាំ។ ដោយមានការដុតកាំជ្រួចនិងគ្រឿងចំបាំងទាំងឡាយពិធីបុណ្យទាក់ទងនិងនាវាជើងទឹកមួយដែលរៀបចំធ្វើនៅខែទី៥ ដែលគេសន្និដ្ឋានថា ជាពិធីបុណ្យអំទូកនាសម័យបច្ចុប្បន្ន។ ដោយគេប្រារព្ធធ្វើនៅ



www.elibraryofcambodia.org

ដំណាច់រដូវវស្សាហើយទឹកក៏ហូរត្រឡប់ពីទន្លេវិញដែរ។ នៅទីបញ្ចប់លោកជីតាក្វាន់ក៏បានរៀបរាប់អំពីពិធីបុណ្យមួយគឺពិធីបុណ្យអភិសេកព្រះពុទ្ធរូប។-

ការរៀបចំបុណ្យដោយព្រះរាជាបានហៅពិធីបុណ្យនេះថា ជាល្បែងកំសាន្តដែលនាំអោយរីករាយក្នុងចិត្ត ហើយដែលនៅគង់វង់និងរក្សាទុកក្នុងព្រះរាជវាំងក្រុងភ្នំពេញរហូតដល់សព្វថ្ងៃនេះ។ គេបានជួបជុំគ្នានៅលើវេទិការដ៏ធំមួយដែលលំអរដោយគោមព្យួរនិងផ្កាភ្ញីទាំងឡាយនៅទីលានព្រះរាជវាំងគេបានយាងព្រះរាជាអោយយាងទៅទតពីទស្សនីយភាពនេះ។

ពេលខ្លះនៅតាមផ្លូវនៃក្រុងអង្គរធំក៏មានក្បួនហែរយ៉ាងអធិកអធមពេលព្រះរាជាស្តេចទៅទតចេតិយ៍មាសតូចៗដែលនៅពីមុខ មានព្រះពុទ្ធរូបមាស។ លោកជីតាក្វាន់បានរៀបរាប់អំពីក្បួនហែរដ៏គួរអោយសរសើរនេះថា មានទាហានសេះទង់ធំ។ និងតន្ត្រីនាំមុខក្បួនហែរបន្ទាប់មកមានស្រីស្នំក្នុងរាជសំណាក់ដែលមានចំនួនច្រើនជាង៣០០នាក់កាន់ទៀន ព្រមទាំងភាជនះមាសនិងប្រាក់ មានទាហានស្ត្រីស្នំអ្នកកាពារកាន់ជាច្រើន អ្នកកាន់ស្គរលំពែងខែល។ល។ បន្ទាប់មកពួកនាហ្មឺនសព្វមុខមន្ត្រីសេនាបតី ព្រះរាជានិងព្រះអគ្គមហេសីតូចធំនិងស្រីស្នំព្រះរាជាជាច្រើននាំគ្នាដើរតាម និងដើរបន្តពីក្រោយបន្ទាប់មកទៀត ទើបព្រះរាជាទ្រង់ឈរលើខ្នងដំរីដោយព្រះហត្ថកាន់ព្រះខ័នទិព្វ។ បើសិនបើស្តេចយាងទៅណាជិតៗឬគ្មានកិច្ចការសំខាន់ក្នុងពេលនោះព្រះអង្គមិនគង់នៅលើគ្រែស្នែងមាសដែលសែងដោយស្រីស្នំ៤នាក់នោះទេ។



www.elibraryofcambodia.org

## ៦.ឯកសារពិគ្រោះ

Bosselier J.Asie du Sud - Est.Paris:Ernest Leroux , 1966

Chandler,DavidP.A HistroryofCambodia.Bouler, Colorado:Westview Press, 1983

ChouTa-Kuan.TheCustomsof Cambodia.Bangkok: The Siam Society,1992.

East Asia.Bangkok:S.N.,1984

Coedés, G.Angkor: An Introduction.trans.Emily Flored Gerdiner, Hong Kong:Oxford University Press, 1967

_____The Indianized States of Southeast Asia.trans.Susan Brown Cowing.Kuala Lumpur University of Malaya,1968

Dumarcay,Jacques.CambodaiArchitecture :

eighth to thieteenth Centuries. By Jacques Dumarcay and Pascal Royre.Trans and ed.Michael Smithies. Leiden and Boston: Brill, 2001

Higham, Charles.The Civilization of Angkor. London: Weidenfeld &Nicolson,2001.

Dagens,B. "Centralime et arechitecture:Les hopitau de JayavaMan VII".Recentes recherché en archeology en Thailande. Bangkok:Silpakorn University, 19991

Madeleine Giteiu.Histoire d' Angkor(ม.จ.สุภัทรดิศ ดิศกุล แปล) มหาวิทยาลัยศิลปากร, ๒๕๔๓

Woodward Jr.,H.W.The Sacred Sculpture of Thailand.Bangkok:River Book,1977

ชะเอม แก้วคล้อย .**จารึกพระเจ้าชัยวรมันที่ ๗**.กรุงเทพฯกรมศิลปากร,๒๕๒๕



www.elibraryofcambodia.org

บุญเรือง คัชมาย์,มรดกอารยธรรมพนมดองแรก(The heritage of Dongreak Civilization Vol.1)มหาวิทยาลัยราชภัฏสุรินทร์ ๒๕๕๑

--------สด็อกก๊อกธม ,กรมประชาสัมพันธ์จังหวัดสระแก้ว, ๒๕๔๕

นิคม มูสิกะคามะ,โบราณคดีกัมพูชา,กรมศิลปากร, ๒๕๔๓

--------ปราสาทหินภิมาย,กรมศิลปากร, ๒๕๔๓

ผาสุก อินทราวุธ.พุทธปฏิมากรฝ่ายมหายาน.กรุงเทพฯ โรงพิมพ์อักษรสมัย,๒๕๓๕

-------รูบเคารพในศาสนาอินดู ,กรุงเทพฯภาควิชาโบราณคดี คณะโบราณคดี **มหาวิทยาลัยศิลปากร,๒๕๒๒**

พีริยะ ไกรฤษ์,ประวัติศาสตร์ศิลปะในประเทศไทย ฉบับคู่มือนักศึกษา.กรุงเทพฯอมรินท**ร์พริ้นติ้ง,**๒๕๒๕

--------อารยธรรมไทย.พื้นฐานทางประวัติศาสตร์ศิลปะ เล่ม ๑.กรุงเทพฯอมรินทร์ติ้ง๒๕๒๘

มโน กลีบทอง. “วฒนธรรมร่วมแบบเขมรในประเทศไทย” พัฒนาการอารยธรรมไทย **กรุงเทพฯกรมศิลปากร,**๒๕๓๖

วรรณวิภา สุเนต์ตา.ชัยวรมันที่ มหาราชองค์สุดท้ายของอาณาจักรกัมพูชา.กรุงเทพฯมติชน, ๒๕๔๘



www.elibraryofcambodia.org

วิศวภัทร มณีปัทมเกตุ(แปล).พระไภษัชยคุรุไวฑูรยประภา

สัปตพุทธปูรวปณิธานวิเศษสูตร.กรุงเทพฯ ส่องศยาม,๒๕๔๔

ศิลปากร,กรม.โครงการและรายงานการสำรวจและการขุด

แต่งในภาคตะวันออกเฉียง

เหนือ ภาคที่ ๑ พ.ศ. ๒๕๐๒.กรุงเทพฯกรมศิลปากร,๒๕๐๓

--------- โครงการและรายงานการสำรวจและการขุดแต่งใน

ภาคตะวันออกเฉียงเหนือ

ภาคที่ ๒ ปี พ.ศ. ๒๕๐๔.กรุงเทพฯกรมศิลปากร,๒๕๑๐

---------จารึกในประเทศไทย,เล่ม ๒,๓,๔ กรุงเทพฯกรม

ศิลปากร ,๒๕๒๘

---------ทำเนียมโบราณสถานขอมในประเทศไทย,เล่มที่ ๑ .

กรุงเทพฯกรมศิลปากร,

๒๕๓๕

---------ทำเนียมโบราณสถานขอมในประเทศไทย,เล่มที่ ๑ .

กรุงเทพฯกรมศิลปากร,

๒๕๓๖

---------ทำเนียมโบราณสถานขอมในประเทศไทย,เล่มที่ ๑ .

กรุงเทพฯกรมศิลปากร,



www.elibraryofcambodia.org

๒๕๓๗

---------ทำเนียมโบราณสถานขอมในประเทศไทย,เล่มที่ ๑ . กรุงเทพฯกรมศิลปากร,

๒๕๓๘

---------ทำเนียมโบราณสถานขอมในประเทศไทย,เล่มที่ ๑ . กรุงเทพฯกรมศิลปากร,๒๕๓๙

ยอร์เซแดส(G.Cedés)นครวัด(Angkor).ปรานีวงษ์เทศแปล. กรุงเทพมหานรนมหาวิทยาลัย ธรรมศาสตร์ ร่วมกับมูลนิธิ โครงการตำรา สังคมศาสตร์และ มนุษย์ศาสตร์,๒๕๒๖

สุจิตต์ วงษ์เทศ(บรรณาธิการ).นครวัด ทัศนะเขมร. กรุงเทพมหานคร:ศิลปวัฒนธรรม,๒๕๔๕

สุภัทรดิศ ดิศกุล,หม่อมเจ้า.ประวัติศาสตร์ศิลปะประเทศใกล้เคียง.กรุงเทพมหานคร:ศิลปวัฒนธรรม,๒๕๔๐

***สุภัทรดิศ ดิศกุล.ม.จ. "ศิลาจารึกปราสาทพระขรรค์ของพระเจ้าชัยวรมันที่ ๗ ปีที่ ๑๐เล่มที่ ๑ (กรกฎาคม ๒๕๓๙)***

สุภัทรดิศ ดิศกุล.ม.จ.หมอมเจ้า(ทรงแปล) "ที่พักคนเดินทางของพระเจ้าชัยวรมันที่ ๗"ศิลปวัฒนธรรม ปีที่ ๑๖ ฉบับที่ ๑(ธันวาคม ๒๕๓๗)



www.elibraryofcambodia.org

สุภัทรดิศ ดิศกุล.ม.จ.ศิลปะขอม(กรุงเทพฯ)โรงพิมพ์คุรุสภา ,๒๕๓๙

สุภัทรดิศ ดิศกุล.ม.จ. ปราสาทเขาพระวิหาร. กรุงเทพมหานคร:ด่านสุทธาการพิมพ์ ๒๕๓๖

หมอมราชวงค์สุริยวุฒิ สุขสวัสดิ์,ปราสาทเขาพนมรุง ศาสนบรรพตที่งดงามที่สุดในประเทศไทย ,พิมพ์ครั้งที่ ๔ (กรุงเทพ), ๒๕๓๙

หมอมราชวงค์สุริยวุฒิ สุขสวัสดิ์,กัมพูชาราชลักษมีถึงศรีชับวรมัน,กรุงเทพมหานคร:สำนักพิมพ์มติชน , ๒๕๔๓



www.elibraryofcambodia.org

## ៧. ប្រវត្តិអ្នករៀបរៀង

ព្រះនាម ព្រះភិក្ខុ សួង ធន់ **(ឧត្តមវរោ)**

ទីកន្លែងកំណើត ភូមិតាម៉ា ឃុំបឹងព្រះ ស្រុកបាភ្នំ ខេត្តព្រៃវែង

ថ្ងៃ ខែ ឆ្នាំ ២៥ តុលា ១៩៧៨

**ប្រវត្តិការសិក្សា**

ឆ្នាំ១៩៨៧_១៩៩២ ជាសិស្សសាលាបឋមសិក្សាដីថុយ

ឆ្នាំ ១៩៩២_១៩៩៤ ជាសិស្សអនុវិទ្យាល័យបឹងព្រះ

ឆ្នាំ ១៩៩៤_១៩៩៥ ជាសិស្សអនុវិទ្យាល័យរក្សជ័យ

ឆ្នាំ១៩៩៥_១៩៩៨ ជាសិស្សវិទ្យាល័យបាភ្នំ

ឆ្នាំ១៩៩៩_២០០០ ជានិស្សិតត្រៀមសកលវិទ្យាល័យភូមិមិន្ទភ្នំពេញ

ឆ្នាំ ២០០១ បានបួសជាភិក្ខុក្នុងខ័ណ្ឌសីមា វត្តឃ្លាំងសេដ្ឋី ឃុំបឹងព្រះ ស្រុកបាភ្នំ ខេត្តព្រៃវែង

ឆ្នាំ២០០២ សិក្សាធម្មសិក្សានិងអក្សរសាស្ត្រថៃ នៅវត្តព្រហ្មសុវណ្ណ ស្រុកតាព្រះយា ខេត្តស្រះកែវ ប្រទេសថៃ

ឆ្នាំ២០០៣_២០០៧ ជាសមណនិស្សិតពុទ្ធិកសកលវិទ្យាល័យ
**(Mahachulalongkornrajavidyalaya University)**
ឆ្នាំ២០០៧_២០១០ជាសមណនិស្សិតពុទ្ធិកសកលវិទ្យាល័យ
**(Mahamakutrajavidyalaya University)**

**បច្ចុប្បន្ន** ជាសាស្ត្រាចារ្យបង្រៀននៅសកលវិទ្យាល័យរាជផាត់ ប្រទេសថៃ
ទូរស័ព្ទ ០៨៤៦០៧៦៣១៦



www.elibraryofcambodia.org

យើងខ្ញុំជាកូន ខ្វៅ យុនសំរ៉ង ខ្វៅ យ៉ាតណៃ ខ្វៅសុខផល ខ្វៅ វិសាល ខ្វៅ រ៉ាមុន
ខ្វៅ ភារាដា ខ្វៅ ចំរើន ខ្វៅ ភារី

បានឧបត្ថម្ភការផ្សាយសៀវភៅនេះជាeBook
ដើម្បីឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធ ឧបាសក ខ្វៅ ពាញ និង ឧបាសិកា ឈរ យឿន

ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ

**មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ**

ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្កេន ជា eBook ដោយ សៀង ស៊ីវ៉ាន់

កក្កដា ឆ្នាំ ២០១៥

បើលោក-លោកស្រីចង់បានសៀវភៅនេះ ឬអានបន្តទៅទៀត សូមទិញ ឬជាវពីអ្នកនិពន្ធ

ឬបណ្ណាគារដោយផ្ទាល់ដើម្បីគោរព "រក្សាសិទ្ធិ" របស់អ្នកនិពន្ធ។

យើងខ្ញុំ ពុំមានការព្រាស្រ័យទាក់ទង ដោយប្រភេទណាមួយជាមួយអ្នកនិពន្ធ ឬបណ្ណាគារទេ។

សូមអរគុណ

ខ្វៅ យុនសំរ៉ង

ប្រធាន

**មូលនិធិខ្មែរសម្រាប់ការសិក្សា**

www.elibraryofcambodia.org